ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

**កំណត់ហេតុជាលាយលក្ខណ៍អក្សរ**

**នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"**

**សាធារណៈ**

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩**

**សវនាការលើកទី៧១**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

កញ្ញា ណាតាចា វីស៊ែល រីស៊ី

*(Ms. Natacha Wexels-Riser)*

លោក ម៉ាតូ គ្រីស្ពារ *(Mr. Matteo Crippa)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក វីលៀម ស្មីត *(Mr. William SMITH)*

លោក តាន់ សេណារ៉ុង

លោក អានីស អះមេដ *(Mr.Anees AHMED)*

លោក សេងប៊ុនឃាង

លោក វាំងសង់ ដឺវ៉ាយដ៍ ដេស្មាឯល

*(Mr.Vincent DE WILDE D'ESTMAEL)*

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

កញ្ញា ទី ស្រ៊ីនណា

លោក គឹម ម៉េងឃី

លោក ហុង គឹមសួន

លោក គង់ ពីសី

លោក អាឡាំង វែ៉នណឺ

*(Mr. Alain Werner)*

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Christine MARTINEAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

# ឧបសម្ព័ន្ធ

## លោក គ្រីស្តូហ្វឺ ឡាប៉ែល

ស្តួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................................................ទំព័រ ១
ស្តួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ....................................................ទំព័រ ៥
ស្តួរដោយលោកស្រី ជា លាង ផ្តើមពី ....................................................ទំព័រ ១១
ស្តួរដោយលោក ដឺវ៉ាយដ៍ ដេស្នាឯល ផ្តើមពី ....................................................ទំព័រ ១៣
ស្តួរដោយលោក ហ្វ្រង់ស្វ័រ រូ ផ្តើមពី....................................................ទំព័រ ១៩

## ជនជាប់ចោទ: កាំង ហ្កេកអ៊ាវ ហៅ ឌុច

ស្តួរបន្តដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ....................................................ទំព័រ ៣០

## លោក ស្តេហ្វិន ហាសែ្សល

ស្តួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................................................ទំព័រ ៤០
ស្តួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ....................................................ទំព័រ ៤១
ស្តួរដោយលោក តាន់ សេណារ៉ុង ផ្តើមពី ....................................................ទំព័រ ៤៤
ស្តួរដោយលោក ដឺវ៉ាយដ៍ ដេស្នាឯល ផ្តើមពី ....................................................ទំព័រ ៤៥
ស្តួរដោយលោកស្រី គ្រីស្ទីន ម៉ាទីណូ ផ្តើមពី ....................................................ទំព័រ ៤៧
ស្តួរដោយលោក ហុង គឹមសួន ផ្តើមពី ....................................................ទំព័រ ៥០
ស្តួរដោយហ្វ្រង់ស្វ័រ រូ ផ្តើមពី....................................................ទំព័រ ៥៣

## ជនជាប់ចោទ: កាំង ហ្កេកអ៊ាវ ហៅ ឌុច

ស្តួរបន្តដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ....................................................ទំព័រ ៦២

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោកស្រី ជា លាង | ខ្មែរ |
| លោក វ៉ាំងសង់ ដឺវ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក ស្តេហ្វិន ហាស្សែល | បារាំង |
| លោក ហុង គឹមសួន | ខ្មែរ |
| លោក គ្រីស្តូហ្វឺ ឡាប៉ែល | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ | បារាំង |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| លោកស្រី គ្រីស្ទីន ម៉ាទីណូ | បារាំង |
| លោក វីលៀម ស្មីត | អង់គ្លេស |
| លោក តាន់ សេណារ៉ុង | ខ្មែរ |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោក អាឡាំង វែនណឺ | អង់គ្លេស |
| កញ្ញា ណាតាចា វីស៊ែល វីសឺ | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលមកកាន់បន្ទប់សវនាការ)*

[០៩:០៥:០០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។ ហើយតាមកាលវិភាគដែលបានគ្រោងទុកនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងដំណើរការស្តាប់សក្ខីកម្មសាក្សីដែលបញ្ជាក់អំពីអត្តចរិតជនជាប់ចោទចំនួនពីររូប គឺនៅព្រឹកនេះមួយរូប ហើយនៅរសៀលនេះមួយរូបទៀត ។

ក្រឡាបញ្ជី, សវនាការឡើងរាយការណ៍ អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី និងបុគ្គលដែលត្រូវអញ្ជើញចូលរួមនៅក្នុងកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន! ភាគីដែលត្រូវចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅក្នុងថ្ងៃនេះមានវត្តមានគ្រប់ចំនួន ។ ចំណែកឯសាក្សី និងអ្នកជំនាញដែលត្រូវមកផ្តល់សក្ខីកម្មនៅក្នុងថ្ងៃនេះមាន៖ សាក្សី គ្រីស្តូហ្វឺ ឡាប៉ែល មានវត្តមានរង់ចាំការកោះហៅពីអង្គជំនុំជម្រះ, អ្នកជំនាញ ស្តេហ្វិន ហាស្បែល នឹងត្រូវមកផ្តល់សក្ខីកម្មតាមរយៈការចូលរួមពីចម្ងាយពីប្រទេសបារាំង ។ អ្នកជំនាញ និងសាក្សីទាំងពីររូបនេះមិនមានចំណងញាតិលោហិត និងញាតិពន្ធជាមួយនឹងជនជាប់ចោទ ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ អ្នកជំនាញ និងសាក្សីទាំងពីររូបនឹងធ្វើសម្បថនៅចំពោះមុខអង្គជំនុំជម្រះ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការអញ្ជើញសាក្សី គ្រីស្តូហ្វឺ ឡាប៉ែល ចូលមកកាន់សាលសវនាការ ។

*(លោក គ្រីស្តូហ្វឺ ឡាប៉ែល ចូលមកក្នុងសវនាការ)*

[០៩:០៨:១៧]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អរុណសួស្តីសាក្សី! តើលោកមាននាមត្រកូល និងនាមខ្លួនរបស់លោក គ្រីស្តូហ្វឺ ឡាប៉ែល អ៊ីចឹងពិតមែនដែរឬទេ?

**ឆ៖** ឈ្មោះរបស់ខ្ញុំគឺ គ្រីស្តូហ្វឺ ឡាប៉ែល ។

**ស៖** លោក គ្រីស្តូហ្វឺ ឡាប៉ែល តើលោកមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ខ្ញុំមានអាយុ ៥១ឆ្នាំ ។

**ស៖** តើសព្វថ្ងៃនេះលោកមានទីលំនៅ នៅទីកន្លែងណាដែរ?

**ឆ៖** ខ្ញុំរស់នៅ ឡូសអេនចាឡឹស កាលីហ្វូនីញ៉ា ប្រទេសសហរដ្ឋអាមេរិក ។

**ស៖** តើលោកមានមុខរបរ ឬក៏វិជ្ជាជីវៈធ្វើអ្វីដែរ?

**ឆ៖** ខ្ញុំគឺជាគ្រូគង្វាល ។

**ស៖** តើលោកមានសញ្ជាតិអ្វីដែរ?

**ឆ៖** ខ្ញុំជាជនជាតិអាមេរិកាំង ។

**ស៖** តើលោកកាន់សាសនាអ្វី?

**ឆ៖** ខ្ញុំគឺជាគ្រីស្តសាសនិកជន ។

**ស៖** លោកគ្រីស្តូហ្វឺ ឡាប៉ែល តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះថា លោកមិនមានចំណងញាតិលោហិត ឬក៏ញាតិពន្ធ ឬក៏ជាសហព័ទ្ធជាមួយនឹងភាគីនៃរឿងក្តីនេះទេ ។ តើពិតមែនដែរឬទេ?

**ឆ៖** តើលោកប្រធានអាចនិយាយសាថ្មីបានដែរឬទេ?

**ស៖** តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការថា លោកមិនមានចំណងញាតិលោហិត ញាតិពន្ធ ឬក៏ជាសហព័ទ្ធជាមួយនឹងភាគីណាមួយនៃរឿងក្តីនេះទេ ។ តើពិតដែរឬទេ របាយការណ៍នេះ?

**ឆ៖** បាទ គឺដូច្នោះមែន ។

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជីសវនាការអន្តរជាតិ កញ្ញា ណាតាចា សូមរៀបចំដល់លោក គ្រីស្តូហ្វឺ ឡាប៉ែល ដើម្បីធ្វើសម្បថតាមជំនឿសាសនារបស់លោក ។

[០៩:១១:២៥]

**កញ្ញា ណាតាចា វីស៊ែល វីសឺ៖**

អរុណសួស្តី! សូមឲ្យលោកថាតាមខ្ញុំ ។

ខ្ញុំសូមប្រកាសជាឱឡារិកថា ខ្ញុំនិយាយតែការពិត និងស្មោះត្រង់ គ្មានអ្វីក្រៅពីការពិត ។

**លោក គ្រីស្ទូហ្វឺ ឡាប៉ែល៖**

(គ្មានការបកប្រែ)

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក គ្រីស្ទូហ្វឺ ឡាប៉ែល តើលោកធ្លាប់បានស្គាល់ជនជាប់ចោទ ឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ពីមុនមកដែរឬទេ?

**ឆ៖** ខ្ញុំបានជួបគាត់នៅចុងខែធ្នូ ឆ្នាំ១៩៩៥ នៅចំការសំរោង ខេត្តបាត់ដំបង នៅពេលដែលគាត់បានមកចូលរួម គោរពព្រះរបស់យើង និងចូលរួមនៅក្នុងកិច្ចប្រជុំសាសនា ។

**ស៖** ហើយចាប់ពីពេលនេះមករហូតដល់បច្ចុប្បន្ននេះ តើលោកនៅដែលធ្លាប់ប្រាស្រ័យទាក់ទងជាមួយនឹងជនជាប់ចោទ ឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែរឬទេ?

**ឆ៖** តាំងពីពេលដែលខ្ញុំជួបគាត់នៅក្នុងឆ្នាំ១៩៩៥មក គាត់នៅពេលនោះក្លាយទៅជាអ្នកគោរពសាសនារបស់យើងខ្ញុំ ។ ហើយបន្ទាប់មកខ្ញុំប្រារពពិធីជ្រមុជទឹកជូនគាត់នៅក្នុងខែមករា ថ្ងៃទី០៦ ឆ្នាំ១៩៩៦ ។ ក្រោយមកទៀត គាត់បានចូលរួមនៅក្នុងប្រជុំបរិស័ទជាមួយនឹងយើងខ្ញុំ ។ បន្ទាប់មក នៅក្នុងឆ្នាំ១៩៩៧ បន្ទាប់ពីរដ្ឋប្រហារ ខ្ញុំទទួលបានដំណឹងថា គាត់បានធ្វើការនៅក្នុងក្រសួងជាមួយនឹងខាងជំរំជនភៀសខ្លួននៅព្រំដែនថៃ ។

**ស៖** ហើយក្រោយមកទៀត តើលោកធ្លាប់បានធ្វើការប្រាស្រ័យទាក់ទង ជាមួយជនជាប់ចោទទៀតដែរឬទេ? ហើយការប្រាស្រ័យទាក់ទង រវាងលោកជាមួយនឹងជនជាប់ចោទហ្នឹង ក្នុងនាមទំនាក់ទំនងយ៉ាងម៉េចដែរ?

**ឆ៖** ថ្មីៗនេះ ខ្ញុំបានជួបរូបគាត់ ដែលមកជួប និងធ្វើការប្រារពគោរពរៀបចំពិធីសាសនា ថ្វាយបង្គំសាសនា ហើយយើងបានជួបគ្នានៅថ្ងៃអាទិត្យ ។ ហើយខ្ញុំបានជួបគាត់ប៉ុន្មានដងដែរ កាលពីអតីតកាលកន្លងទៅពីរបីឆ្នាំមុននេះ ។

**ស៖** តាមទំនាក់ទំនងរវាងលោកជាមួយនឹងជនជាប់ចោទហ្នឹង អាចនិយាយថា លោកគឺជាគ្រូគង្វាលរបស់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច អ៊ីចឹងពិតមែន-- អាចនិយាយអ៊ីចឹងបានដែរឬទេ?

**ឆ៖** បាទ, ពិតជាដូច្នោះមែន។ ខ្ញុំជាគ្រូគង្វាលរបស់គាត់។ ហើយខ្ញុំបានស្នើសុំជួបជាមួយនឹងគាត់ ដើម្បីធ្វើការប្រារពពិធីគោរព និងសិក្សាគម្ពីគ្រីស្ត ហើយនិងធ្វើការគោរពទៅដល់ព្រះ ។

[០៩:១៥:៤៦]

**ស៖** តាមអ្វីដែលលោកបាននិយាយរៀបរាប់ប្រាប់ដល់អង្គសវនាការ ចំពោះសំណួររបស់ខ្ញុំគឺបង្ហាញថា លោកមានការប្រាស្រ័យទាក់ទងជាច្រើន ជាមួយនឹងជនជាប់ចោទ ។ សំណួរសួរថា អង្គជំនុំជម្រះសុំឲ្យលោកនិយាយរៀបរាប់ជូនដល់អង្គសវនាការ អំពីអត្តចរិតរបស់ជនជាប់ចោទឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលលោកធ្លាប់បានដឹង ឬបានកត់សម្គាល់នៅក្នុងអំឡុងពេលដែលលោកបានស្គាល់និងជួបប្រាស្រ័យទាក់ទងជាមួយនឹងជនជាប់ចោទកន្លងមក ។ តើយ៉ាងម៉េចដែរ?

**ឆ៖** នៅពេលដែលខ្ញុំបានជួបគាត់ តាំងពីឆ្នាំ១៩៩៥ មកទល់ពេលបច្ចុប្បន្ន ខ្ញុំអាចយល់ឃើញអំពីអត្តចរិតរបស់គាត់ថាជាបុរសមួយរូបដែលមានទឹកចិត្ត ហើយបុរសដែលស្រលាញ់គោរពព្រះហើយគាត់ប្តេជ្ញា ទៅលើការគោរពព្រះ និងចូលរួមចែករំលែកជាមួយនឹងអ្នកដទៃ ។ ហើយគាត់គឺជាបុរសដែលមានភាពជិតស្និទ្ធនិងរួសរាយ ហើយគឺមានភាពស្មោះត្រង់ រាក់ទាក់ ហើយនិងដូចដែលខ្ញុំលើកឡើងគឺរួសរាយណាស់ ។

**ស៖** ក្នុងអំឡុងពេលដែលលោកបាន ធ្វើការប្រាស្រ័យទាក់ទងក្នុងនាមជាគ្រូគង្វាល ហើយនិងអ្នកកាន់សាសនាគ្រិស្តសាសនាជាមួយនឹងលោកហ្នឹងថាតើលោកដែលឃើញ ឬក៏កត់សម្គាល់ ជនជាប់ចោទបង្ហាញអំពីវិប្បដិសារីរបស់គាត់ ចំពោះអំពើដែលគាត់បានប្រព្រឹត្តពីអតីតកាលដែរឬទេ? ឬក៏លោកបានដឹង អំពីជីវប្រវត្តិរបស់គាត់ពីអតីតកាលដែរឬទេ នៅអំឡុងពេលដែលគាត់ប្រាស្រ័យទាក់ទងជាមួយលោក?

**ឆ៖** ខ្ញុំមិនបានដឹងច្រើនអំពីអតីតកាលរបស់គាត់នោះទេ ប៉ុន្តែខ្ញុំបានស្គាល់គាត់ក្នុងនាមជាបុរសមួយរូបដែលគាត់ចូលរួមនៅក្នុងបេសកកម្មសាសនា ដែលខ្ញុំនឹកឃើញទៅលើករណីទាំងអស់នេះ ហើយគាត់ចូលរួមនៅក្នុងបេសកកម្មសាសនា ។ នៅពេលដែលខ្ញុំជួបគាត់ម្តងៗគឺ ខ្ញុំធ្វើការថ្វាយបង្គំជាមួយនឹងគាត់ ហើយនិងសិក្សាគម្ពីគ្រិស្ត ហើយជំរុញឲ្យគាត់មានភាពរឹងមាំនិងគោរពទៅលើព្រះ ។ ហើយធម្មតាគឺគាត់និយាយអំពីពិរុទ្ធភាពរបស់គាត់ ចំពោះនូវអ្វីដែលគាត់បានប្រព្រឹត្តខុសទៅដល់មនុស្សទាំងឡាយ ហើយគាត់បានអារម្មណ៍សោកស្តាយចំពោះចំណុចទាំងអស់នុ៎ង ។

**ស៖** ចាប់តាំងពីពេលដំបូងដែលលោកបានស្គាល់គាត់ ហើយរហូតមកពេលចុងក្រោយដែលលោកបានជួបប្រាស្រ័យទាក់ទងជាមួយគាត់ចុងក្រោយនេះ តើលោកអាចបញ្ជាក់ដល់អង្គជំនុំជម្រះបានដែរឬទេថា តើកិរិយាមាយាទ ឬក៏អត្តចរិតរបស់គាត់មានការវិវឌ្ឍន៍ប្រែប្រួលដូចម្តេចដែរ តាមដែលលោកបានកត់សម្គាល់?

**ឆ៖** ប្រសិនបើខ្ញុំមិនដឹងអំពីអតីតកាលរបស់គាត់ ខ្ញុំពិបាកជម្រាបថា តើគាត់ជាមនុស្សយ៉ាងម៉េចណាស់នៅក្នុងពេលអតីតកាល ។ ប៉ុន្តែ ដូចដែលខ្ញុំបានជម្រាបលោកប្រធានអ៊ីចឹង គឺខ្ញុំមិនគាត់បានប្រព្រឹត្តអ្វីខ្លះនៅអតីតការនោះទេ ។ ប៉ុន្តែ នៅពេលដែលគាត់ចូលរួមគោរពទៅព្រះ ខ្ញុំសង្កេតឃើញថាគាត់ជាមនុស្សមួយរូបដែលជាមនុស្សដែលមានសីលធម៌ ហើយគោរពទៅលើព្រះ ហើយគាត់មានសន្តិភាព និងមានភាពរីករាយក្នុងចិត្តចំពោះអ្វីដែលគាត់បានគោរពទៅលើព្រះ ហើយរស់នៅជាមួយជាមួយព្រះ ។

គាត់គឺជាបុរសល្អមួយរូប ប្រសិនជាខ្ញុំមិនដឹងអតីតកាលនូវអ្វីដែលកើតឡើងទេ គឺខ្ញុំយល់ឃើញថាគាត់គឺជាមនុស្សដ៏ល្អមួយរូប ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីត្រូវសួរដល់សាក្សីរូបនេះទេ?

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ។

[០៩:២១:២៩]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

អរុណសួស្តីលោកគ្រូគង្វាល! ខ្ញុំមានសំណួរមួយចំនួនតូច បើសិនជាខ្ញុំយល់ត្រឹមត្រូវនោះ លើកដំបូងដែលលោកជួបជនជាប់ គឺនៅចុងខែធ្នូឆ្នាំ១៩៩៥ ហើយលោកបានបញ្ជាក់ថា គាត់ត្រូវបានទទួលពិធីជ្រមុជទឹកនៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៩៦ ។

**ស៖** ថាតើនរណាគេជាអ្នកធ្វើពិធីជ្រមុជទឹក ថាតើលោក កាំង ហ្គេកអ៊ាវ ទទួលបានពិធីជ្រមុជទឹកនេះ ឬក៏អ្នកណាផ្សេងនៅក្នុងថ្ងៃនុ៎ង?

**ឆ៖** លោកចៅក្រមជាទីគោរព! ខ្ញុំបានជួបគាត់នៅចុងខែធ្នូ ឆ្នាំ១៩៩៥ បន្ទាប់ពីគាត់ឮពាក្យថាព្រះ គាត់បានប្រគល់ជីវិតជូនព្រះ ហើយបន្ទាប់ពីនោះមកយើងខ្ញុំបានធ្វើពិធីជ្រមុជទឹកទៅលើគាត់ ។ ខ្ញុំមានក្រុមការងារដែលធ្វើការជាមួយខ្ញុំ ហើយខ្ញុំចាំថាកាលនោះមានគ្រូគង្វាល ដានអាលីស ផងដែរ ។ យើងខ្ញុំបានធ្វើពិធីជ្រមុជទឹកលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច នៅទន្លេសង្កែខេត្តបាត់ដំបង គឺយើងធ្វើពិធីនោះនៅថ្ងៃទី ៦ ខែមករា ឆ្នាំ១៩៩៦ ។

**ស៖** នៅក្នុងប្រជុំគ្រិស្តបរិស័ទ ថាតើលោកធ្វើការធ្វើប្រារព្ធពិធីជ្រមុជទឹកនេះទៅលើឈ្មោះ កាំង ហ្គេកអ៊ាវ ឬក៏ឈ្មោះ ផ្សេង?

**ឆៈ** ខ្ញុំសូមបញ្ជាក់ឈ្មោះ កាំង ហ្កេកអ៊ាវ ។ នៅពេលដែលខ្ញុំបានជួបគាត់នៅក្នុងឆ្នាំ១៩៩៥ ពេលនោះហើយ គឺខ្ញុំមិនស្គាល់ឈ្មោះ កាំង ហ្កេកអ៊ាវ ឬក៏ ឌុច នោះទេ ។ ខ្ញុំស្គាល់ឈ្មោះ ហង់ ពិន នៅពេលនោះ ។ នៅពេលដែលយើងខ្ញុំបានប្រារព្ធពិធីជ្រមុជទឹក កាំង ហ្កេកអ៊ាវ នៅពេលនោះគឺមិនមែនគាត់ឈ្មោះ កាំង ហ្កេកអ៊ាវ ទេ គឺគាត់មានឈ្មោះ ហង់ ពិន ។ នៅពេលថ្មីៗនេះ នៅក្នុងឆ្នាំ១៩៩៩ ប្រហែលជាក្នុងអំឡុងខែមេសា នៅពេលនោះខ្ញុំបានឮឈ្មោះ ហង់ ពិន ដែលឈ្មោះពិតប្រាកដរបស់គាត់ គឺ កាំង ហ្កេកអ៊ាវ ហៅ ឌុច ។

**សៈ** ដូច្នេះ លោកកំពុងតែជម្រាបយើងខ្ញុំថា មិនមែនជនជាប់ចោទខ្លួនឯងគាត់លាតត្រដាងទៅលើអត្តសញ្ញាណរបស់គាត់នោះទេ ។ អត្តសញ្ញាណគាត់នេះគឺលោកដឹងក្រោយមកតែប៉ុណ្ណោះ នៅពេលដែលលោកទទួលបាននូវព័ត៌មានអំពីអត្តសញ្ញាណរបស់ជនជាប់ចោទ ហើយបុគ្គលណាដែលប្រាប់លោកអំពីឈ្មោះពិតប្រាកដរបស់គាត់?

**ឆៈ** លោកចៅក្រម! ខ្ញុំបានចងចាំថានៅពាក់កណ្តាល ឬក៏ចុងខែមេសា ឆ្នាំ១៩៩៩ ខ្ញុំទទួលបានការហៅទូរស័ព្ទពីបុគ្គលមួយរូបជាអ្នកសារព័ត៌មានមកពី អេភី (AP) ដែលប្រាប់ខ្ញុំថា មាន-- សួរខ្ញុំអំពី ហង់ ពិន ហើយគឺគាត់សួរខ្ញុំថា តើខ្ញុំស្គាល់គាត់ដែរឬទេ? ខ្ញុំបានប្រាប់គាត់ថា ខ្ញុំស្គាល់ឈ្មោះ ហង់ ពិន ហើយគាត់អ្នកកាសែតនោះប្រាប់ខ្ញុំវិញថា ឈ្មោះរបស់គាត់នោះ គឺ កាំង ហ្កេកអ៊ាវ នេះជាចំណុចមួយដែលធ្វើឲ្យខ្ញុំមានការភ្ញាក់ផ្អើល ។ ប៉ុន្តែ ខ្ញុំគិតថា ខ្ញុំយល់ឃើញឲ្យខ្ញុំមានការសប្បាយរីករាយថា តែខ្ញុំស្គាល់មនុស្សមួយរូប ដែលកាលពីមុនគាត់ធ្វើជាអ្នក-- ធ្វើជាឃាតក ហើយក្រោយមកគាត់ក្លាយជាអ្នកចូលរួមគោរពទៅលើសាសនាវិញ ។

[០៩:២៥:៥៥]

**សៈ** តើលោកអាចជួយពន្យល់ជូនអង្គជំនុំជម្រះសាលាដំបូង និងសាធារណជនបានដែរឬទេ? ថាតើពិធីជ្រមុជទឹកនោះវាធ្វើយ៉ាងម៉េច ហើយគេតម្រូវលក្ខខណ្ឌពីបុគ្គលមួយរូបយ៉ាងម៉េចដើម្បីឲ្យគាត់អាចទទួលនូវពិធីជ្រមុជទឹក ហើយវាមានអត្ថន័យយ៉ាងម៉េចចំពោះពិធីជ្រមុជទឹកនោះ? ហើយចំពោះលោកថា តើជនជាប់ចោទនឹងគាត់ទទួលឆ្លងកាត់បទពិសោធន៍អ្វីខ្លះពីពិធីជ្រមុជទឹកនេះ?

**ឆៈ** លោកចៅក្រម, បុគ្គលដែលខ្ញុំធ្វើជ្រមុជនេះ គឺគាត់ត្រូវតែជាបុគ្គលដែលគាត់ទទួលដំណឹងនិងជឿអំពីព្រះ ហើយបុគ្គលដែលទទួលនិងគោរពទៅលើព្រះ ហើយខ្ញុំត្រូវផ្តល់ពន្យល់អត្ថន័យរបស់គាត់ថា ពិធីជ្រមុជនេះមានន័យយ៉ាងម៉េច? ក្រោយពីបុគ្គលនោះគាត់យល់អំពីពិធីនេះ ទើបយើងនាំគាត់ទៅ

ទន្លេ ឬស្ទឹង ឬកន្លែងដែលមានទឹក នៅទីនោះហើយដែលយើងធ្វើការប្រារព្ធពិធីជ្រមុជទឹកក្នុងនាមជាព្រះជាម្ចាស់ ព្រះយេស៊ូ ។

[០៩:២៧:៣៤]

**ស៖** ប្រសិនបើខ្ញុំយល់ត្រឹមត្រូវនោះ គឺជាការប្តូរសាសនាពាក្យនេះ បានន័យថាបុគ្គលម្នាក់គាត់ប្តូរសាសនាគោរពទៅលើសាសនាផ្សេង ។ ប៉ុន្តែ អ្វីដែលខ្ញុំចង់ដឹងនោះគឺថាការធ្វើសេចក្តីសន្និដ្ឋាន ឬការសម្រេចចិត្តចំពោះភាពស្មោះត្រង់និងវិធីគោរព ហើយនិងវាមានភាពភ្លឺថ្លាទៅលើពិធីនេះ ។ ថាតើពិធីសាសនាជ្រមុជទឹកនេះអាចចាត់ទុកថាវាជាភាពត្រឹមត្រូវដែរឬទេ? ទោះបីជាបុគ្គលម្នាក់ធ្វើការលាក់កំបាំងទៅលើសេចក្តីការពិតរបស់គាត់ចំពោះបុគ្គលដែលគាត់ព្យាយាមចង់ទទួលនូវពិធីជ្រមុជទឹកនេះ?

**ឆ៖** លោកចៅក្រមជាទីគោរព! ខ្ញុំនៅចាំទៅលើបុគ្គលមួយដែលយើងបានធ្វើពិធីជ្រមុជទឹកជូនគាត់ គឺថាបុគ្គលនោះត្រូវតែជាអ្នកស្ម័គ្រចិត្តតាមឆន្ទៈរបស់គាត់ក្នុងការទទួលយកព្រះជាម្ចាស់ក្នុងជីវិតរបស់គាត់ ហើយជាព្រះដែលជួយសង្គ្រោះទៅដល់រូបគាត់ ។ ហើយមនុស្សនោះត្រូវតែចូលរួមដោយឆន្ទៈក្នុងការស្វែងយល់និងសិក្សាអំពីព្រះ ហើយគាត់ត្រូវយល់អំពីអត្ថន័យនៃពិធីជ្រមុជទឹក ។ ខ្ញុំចងចាំទៅលើពិធីជួយសង្គ្រោះ ហើយឲ្យបុគ្គលនោះគាត់យល់ ដូច្នេះហើយទើបយើងធ្វើពិធីជ្រមុជទឹកជូនគាត់។

[០៩:២៩:៣៧]

**ស៖** ដូច្នេះ បុគ្គលដែលគាត់ទទួលពិធីជ្រមុជទឹកគឺគាត់ ត្រូវបានជួយសង្គ្រោះ ។ បានន័យថាកើតជីវិតសាជាថ្មី ថាតើលោកកំណត់ន័យនឹងយ៉ាងម៉េចនៅក្នុងសាសនារបស់លោក? ថាតើមានការលើកឡើងអំពីកម្មដែរឬទេ? ហើយថាតើគេគិតយ៉ាងម៉េចទៅលើកម្មទាំងឡាយនោះ ឬក៏អំពើបាបនោះ?

**ឆ៖** ខ្ញុំហៅថា វាជាការកើតឡើងវិញនៃសាសនាគ្រិស្ត និងបុគ្គលដែលគោរពសាសនាគ្រិស្ត។ គឺបុគ្គលនេះគាត់មានឆន្ទៈរស់នៅសាជថ្មីនៅក្នុងជីវិតជាមួយនឹងព្រះ ខ្ញុំនៅចាំនៅពេលដែលខ្ញុំបានជួប ឌុច ឬក៏ ហង់ ពិន នាពេលនោះ ។ នៅចុងឆ្នាំ១៩៩៥ ខ្ញុំបានពិនិត្យទៅលើអត្តចរិត ហើយគិតថាគាត់ជាបុគ្គលមួយរូបដែលរស់នៅក្នុងជីវិតដែលទុក្ខសោក ហើយមិនមានសន្តិភាព និងមិនមានសេចក្តីរីករាយ ហើយមិនមានគោលដៅសម្រាប់ជីវិតរបស់គាត់ ។ ប៉ុន្តែ ក្រោយពីគាត់ទទួលបាននៅពិធីជ្រមុជទឹក ខ្ញុំអាចយល់ឃើញថា គាត់គឺជាមនុស្សមួយរូបដែលផ្ទុយនឹងមានអត្តចរិត មួយរយភាគរយគឺខុសពីមុន គឺគាត់ក្លាយទៅជាបុគ្គលមួយរូបដែលថា គាត់ជាបុរសដែលមាននូវភាពសប្បាយរីករាយ និងសន្តិភាពនៅក្នុងខ្លួនរបស់គាត់វិញ ហើយគាត់យល់អំពីអត្ថន័យនៃជីវិតរបស់គាត់ ។

ខ្ញុំបានចាំយ៉ាងច្បាស់នូវថ្ងៃដែលគាត់ទទួលបានពិធីជ្រមុជទឹកគឺ គាត់មានភាពខុសគ្នាស្រឡះតែម្ដង គឺគាត់ពាក់វ៉ែនតា ហើយគាត់ស្លៀកពាក់ ហើយនិងនៅពេលដែលគាត់អង្គុយនៅក្នុងពិធីសិក្សាទៅលើពិធីសិក្សាទៅលើសាសនានោះគឺគាត់ប្ដូរកន្លែងពីក្រោយមកអង្គុយខាងមុខ ហើយគាត់បានសួរអំពីព្រះជាម្ចាស់ ហើយគាត់និយាយការជួយសង្គ្រោះនិងនិយាយ និងសួរអំពីបាបផងដែរ ។ នៅពេលដែលគាត់ទទួលបានការបណ្ដុះបណ្ដាលជាមេដឹកនាំក្នុងរយៈពេលដែលគាត់សិក្សានោះ គឺបន្ទាប់មកគឺគាត់ត្រឡប់មកភូមិរបស់គាត់ ហើយគាត់ធ្វើការបើកនៅព្រះវិហារប្រជុំគ្រិស្ដបរិស័ទចូលរួមជាមួយនឹងបុរសនិងស្ត្រី និងកូនក្មេងផ្សេងៗ ។ នេះហើយដែលខ្ញុំហៅថា គ្រិស្ដស្មៀន ដែលកើតជាថ្មីឡើងវិញដែលនៅក្នុងចិត្តរបស់ជននោះ គឺថាមិនមែនជាជនដែលថាមក ហើយស្នើសុំពិធីជ្រមុជទឹកតែប៉ុណ្ណឹងទេ ។

[០៩:៣២:៥២]

**ស៖** លោកគ្រូគង្វាល, នៅពេលដែលបានជួបជនជាប់ចោទ នៅចុងឆ្នាំ១៩៩៥ នោះ តើគាត់បានប្រាប់អ្វីលោកទេមុនពេលកិច្ចប្រជុំនោះ? តើលោកធ្លាប់ឮគាត់ថា គាត់បានមានការបណ្ដុះបណ្ដាល ឬក៏ការរៀបចំអ្វីដែរឬទេ មុននឹងពេលជួបលោកនោះ? តើលោកបានដឹងអំពី-- តើគាត់បានដឹងអំពីគ្រិស្ដសាសនាទេមុនពេលដែលគាត់បានជួបលោកនៅឆ្នាំ១៩៩៥ ខែធ្នូនោះ?

**ឆ៖** លោកចៅក្រមជាទីគោរព! ខ្ញុំមិនច្បាស់ទេពីបញ្ហានោះ ប៉ុន្តែខ្ញុំច្បាស់នៅពេលដែលគាត់មកបានជួបខ្ញុំ ហើយមកចូលរួមធ្វើថ្វាយបង្គំព្រះ ហើយចូលរួមក្នុងវគ្គអប់រំមេដឹកនាំសាសនា ខ្ញុំអាចពិនិត្យឃើញថា គាត់ជាមនុស្សម្នាក់ដែលរស់នៅក្នុងភាពជំនឿ-- ភាពមិនមានសេចក្ដីស្រឡាញ់ និងសេចក្ដីទុក្ខ ហើយនិងគ្មានសន្តិភាព ប៉ុន្តែក្រោយមកខ្ញុំអាចពិនិត្យឃើញថាក្រោយពីពិធីជ្រមុជទឹកមកគាត់ជាមនុស្សថ្មីមួយទៀត ។

[០៩:៣៤:២០]

**ស៖** អ៊ីចឹងលោកនិយាយថា នៅចុងឆ្នាំ១៩៩៥ គាត់បានទទួលពិធីជ្រមុជទឹកនៅថ្ងៃទី៦ មករា ឆ្នាំ១៩៩៦ នេះគឺជាពិធីប្ដូរសាសនាមួយដ៏លឿនមួយ តើមនុស្សទាំងអស់អ្នកដែលទទួលការពិធីជ្រមុជទឹក ហើយក៏បានប្ដូរលឿនអ៊ីចឹង តើ ឌុច ហ្នឹងជាមនុស្សពិសេសជាងគេ ឬយ៉ាងម៉េច?

**ឆ៖** លោកចៅក្រមជាទីគោរព! ខ្ញុំនៅចាំថា អ្នកទាំងអស់ដែលបានចូលរួមក្នុងពិធីថ្វាយបង្គំព្រះ ហើយនិងចូលរួមក្នុងការអប់រំមេដឹកនាំសាសនានៅឆ្នាំ១៩៩៥ នៅក្នុងខែធ្នូនោះ ខ្ញុំមានការលំបាកក្នុងការអធិប្បាយបន្ទាប់ពីអ្នកទាំងអស់នោះ គាត់ឮព្រះបន្ទូលព្រះហើយ ហើយព្រះបានចូលសន្និតនៅក្នុងបេះ

ដួងរបស់គេ ក្នុងចិត្តគេ ហើយអ្នកទាំងនោះបានចូលមកជួប ហើយមកជួបបានទទួលព្រះយេស៊ូថា ជាព្រះៗអង្គសង្គ្រោះរបស់គេ ។ ហើយខ្ញុំមិនអាចត្រួតត្រាលើចិត្តគំនិតផ្ទៃរបស់គេ។ ប៉ុន្តែ ខ្ញុំអាចឃើញអ្នកទាំងអស់នោះ ដែលមកបង្ហាញខ្លួនបន្ទាប់ពីការទទួលបានការអញ្ជើញខ្ញុំ ហើយគាត់បានចូលខ្លួនមកសុំទទួលព្រះជាព្រះសង្គ្រោះរបស់គេនោះមួយចំនួនច្រើន ។

**ស៖** ដូច្នេះ បន្ទាប់ពីពួកគេបានឮព្រះបន្ទូលព្រះក្នុងរយៈពេលក្រោយមក ហើយគេក៏ទទួលពិធីជ្រមុជទឹក។ ប៉ុន្តែ ក្នុងករណីជនជាប់ចោទ ហើយគាត់បានចូលរួមក្នុងពិធីអប់រំមេដឹកនាំសាសនាដប់ប្រាំថ្ងៃហើយគាត់ក្លាយទៅប្រធាននៅក្នុងព្រះវិហារ ឬក៏ជាប្រធាននៅវិហារនៅភូមិរបស់គាត់? តើអ៊ីចឹងមែនទេ?

**ឆ៖** បន្ទាប់ពីគាត់ប្រគល់ជីវិតជូនព្រះ ហើយគាត់បានចូលរៀនពីព្រះបន្ទូលរបស់ព្រះ បន្ទាប់មកបន្ទាប់ពីពីរសប្តាហ៍នោះ ហើយគាត់ត្រឡប់ទៅភូមិរបស់គាត់វិញ ហើយគាត់បានបង្កើតជាព្រះវិហារតូចមួយ ដែលមានដប់បួនគ្រួសារដែលជាអ្នកដើរតាម ។

**ស៖** នៅពេលដែលលោកនិយាយថា គាត់បានបង្កើតព្រះវិហារមួយនោះ តើគាត់ប្រគល់តួនាទីអ្វីពីព្រះវិហាររបស់លោកឲ្យគាត់គ្រប់គ្រងដែរឬទេ? ឬក៏គាត់មានបេសកកម្មសាសនារបស់គាត់ ដើម្បីប្តូរសាសនាកុមារកម្ពុជាឲ្យជឿគ្រិស្តសាសនា ឬយ៉ាងម៉េច? តើបេសកកម្មគាត់កាលនោះយ៉ាងដូចម្តេច?

**ឆ៖** លោកចៅក្រម! បន្ទាប់ពីគាត់បានទទួលការរៀនសូត្រ គាត់រៀនព្រះបន្ទូលព្រះហើយ គាត់ផ្សព្វផ្សាយ ហើយខ្ញុំឃើញចេតនាពីផ្លូវចិត្តរបស់គាត់ គាត់ចង់ត្រឡប់ទៅភូមិរបស់គាត់វិញ ហើយចង់ចែករំលែកដំណឹងល្អពីព្រះទៅមិត្តភក្តិរបស់គាត់ ហើយនិងក្រុមគ្រួសារមួយចំនួន ។ ខ្ញុំពិនិត្យឃើញកាលនោះ គឺជាពេលការប្តេជ្ញាចិត្តមួយរបស់គាត់ក្នុងឋានៈជាអ្នកជឿ ដែលថាចង់ចែករំលែកជំនឿព្រះយេស៊ូហ្នឹងទៅដល់អ្នកដែលមិនជឿ ។

[០៩:៣៨:០៣]

**ស៖** ដូច្នេះ បេសកកម្មរបស់គាត់អំពីផ្សព្វផ្សាយពីជំនឿថ្មីរបស់ព្រះយេស៊ូទៅអ្នកជិតខាង អ្នកភូមិដែលនៅជាមួយគាត់ ហើយបេសកកម្មរបស់គាត់បានធ្វើល្អ ឬក៏ឆ្ងាយជាងហ្នឹងដែរឬទេ? តើគាត់បានបង្រៀនពួកគេ តើគាត់បានធ្វើពិធីជ្រមុជទឹក? តើគាត់បានរៀបចំឲ្យមានពិធីថ្វាយបង្គំដូចម្តេច?

**ឆ៖** លោកចៅក្រម! គាត់មានឱកាសដឹកនាំអំពីការថ្វាយបង្គំព្រះ គាត់មានឱកាសបង្រៀនអំពីព្រះបន្ទូលព្រះ ហើយគាត់មានឱកាសដើម្បីតាមដានអ្នកទាំងនោះ ។ គាត់មានឱកាសដើម្បីថ្វាយបង្គំ

ហើយនិងជាមួយនឹងអ្នកជំនឿផ្សេងៗទៀត ក្នុងខណៈពេលដែលគាត់ជាអ្នកដឹកនាំព្រះវិហារមួយនៅក្នុងភូមិរបស់គាត់នោះ ។

**ស៖** តើលោកមានការភ័យខ្លាចបន្តិចបន្តួចដែរឬទេដែលថា ជំនឿអ្នកដែលទទួលព្រះថ្មីហ្នឹងអាចនឹងមានចំណុចចន្លោះប្រហោងអីមួយទេ ក្នុងការផ្សាយព្រះបន្ទូលព្រះនោះ?

**ឆ៖** ទេ, ខ្ញុំមិនមានការភ័យខ្លាចទេ ដោយសារតែគាត់ជាអ្នកបង្រៀនព្រះបន្ទូលព្រះនោះហើយ។ មនុស្សនោះគឺថាអាចទទួលបាននូវការពិសោធន៍នូវព្រះបន្ទូល ។ នេះជាចំណុចដែលខ្ញុំអាចជម្រាបលោកចៅក្រមបាន ។

**ស៖** តើអ្នកណាជាអ្នកធ្វើពិធីជ្រមុជកូនៗរបស់ជនជាប់ចោទ?

**ឆ៖** លោកចៅក្រម! ខ្ញុំមិនដឹងច្បាស់ទេ ប្រហែលជាគាត់ខ្លួនឯង ពីព្រោះគាត់មានសិទ្ធិ ដើម្បីបង្រៀន ដើម្បី-- ហើយនិងធ្វើពិធីជ្រមុជទឹកអ្នកដែលកាន់ជំនឿថ្មីនោះ ។

**ស៖** តើលោកមានឱកាសដើម្បីនិយាយអំពីក្រុមគ្រួសាររបស់គាត់ដែរទេ ជាពិសេសប្រពន្ធរបស់គាត់ជាមួយគាត់? តើគាត់បានជម្រាបលោកដូចម្តេចអំពីប្រពន្ធគាត់កាលនោះ?

**ឆ៖** លោកចៅក្រមជាទីគោរព! នៅក្នុងចុងឆ្នាំ១៩៩៥ ឬក៏ដើមខែមករា បន្ទាប់ពីគាត់បានប្រគល់ជីវិតឲ្យព្រះនោះ ហើយបន្ទាប់ពីទទួលការរៀនសូត្រមួយ ខ្ញុំបានឮពាក្យមួយចំនួន មិនមែនជាពាក្យចេញពីមាត់គាត់ទេ ប៉ុន្តែពីមិត្តភក្តិរបស់គាត់ថា អំពីគ្រួសាររបស់គាត់ ជាពិសេសអំពីប្រពន្ធរបស់គាត់ ដែលព្រះដែលទទួលមរណភាពដោយអំពើអ្វីមួយពីអ្នកផ្សេង ដែលជាអ្នកសម្លាប់ ។

**ស៖** ដូច្នេះ អ្វីដែលលោកបាននិយាយនោះ គឺថា គាត់មិនដែលនិយាយអំពីរឿងរ៉ាវគ្រួសាររបស់គាត់ពីគ្រួសាររបស់គាត់ទេ ។ គាត់មិនបានប្រាប់លោកថា ប្រពន្ធរបស់គាត់ត្រូវបានស្លាប់ ហើយគាត់មិនដែលប្រាប់ពីលក្ខខណ្ឌដែលប្រពន្ធរបស់គាត់ត្រូវបានស្លាប់នោះទេ? តើមែនទេ?

[០៩:៤១:៤៣]

**ឆ៖** លោកចៅក្រម! ខ្ញុំនៅចាំថា នៅក្នុងវគ្គបណ្តុះបណ្តាលមេដឹកនាំសាសនានោះ នៅក្នុងចុងឆ្នាំ១៩៩៥ ហើយនិងដើមឆ្នាំ១៩៩៦ យើងបានប្រឹងប្រែងជាខ្លាំងផ្តោតទៅលើការបណ្តុះបណ្តាល និងការបង្រៀនទៅដល់មេដឹកនាំសាសនារបស់យើង ។ ហើយនៅក្នុងពេលនោះ យើងមានគ្រូគង្វាលជាច្រើន ហើយអ្នកដឹកនាំជាច្រើន ដែលចូលរួមក្នុងវគ្គសិក្សានោះ ។ ខ្ញុំពិបាកនឹងផ្តោតអារម្មណ៍ទៅបុគ្គលម្នាក់នោះ ប៉ុន្តែខ្ញុំចាប់អារម្មណ៍ទៅលើអ្នកទាំងអស់ដែលជាមេដឹកនាំសាសានា ជាគ្រូគង្វាលនោះ ដែលនៅ

ក្នុងចំណោមនោះមាន ឌុច ម្នាក់ផងដែរ ។

**ស៖** តើឋានៈរបស់ ឌុច នៅពេលណា? ពេលនោះ តើគាត់មានឋានៈជាមេដឹកនាំនៅព្រះវិហារ តើគាត់ជាគ្រូគង្វាល ឬគាត់ជាអ្វី?

**ឆ៖** លោកចៅក្រមជាទីគោរព! ខ្ញុំហៅគាត់ថា ជាគ្រូគង្វាលសាមញ្ញនៅឡើយ ដោយសារថា គាត់មានឱកាស គាត់បានទទួលវគ្គបណ្តុះបណ្តាលនោះ គាត់បុព្វជិត ដើម្បីគាត់ជាអ្នកបង្កើត មានផែនការបង្កើតព្រះវិហារនៅក្នុងភូមិគាត់ ។

**ស៖** តើលោកអាចប្រាប់យើងបានដែរឬទេ? តើមានមនុស្សប៉ុន្មាននាក់ដែលត្រូវបានទទួលពិធីជ្រមុជទឹកក្នុងព្រះវិហាររបស់លោកនៅកម្ពុជានេះ?

**ឆ៖** លោកចៅក្រមជាទីគោរព! ខ្ញុំមិនចាំចំនួនច្បាស់ទេ មិនបានរាប់ ហើយខ្ញុំបាន ខ្ញុំអាចនិយាយច្រើនពាន់នូវអ្នកទទួលជំនឿថ្មី នៅក្នុងរយៈពេលដប់ប្រាំបី ឬក៏ដប់ប្រាំបួនឆ្នាំ ដែលខ្ញុំមកធ្វើការនៅកម្ពុជា ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកគ្រូគង្វាល ។ ខ្ញុំមិនមានសំណួរអ្វីទៀតទេលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីត្រូវសួរដល់សាក្សីរូបនេះទេ? បើមិនមានទេ អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការសួរសំណួរដល់សាក្សីរូបនេះ ហើយអង្គជំនុំជម្រះសូមជម្រាបថា សហព្រះរាជអាជ្ញាមានពេលវេលាដប់ប្រាំនាទីក្នុងការសួរសំណួរចំពោះសាក្សីរូបនេះ ។ សូមអញ្ជើញ ។

[០៩:៤៤:៤៥]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោកស្រី ជា លាង៖**

សូមអរគុណលោកប្រធាន ហើយសូមគោរពអង្គសវនាការទាំងមូល ក៏ដូចជា ស្វាគមន៍លោកឡាប៉ែល ដែលបានចូលរួមក្នុងការចូលរួមធ្វើសាក្សីនៅពេលនេះ ។

**ស៖** អ្វីដែលលោកបានរៀបរាប់ គឺថាមានប្រយោជន៍ចំពោះយើងអំពីសាសនាមួយទៅសាសនាមួយទៀត ហើយលោកចៅក្រម ក៏ជាដូចលោកប្រធានបានលើកនូវសំណួរជាច្រើនដែលបញ្ជាក់ឲ្យដឹង

នូវសាសនានានាដែលជាជាប់ចោទមានការផ្លាស់ប្តូរពីសាសនាព្រះពុទ្ធ ទៅមានការជឿទៅលើសាសនាគ្រិស្តវិញ ។ ជាមួយគ្នាហ្នឹងដែរ ព្រះរាជអាជ្ញាគ្រាន់តែមានសំណួរពីរបីសំណួរតែប៉ុណ្ណោះ ដើម្បីបញ្ជាក់បន្ថែមទៅលើអ្វីដែលលោក ឡាប៉ែល បានរៀបរាប់អម្បាញ់មិញនេះ ។

លោកបានរៀបរាប់ហើយថា លោកមិនធ្លាប់បានដឹងអ្វីពីអតីតកាលដែលជនជាប់ចោទបានធ្វើពីមុន ដែលគាត់ចូលជាសាសនាគ្រិស្តនោះទេ ។ អ៊ីចឹង ខ្ញុំចង់សួរបញ្ជាក់នៅពេលដែលជនជាប់ចោទផ្លាស់ប្តូរពីសាសនាព្រះពុទ្ធមកសាសនាគ្រិស្តនេះ តើជនជាប់ចោទធ្លាប់បានរៀបរាប់ប្រាប់លោកថា តើគាត់ធ្លាប់ជាអតីតមន្ទីរម-១៣ ហើយក្រោយមកទៅជាប្រធានមន្ទីរស-២១ ដែរឬទេ?

**ឆ៖** ខ្ញុំនៅចាំថា គាត់មិនដែលបានប្រាប់ខ្ញុំថា តើគាត់ជាអ្នកណាទេក្នុងអតីតកាលនោះ? ខ្ញុំនៅចាំថា ខ្ញុំបានជួបគាត់ ជាទៀងទាត់ថា គាត់ជាមនុស្សធម្មតា ដែលបានមកចូលរួមអំពី-- ធ្វើការថ្វាយបង្គំព្រះ ហើយនិងការរៀនសូត្រអ្នកដឹកនាំសាសនានោះ ។ ហើយខ្ញុំមិនបានដឹងអំពីជំនឿរបស់គាត់ពីអតីតកាលដែរ ប៉ុន្តែនៅពេលដែលបានជួបគាត់ គាត់បានចូលមកជួបខ្ញុំ ហើយគាត់បញ្ជាក់ថា គាត់ចង់ទទួលព្រះយេស៊ូគ្រិស្តជាព្រះសង្គ្រោះរបស់គាត់ ។ នេះហើយគឺជាអ្វីដែលខ្ញុំនៅចាំ ពាក្យដែលគាត់ប្រាប់ខ្ញុំ ។

**ស៖** ឆ្លងទៅសំណួរទីពីរ ។ ក្នុងនាមលោកជាគ្រូគង្វាល តើការវិភាគជារបៀបសាសនារបស់លោកហ្នឹង តើលោកគិតថា ជនជាប់ចោទប្រកាន់យកនូវរូបលោកជាគ្រូគង្វាលដោយសុទ្ធចិត្តឬទេ? ដោយយើងបានឃើញនូវការសម្ភាសន៍មួយដែលបញ្ជាក់ថា ជនជាប់ចោទហ្នឹងមិនមានការជឿទេ ប៉ុន្តែដោយសារមានការជំរុញរបស់មិត្តភក្តិ ដែលធ្វើឲ្យគាត់ទៅជា ប្តូរសាសនាពីសាសនាព្រះពុទ្ធទៅសាសនាគ្រិស្ត?

**ឆ៖** លោកស្រីសហព្រះរាជអាជ្ញា! ខ្ញុំនៅចាំថា ខ្ញុំមិនបានបញ្ចុះបញ្ចូលគាត់ទេ ឲ្យប្តូរសាសនា ឬក៏ជំរុញគាត់ឲ្យជឿទេ ប៉ុន្តែដោយសារគាត់បានឮព្រះបន្ទូលព្រះ ហើយគាត់ក៏បានចូលមក ហើយគាត់បានទទួលយកព្រះ ។ ហើយខ្ញុំមិននឹកឃើញថា គាត់មានគោលបំណងចង់ធ្វើគ្រូគង្វាលទេ។ ប៉ុន្តែ ចិត្តរបស់គាត់ចង់ផ្សាយព្រះបន្ទូលរបស់ព្រះទៅដល់មិត្តភក្តិហើយនិងទៅដល់សមាជិកក្រុមគ្រួសាររបស់គាត់ ។

[០៩:៤៨:៥១]

**លោកស្រី ជា លាង៖**

សូមអស់សំណួរហើយ ហើយខ្ញុំប្រហែលជាសហការីរបស់ខ្ញុំខាងអន្តរជាតិមានសំណួរចង់សួរ

លោក ។ សូមអរគុណលោកគ្រូគង្វាល ។

**សួរដោយលោក រាំងសង់ ដឺវ៉ាយដ៍ ដេស្មាឯល៖**

**ស៖** សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម សូមជម្រាបសួរលោកសាក្សី ។ លោកនិយាយថា អ្នកសារព័ត៌មាននៅបាងកក បានជួបសួរលោកអំពីខែមករា ឆ្នាំ១៩៩៦ តើអ្នកកាសែតនោះជាអ្នកណា?

**ឆ៖** មិនមែនឆ្នាំ១៩៩៦ ទេ គឺខែមេសា ឆ្នាំ១៩៩៩ ។ ខ្ញុំមិនអាចចាំឈ្មោះរបស់គាត់នោះទេ ប៉ុន្តែគាត់បានប្រាប់ខ្ញុំថា គាត់ធ្វើការឲ្យសារព័ត៌មាន អាប៉េ (AP) ហើយគាត់បានរកខ្ញុំប្រហែលជាបួនថ្ងៃ បីថ្ងៃបួនថ្ងៃហើយ ។ ខ្ញុំចាំបានតែប៉ុណ្ណឹង ខ្ញុំមិនចាំឈ្មោះអ្នកសារព័ត៌មាននោះទេ ។

[០៩:៥០:០៥]

**ស៖** លោកសាក្សី តើលោកស្គាល់សៀវភៅមួយ ដែលសរសេរឡើងដោយលោក នីក ដងឡុប ដែលមានចំណងជើងថា “ពេជ្ឈឃាដបាត់ខ្លួន” ដែរឬទេ?

**ឆ៖** បាទ, ខ្ញុំបានដឹងពីសៀវភៅហ្នឹង ។ ខ្ញុំជួប នីក ដងឡុប នៅពេលគាត់បានទៅព្រះវិហាររបស់ យើងនៅបាត់ដំបង ហើយបានសួរព័ត៌មានមួយចំនួនពីយើងអំពីការប្តូរសាសនារបស់ ឌុច នោះ ។

**ស៖** ប្រសិនបើលោកបានអានសៀវភៅនោះ លោកគ្រូគង្វាល លោកសាក្សី តើលោកអាចប្រាប់យើងបានដែរឬទេ តើលោកបាននិយាយអ្វីខ្លះ តើអ្វីដែលនិយាយទៅ នីក ដងឡុប គឺបានចែងនៅក្នុង-- សរសេរនៅក្នុងសៀវភៅហ្នឹងឬទេ?

**ឆ៖** លោកសហព្រះរាជអាជ្ញា សូមលោកបញ្ជាក់ពាក្យហ្នឹងឲ្យបានច្បាស់ ដែល នីក ដងឡុប និយាយពីរឿងហ្នឹងក្នុងសៀវភៅរបស់គាត់បានទេ?

**ស៖** គាត់និយាយអំពីរឿងហ្នឹងក្នុងចំនួនពីរបីបួនទំព័រ ហើយខ្ញុំមិនអាចយោងទៅរកចំណុចហ្នឹងទេ ប៉ុន្តែបានដកស្រង់ខ្លឹមសារក្នុងសៀវភៅរបស់គាត់ប្រាប់លោក ។ តើលោកនៅចាំទេ សេចក្តីដកស្រង់នោះត្រូវឬទេ? ខ្ញុំចាប់ផ្តើមពីអ្វីដែលលោកនិយាយពីខាងដើមនោះគឺ ហើយក៏នៅក្នុងសៀវភៅរបស់ នីក ដងឡុប ដែរ ដែលមានចំណងជើងថា “ពេជ្ឈឃាដបាត់ខ្លួន” នោះ ។ ថាក្នុងការជួបដំបូងជាមួយ ឌុច ឌុច នៅក្នុងបន្ទប់ចុងក្រោយជួរក្រោយនៃបន្ទប់ ហើយក្រោយមកគាត់មកអង្គុយនៅខាងមុខ ហើយនៅក្នុងសៀវភៅ នីក ដងឡុប នោះ គឺថា ហាង់ ពិន នៅពេលនោះ គឺត្រូវបានប្រាប់លោកថា គាត់មានអំពើបាបធ្ងន់នៅក្នុងកម្រិតមួយដែលគាត់មិនគិតថា បងប្អូនប្រុសរបស់គាត់មិនអាចលើកលែងអំពើបាបនោះ

ឲ្យគាត់ទេ ។ តើគាត់ប្រាប់អ៊ីចឹងទេ?

**ឆ៖** (គ្មានការបកប្រែ) ។

**ស៖** តើពាក្យថា ប្រើដោយ ហាង់ ពិន នៅពេលនោះ មិនមែនជាពាក្យ ដែលជំរុញឲ្យលោកសួរសំណួរគាត់ច្រើនថែមទៀតទេ មុនពេលនឹងទទួលហានិភ័យក្នុងការស្វាគមន៍គាត់ឲ្យចូលក្នុងសហគមន៍របស់លោក បណ្តុះបណ្តាលគាត់ ហើយផ្តល់បេសកកម្មឲ្យគាត់ ហើយនិងប្តូរសាសនាឲ្យគាត់ ដើម្បីឲ្យធ្វើពិធីជ្រមុជទឹកឲ្យអ្នកដទៃនៅក្នុងភូមិរបស់គាត់នោះ?

**ឆ៖** លោកសហព្រះរាជអាជ្ញា! បន្ទាប់ពីបានចែកដំណឹងល្អពីព្រះទៅក្នុងមនុស្សរបស់ខ្ញុំ ពាក្យដែលបាន-- ពាក្យដំណឹងល្អហ្នឹង គឺចូលនៅក្នុងចិត្តរបស់គេ ហើយគេក៏បានទទួលព្រះយេស៊ូជាព្រះអង្គសង្គ្រោះ ហើយមិនមែនជាខ្ញុំជាអ្នកមានសិទ្ធិ តើគាត់ហ្នឹងជាអ្នកណា? តើប្រវត្តិដើមគឺអ្វីនោះទេ ។ ការទទួលខុសត្រូវរបស់ ខ្ញុំគឺថាចែករំលែកជំនឿព្រះយេស៊ូគ្រិស្តរបស់គាត់ ហើយដឹកនាំគេឲ្យគេជួបជាមួយព្រះ ហើយបង្រៀនពួកគេធ្វើឲ្យគេយល់អំពីព្រះយេស៊ូរបស់យើងដែលជាព្រះដែលគេជឿជាក់នោះ ។

**ស៖** ខ្ញុំត្រឡប់មករកសំណួរពីរ ដែលលោកមិនទាន់បានឆ្លើយពីមុននៅពេលដែលចៅក្រម ឡាវែន៍ សួរលោក ។ ទីមួយ ថាតើពិធីជ្រមុជទឹកអាចនឹងលើកលែងអំពើបាបរបស់ជននោះទាំងអស់ តើជាទ្រឹស្តីនៅក្នុងសាសនារបស់លោកហ្នឹងមែនឬទេ?

**ឆ៖** លោកសហព្រះរាជអាជ្ញា! ខ្ញុំត្រូវតែបំភ្លឺចំណុចនេះអំពីអត្ថន័យនៃពិធីជ្រមុជទឹក ។ ប្រសិនបើ បុគ្គលម្នាក់មិនបានទទួលយកព្រះយេស៊ូគ្រិស្តជាព្រះ ជាព្រះសង្គ្រោះរបស់គេទេ បើគេមិនយល់ន័យរបស់ពិធីជ្រមុជទឹកទេ ពិធីជ្រមុជទឹកមិនមានន័យសម្រាប់ជននោះដែលទទួលពិធីជ្រមុជទឹកនោះទេ ។ ប្រសិនបើជននោះបានឮព្រះបន្ទូល ទទួលយកព្រះយេស៊ូគ្រិស្តជាព្រះអង្គសង្គ្រោះ ពេលនោះព្រះយល់អ្វីជាអត្ថន័យរបស់ពិធីជ្រមុជទឹកនោះមានន័យថា ពិធីជ្រមុជទឹកនោះ គឺបានលាងបាបរបស់គេហើយ ។

**ស៖** ពីមុននោះចៅក្រម ឡាវែន៍ បានសួរលោក តើឈ្មោះអ្វីដែលកត់ត្រាឈ្មោះជនជាប់ចោទនៅក្នុងព្រះវិហារហ្នឹង? ហើយលោកនិយាយថា ឈ្មោះគាត់នៅពេលនោះគឺថា ហាង់ ពិន ។ តើឈ្មោះចុះបញ្ជីហ្នឹងមានសុពលភាពដល់ពេលថ្ងៃនេះទេ? តើមានឈ្មោះថ្មីដែរឬទេ? បើសិនជាឈ្មោះពិតមិនមែននៅក្នុងកំណត់ត្រាបញ្ជីជ្រមុជទឹកនោះទេនោះ?

**ឆ៖** លោកសហព្រះរាជអាជ្ញា នោះគឺជាឈ្មោះ ដែលខ្ញុំទទួលពីគាត់ដោយផ្ទាល់ខ្លួន ហើយគាត់បាន ប្រាប់ខ្ញុំថា ឈ្មោះគាត់គឺ ហាង់ ពិន ។ មនុស្សភាគច្រើន ដែលខ្ញុំធ្វើពិធីជ្រមុជទឹកឲ្យនោះជាពិសេស

ខ្ញុំ និយាយថា ក្នុងចំណោមគ្រិស្តសាសនិក គឺថាគេប្រើឈ្មោះបី ពេលខ្លះ ។ ជួនកាលគេប្រើឈ្មោះពិត ពេលខ្លះ គេប្រើឈ្មោះហៅក្រៅ ពេលគេគ្រាន់តែប្រើឈ្មោះ ដែលគេប្រើក្នុងសាសនា អ៊ីចឹងវាអាចបី ។

**ស៖** ខ្ញុំសូមអនុញ្ញាតសួរលោកគ្រូគង្វាលអំពីសំណួរពីរបីទៀតគឺ ទាក់ទងទៅនឹងកត្តាជំរុញពីជនជាប់ចោទឲ្យក្លាយទៅជាគ្រិស្តស្ទៀន ។ តើលោកអាចបានប្រាប់យើងបានទេ គឺថាមានមនុស្សមួយចំនួនច្រើនដែលចូលរួមក្នុងការបណ្ដុះបណ្ដាល? ហើយប្រហែលជាលោកមិនមានការដឹងអំពីអត្តចរិតច្រើនអំពីជនជាប់ចោទទេ ។ តើលោកបានសួរខ្លួនឯងដែរឬទេ? ប្រហែលជាមានឱកាសខាងវិភាគខាងចិត្តសាស្ត្រ ហើយនិងផ្អែកទៅលើការអនុវត្តជាក់ស្ដែង ឬក៏ប្រើមើលកត្តាមួយចំនួនដែលអ្នកជំនាញចិត្តសាស្ត្រប្រើនៅក្នុងពេលនោះ គឺថា ឌុច ពិតជាបានប្ដូរសាសនា ។ ប៉ុន្តែពេលក្រោយមក នៅពេល ដែលលោកបានដឹងថា ហង់ ពិន គឺជា ឌុច នោះ តើលោកសួរខ្លួនឯងពីសំណួរហ្នឹងដែរឬទេ? តើលោកមិនមានឱកាស ឬក៏មិនមានការពិត ដែលលោកគិតថា ឌុច ត្រូវបានប្ដូរសាសនា ដើម្បីទទួលផលប្រយោជន៍ដោយមិនមានលក្ខខណ្ឌអំពីចំណុចមួយដែលថា គាត់នឹងទទួលការលើកលែងពីព្រះជាម្ចាស់ ព្រះយេស៊ូគ្រិស្ត ។ ហើយប៉ុន្តែ នៅក្នុងពុទ្ធសាសនាមិនអាចនឹងទទួលបាននូវការកើតជាថ្មីទេ បើមានអំពើបាបបែបនេះ ធ្ងន់បែបនេះនោះ ។

[០៩:៥៧:៣៤]

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំមិនជឿថា ខ្ញុំអានរបាយការណ៍របស់អ្នកជំនាញនោះនៅក្នុងឯកសារនោះ ដែលថា ឌុច បានប្ដូរសាសនាដើម្បីជាការឆក់ឱកាសផ្អែកលើហ្នឹង ឆ្ងៀតចេញពីការពិត ។ ដូច្នេះ លោកសហព្រះរាជអាជ្ញា សូមសួរសំណួរហ្នឹងឲ្យបានត្រឹមត្រូវដើម្បីកុំឲ្យសាក្សីមានការភាន់ច្រឡំ។ ដូច្នេះសូមលោកព្យាយាមនិយាយឡើងវិញពីអ្វីដែលអ្នកជំនាញ ពិតជាបាននិយាយនោះ ។

**លោក វ៉ាំងសង់ ដឺវ៉ាយដ៍ ដេស្បាឯល៖**

ខ្ញុំ--ទំព័រ៤៣ នៃរបាយការណ៍នោះ ERN00177548 ជារបាយការណ៍អ្នកជំនាញដែលខ្លឹមសារខាងក្រោមនេះបានបញ្ជាក់នៅទីនោះ ។ នៅក្នុងជំពូកមួយដែលនិយាយថា ការសិក្សាអំពីកម្រិតនៃបញ្ញាក្នុងការសម្ដែងហេតុផល--

**លោក ហ្វ្រង់ស្វ័រ រូ៖**

តើទំព័រណា?

**លោក វ៉ាំងសង់ ដឺវាយដ៍ ដឺស្មាឯល៖**

ទំព័រ៤៣ នៃរបាយការណ៍ ។ ចំណងជើងទីមួយនោះ គឺការបញ្ហាក្នុងការកំណត់បង្កើត គឺថាក្នុងរយៈពេលកុម្មុយនីស្ត ក្នុងសម័យក្រោយមក ក្នុងសម័យដែលគាត់ជឿគ្រិស្តសាសនា ។ ចំណុចមួយនៅក្នុងបន្ទាត់ទីបី នៃទំព័រ៤៣ នៃអត្ថបទភាសាបារាំងនិយាយថា ដំណាក់កាល ដំណើរការគិតហ្នឹង គឺថាមានកម្លាំងខ្លាំង គឺថាផ្អែកទៅលើការណៈនិយម គឺគាត់បានប្តូរទៅជាសាសនាគ្រិស្តនៅក្នុងឆ្នាំ១៩៩៦ មិនមែនដោយសារការជឿលើសាសនានោះទេ គឺការជំនឿទៅលើការកាត់បន្ថយទោស ហើយនិងការណៈនិយមទៅតាមការពិត ។ ថាតើឲ្យសាក្សីគាត់ឆ្លើយបានទេ?

[១០:00:00]

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធានសូម! សុំឲ្យលោកដកពាក្យថា គំនិតឆក់ឱកាសនិយមនេះចេញ ហើយវាមានពាក្យហ្នឹង ប៉ុន្តែយើងមិនត្រូវប្រើពាក្យថា “ឆក់ឱកាសនិយម” ទេ ពីព្រោះពាក្យហ្នឹងមិនបានប្រើនៅក្នុងរបាយការណ៍នេះទេ ។

**លោក វ៉ាំងសង់ ដឺវាយដ៍ ដេស្មាឯល៖**

ខ្ញុំបានសួរសំណួរ--

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញារៀបចំនូវពាក្យពេចន៍នៅក្នុងការតាំងសំណួរហ្នឹងឲ្យបានត្រឹមត្រូវ សមស្របហ្នឹងរបាយការណ៍ តាមការមតិជំទាស់លើបញ្ហានេះ សូមប្រើពាក្យឲ្យបានត្រឹមត្រូវជាក់លាក់ ដែលមានចែងនៅក្នុង-- មានសរសេរនៅក្នុងរបាយការណ៍របស់អ្នកជំនាញ។ ប្រសិនបើលោកផ្អែកលើរបាយ-ការណ៍របស់អ្នកជំនាញក្នុងការតាំងសំណួរដល់សាក្សីរូបនេះ ។

**លោក វ៉ាំងសង់ ដឺវាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី, ខ្ញុំសូមនិយាយសំណួរសាជាថ្មី ។ នៅពេលដែលអ្នកជំនាញខាងចិត្តសាស្ត្របានមកផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ ឌុច គាត់បានផ្លាស់ប្តូរសាសនារបស់គាត់ចូលទៅជាអ្នកគោរពសាសនាគ្រិស្ត ។ ថាតើលោកយល់យ៉ាងម៉េចទៅលើពិធីបញ្ចូលនិងជ្រមុជទឹកនេះ? នៅពេល

ក្រោយមកដែលលោកបានដឹងថា គឺ ឌុច នេះហើយដែលមនុស្សដែលគាត់ធ្លាប់មានអតីតរបស់គាត់នោះ។ ដូច្នេះ ខ្ញុំចង់សួរលោក ថាតើវាមានភាពងាយស្រួលសម្រាប់ជនជាប់ចោទក្នុងការផ្លាស់ប្តូរសាសនា ទៅសាសនារបស់លោក ដើម្បីឲ្យគាត់បានទទួលនូវការអត់ឱនទោសពីសាសនានិងព្រះរបស់គាត់ដែរឬទេ? ប៉ុន្តែនៅក្នុងសាសនាព្រះពុទ្ធវិញ គឺគាត់ត្រូវតែមានការចាប់ជាតិសាជាថ្មី ឬក៏គាត់ត្រូវតែលាងបាបរបស់គាត់ ដើម្បីជម្រះឲ្យអស់នូវជីវិតរបស់គាត់ ។

**លោក គ្រីស្ទហ្វឺ ឡាប៉ែល៖**

**ឆ៖** នេះគឺជាសំណួរមួយយ៉ាងវែង ។ ប៉ុន្តែ ខ្ញុំអាចធ្វើការសង្ខេបទៅលើសំណួរនេះដោយឆ្លើយតែពីរពាក្យតែប៉ុណ្ណោះ ។ វាមានការពិបាកក្នុងការកំណត់អំពីអានុភាពរបស់ព្រះយ៉េស៊ូគ្រិស្ត។ វាមានការពិបាកក្នុងការកំណត់និយមន័យនៃពាក្យថា បុគ្គលនេះ នៅពេលដែលអនុភាពនៃព្រះ គឺបានចូលទៅក្នុងដួងចិត្តរបស់គាត់ ។ ហើយខ្ញុំអាចឆ្លើយទៅនឹងសំណួររបស់លោកថា នៅពេលដែល ឌុច គាត់បានផ្លាស់ប្តូរសាសនារបស់គាត់ វាចេញពីឆន្ទៈរបស់គាត់ដោយផ្ទាល់ ដែលជំរុញដោយព្រះយ៉េស៊ូគ្រិស្ត ហើយគាត់ស្ម័គ្រចិត្តចូលខ្លួនសារភាពនូវពិរុទ្ធភាពរបស់គាត់ ហើយស្ម័គ្រចិត្តទទួលយកនូវពិធីសាសនាជ្រមុជទឹក ។ គាត់ចូលរួមស្ម័គ្រចិត្តចែករំលែកព្រះបន្ទូលរបស់ព្រះទៅដល់អ្នកដទៃ ។

**ស៖** ខ្ញុំនៅសល់សំណួរចុងក្រោយមួយទៀតចង់សួរទៅកាន់លោកសាក្សី។ នៅពេលដែលខ្ញុំអានសៀវភៅរបស់លោក នីក ដងឡុប ខ្ញុំយល់ឃើញថា លោកបាត់បង់នូវសមាជិកគ្រួសាររបស់លោកនៅមន្ទីរស-២១ ខ្ញុំមិនដឹងថាតើជាសមាជិកគ្រួសារ ឬក៏អ្នកដែលជាទីស្រលាញ់របស់លោកនោះទេ? នៅក្នុងសំណួររបស់លោក នីក ដងឡុប ថា “តើលោកអាចអត់ឱនឲ្យ ឌុច ដែរឬទេ?” ។ នៅពេលនោះលោកបានឆ្លើយថា “ខ្ញុំអាចអត់ឱនឲ្យគាត់បាន” ប្រសិនបើខ្ញុំជួបគាត់នោះ គឺថាខ្ញុំនឹងប្រាប់គាត់ថា “ខ្ញុំស្រឡាញ់គាត់ ហើយខ្ញុំស្អប់នូវអ្វីដែលគាត់បានធ្វើ” ។

ដូច្នេះ តាំងពីលោកជួបគាត់មក ថាតើមានអ្វីកើតឡើងបន្ទាប់ពីលោកជួបគាត់? តើលោកមានអារម្មណ៍យ៉ាងម៉េច ចំពោះអតីតរបស់គាត់ដែលប្រព្រឹត្តនូវអំពើឧក្រិដ្ឋ? ថាតើលោកមានអារម្មណ៍ផ្ទាល់ខ្លួនយ៉ាងម៉េច? តើលោកមិនមានការបារម្ភទៅលើបញ្ហានោះទេ ដែលវាទាក់ទងទៅនឹងបុគ្គលម្នាក់គាត់លាក់កំបាំងនិងអត្តសញ្ញាណរបស់គាត់ ហើយគឺគាត់បានទទួលខុសត្រូវទៅលើការស្លាប់មនុស្សនៅមន្ទីរស-២១ ជាងមួយម៉ឺននាក់ ហើយបុគ្គលដែលលោកបានជួបនេះ គឺមានជាអ្នកដែលមានភាពជិតស្និទ្ធនិងលោកផងដែរ ។

[១០:០៥:០៨]

**ឆះ** លោកសហព្រះរាជអាជ្ញា! ខ្ញុំបានបាត់បង់នូវមិត្តភក្តិជិតស្និទ្ធនៅមន្ទីរស-២១ ។ ខ្ញុំបាត់បង់ឪពុកម្តាយរបស់ខ្ញុំ បងប្អូនប្រុសស្រីរបស់ខ្ញុំ ក្នុងរបបវាលពិឃាតនេះ ។ ជាការពិត ខ្ញុំបានប្រាប់លោក *នីក ដងឡប* នៅពេលដែលលោក *នីក ដងឡប* បានសួរខ្ញុំអំពីការផ្លាស់ប្តូរសាសនារបស់ ឌុច ។ អំពីការអត់ឱនទោស ខ្ញុំបានប្រាប់ និក ។ ខ្ញុំដកស្រង់នូវពាក្យរបស់ខ្ញុំថា ខ្ញុំស្អប់អំពើបាប មិនមែនស្អប់អ្នកប្រព្រឹត្តអំពើបាបនោះទេ ។

នៅពេលដែលខ្ញុំជួប ឌុច នៅក្នុងខែមិថុនា ឆ្នាំ២០០៨ ខ្ញុំបានប្រាប់គាត់ថាខ្ញុំស្រឡាញ់ពេញចិត្តគាត់ ហើយខ្ញុំអនុគ្រោះទៅដល់គាត់នូវអំពើដែលគាត់បានប្រព្រឹត្តពីមុន ចំពោះឪពុកម្តាយ បងប្អូនប្រុសស្រី និងមិត្តភក្តិជិតស្និទ្ធរបស់ខ្ញុំនៅស-២១ ។ ខ្ញុំនិយាយក្នុងនាមខ្លួនខ្ញុំជាសាសនាគ្រិស្តហើយជាអ្នកជឿទៅលើព្រះយេស៊ូគ្រិស្ត ថាខ្ញុំអត់ឱនឲ្យគាត់ ដោយខ្ញុំប្រាប់គាត់ដោយផ្ទាល់មុខនៅពេលនោះ ។ ខ្ញុំបានប្រាប់គាត់ថាខ្ញុំអត់ឱនគាត់នូវអ្វីដែលគាត់បានប្រព្រឹត្តចំពោះជីវិតមនុស្សស្លូតត្រង់ជាងមួយម៉ឺនពីរនាក់នៅមន្ទីរស-២១ ។ នៅពេលនោះ ខ្ញុំមានភាពស្ងប់ស្ងាត់នៅក្នុងចិត្ត ខ្ញុំមានភាពរីករាយសប្បាយចិត្ត បានន័យថា វាជាការព្យាបាលផ្លូវចិត្តខាងក្នុងរបស់ខ្ញុំ នៅពេលដែលខ្ញុំបានជួបប្រទះនូវស្ថានភាពចំពោះគ្រួសារខ្ញុំនោះ ។

នៅពេលដែលយើងក្លាយទៅជាអ្នកដែលមានជំនឿយ៉ាងខ្លាំង ហើយនៅពេលដែលយើងយល់អំពីភាពស្រឡាញ់របស់ព្រះ យើងនឹងយល់អំពីការអត់ឱន ឬអនុគ្រោះ ។

**សះ** ប្រសិនបើខ្ញុំអាចធ្វើសង្ខេបទៅលើចម្លើយនេះបាន នៅពេលដែលលោកនិយាយអំពីការអនុគ្រោះក្នុងនាមជាព្រះនោះ ដោយសារតែលោកមានជំនឿទៅលើព្រះ ហើយលោកបានប្រគល់ជីវិតរបស់លោកទៅព្រះហើយ ហើយលោកត្រូវធ្វើការងារនេះបន្ត ។ ប្រសិនបើលោកមិនមានជំនឿទៅលើព្រះ ហើយប្រសិនបើលោកមិនមែនជាអ្នកជឿព្រះនោះទេ ថាតើលោកនឹងអនុគ្រោះទៅលើគាត់ដែរឬទេ? ហើយ តើលោកយល់អំពីអារម្មណ៍និងទឹកចិត្តរបស់ជនរងគ្រោះទាំងឡាយ ដែលគាត់មិនទាន់ត្រៀមខ្លួនទៅលើការអនុគ្រោះដែរឬទេ?

**ឆះ** ខ្ញុំយល់ថា ក្នុងនាមជាបុគ្គលមួយរូបដែលមិនមានជំនឿទៅលើព្រះយេស៊ូគ្រិស្តនោះ ឬក៏បុគ្គលដែលមិនមានការជឿជាក់មោះមុតស្មោះត្រង់ទៅលើព្រះ ពួកគាត់និងមិនយល់អំពីព្រះបន្ទូលរបស់ព្រះនោះទេ ។ ហើយវាពិបាកណាស់ក្នុងការស្វែងយល់ហើយនិងមិនអាចអត់ឱនបាននោះទេ ។ ដូច្នេះ

ខ្ញុំនិយាយនេះក្នុងនាមជាអ្នកកាន់សាសនា ។ ខ្ញុំមិនអាចនិយាយក្នុងនាមជាអ្នកមិនកាន់សាសនានោះទេ ។ ប៉ុន្តែ នៅទីនេះខ្ញុំជាអ្នកកាន់សាសនា ហើយខ្ញុំត្រូវយល់ ខ្ញុំយល់អំពីព្រះបន្ទូលរបស់ព្រះ។ ដូច្នេះនៅពេលដែលខ្ញុំយល់អំពីព្រះបន្ទូលរបស់ព្រះ ខ្ញុំនឹងយល់អំពីការអត់ឱននិងការអនុគ្រោះ ។

[១០:០៨:៥៨]

**លោក វ៉ាំងសង់ ដឺវ៉ាយដ៍ ដេស្សាងលេ៖**

សូមអរគុណលោកប្រធាន ខ្ញុំពុំមានសំណួរបន្ថែមនោះទៀតទេ ហើយខ្ញុំសូមថ្លែងអំណរគុណចំពោះសាក្សីផងដែរ ។

**ប្រធានអង្គជំនុំ៖**

ជាបន្ត អង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវីការពារក្តី ដើម្បីមានឱកាសក្នុងការតាំងសំណួរចំពោះសាក្សីរូបនេះ ប្រសិនបើមាន ។ សូមអញ្ជើញ ហើយតំណាងមេធាវីការពារក្តីមានពេលវេលាដប់ប្រាំនាទីក្នុងការតាំងសំណួរនេះ ។

**ការតាំងសំណួរដោយមេធាវីការពារក្តី**

**សួរដោយលោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសង្ឃឹមថា ប្រសិនបើខ្ញុំត្រូវការពេលវេលាបន្ថែមទៀត គឺខ្ញុំសូមអនុញ្ញាតសុំពេលវេលាបន្ថែមទៅតាមភាពចាំបាច់ដូចដែលសហព្រះរាជអាជ្ញាផងដែរ ។

**ស៖** លោកសាក្សី, សូមថ្លែងអំណរគុណលោក ដែលបានមកចូលរួមជាយើងខ្ញុំនៅទីនេះ ។ លោកបាននិយាយជម្រាបប្រាប់យើងខ្ញុំអំពីបុគ្គលក្នុងនាមជាអ្នកជឿទៅលើព្រះ ។ តើលោកអាចជម្រាបខ្ញុំឱ្យបានជាក់លាក់ជាងនេះបន្តិចដែរឬទេ? ថាតើលោកស្ថិតនៅក្នុងប្រជុំគ្រិស្តបរិស័ទមួយណាដែរ? ឬក្នុងវិហារមួយណាដែរ?

**ឆ៖** លោកមេធាវីការពារក្តី! ខ្ញុំគឺជាគ្រូគង្វាលនៅព្រះវិហារ ហ្គោលដិនវ៉េស៍ គ្រិស្តស្ទៀនឆឺចនៅកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក ។ ខ្ញុំគឺជាជនជាតិកម្ពុជាអាមេរិក ហើយខ្ញុំរស់នៅប្រទេសកម្ពុជាម្ភៃឆ្នាំហើយ ។ ហើយខ្ញុំក៏ជាមេដឹកនាំនៅក្នុងសមាគមព្រះវិហារគ្រិស្តសាសនា រយៈពេលដប់ប្រាំបីឆ្នាំរួចមកហើយ ។

**ស៖** វិហារនេះ គឺជាវិហារដែលទទួលបានការតែងតាំងពីសាសនាគ្រិស្តប្រូតេស្តង់ ។

**ឆ៖** ជាការត្រឹមត្រូវ ។

**ស៖** លោកត្រូវបានភាគីសួរសំណួរទាំងឡាយច្រើន ទៅលើការផ្លាស់ប្តូរសាសនារបស់ ឌុច ។ ហើយប្រហែលស្ថិតនៅលើល្បឿន ឬក៏ទៅលើការផ្លាស់ប្តូរសាសនានេះ គឺខ្ញុំយល់ថា លោកយល់ឃើញថា នៅពេលដែល ឌុច មកជួបលោកនោះ គឺនៅពេលនោះ ឌុច គឺជាបុរសមួយរូបដែលស្ទើស៊ុំនិងស្វែងរកនូវទិដ្ឋភាព ឬចំណុចមួយនៅក្នុងខ្លួនរបស់គាត់ ។ ថាតើនោះជាការយល់ឃើញរបស់លោកនៅពេលនោះ ឬយ៉ាងម៉េច?

**ឆ៖** បាទ, ជាការពិត ។ នៅពេលដែលរូបគាត់បានដើរចូលមក ហើយចូលមកទទួលយកព្រះថាជាព្រះដែលជួយសង្គ្រោះទៅដល់គាត់ ។ នៅពេលនោះ ដោយសារតែគាត់ដឹងថាជីវិតរបស់គាត់ គឺគ្មានអ្វីទាំងអស់ គ្មានភាពស្ងប់ស្ងាត់ក្នុងចិត្ត គ្មានភាពរីករាយ គ្មានភាពស្រឡាញ់នៅក្នុងខ្លួន ។ ក្រោយពីពេលដែលគាត់ទទួលយកសាសនាគ្រិស្ត គឺខ្ញុំសង្កេតឃើញថាគាត់ក្លាយទៅជាបុរសថ្មីមួយរូបដែលពោរពេញទៅដោយភាពស្ងប់ស្ងាត់ ភាពស្រឡាញ់ រាក់ទាក់ និងភាពជិតស្និទ្ធ ហើយគាត់ស្វែងយល់អំពីជីវិតរបស់គាត់ ។

[១០:១៣:៣៥]

**ស៖** តើលោកយល់ស្របជាមួយខ្ញុំដែរឬទេ? ប្រសិនបើខ្ញុំនិយាយថា ក្រៅពីទទួលការអប់រំទៅលើព្រះនោះ បុគ្គលមួយរូបគាត់ទាមទារឲ្យមានការជួបប្រទះ ជួបប្រឈមផ្ទាល់ខ្លួនរបស់គាត់ទៅនឹងព្រះ ហើយការជួបជាមួយព្រះនោះ គឺមិនមានភាពចាំបាច់តម្រូវឲ្យមានការសិក្សាច្រើននោះទេ ។

**ឆ៖** ខ្ញុំយល់ស្របទៅលើចំណុចនេះ ។ វាមិនចាំបាច់តម្រូវឲ្យមានការអប់រំ ការសិក្សាទៅលើព្រះច្រើននោះទេ គឺអារម្មណ៍ទាំងអស់នេះផុសចេញពីក្នុងចិត្តរបស់បុគ្គលមួយរូបដែលគាត់មានឆន្ទៈក្នុងការចូលរួមចែករំលែកសាសនារបស់ព្រះទៅដល់អ្នកដទៃ ។

**ស៖** គ្រិស្តសាសនា គឺនិយាយនិងគោរពទៅលើព្រះ ហើយដោយផ្អែកទៅលើគម្ពីគ្រិស្ត ។ ថាតើមិនមានការលើកឡើងនូវឧទាហរណ៍ណាមួយនៅក្នុងគម្ពីររបស់ព្រះទេឬ ទាក់ទងទៅនឹងបុគ្គលដែលគាត់មានចិត្តផ្លាស់ប្តូរសាសនា? ហើយអ្នកទាំងនោះកាលពីមុនជាអ្នកដែលប្រព្រឹត្តនូវអំពើទុច្ចរិត ឬឧក្រិដ្ឋមួយចំនួន តើមានការលើកឡើងទៅលើចំណុចនេះដែរឬទេ?

**ឆ៖** លោកមេធាវីការពារក្តី! យោងតាមគម្ពីររបស់ព្រះទាំងមូល គឺយើងគិតថាវាជាការប្តេជ្ញានៅពេលដែលបុគ្គលមួយរូបប្រគល់ជីវិតរបស់ព្រះ ហើយទទួលពិធីជ្រមុជទឹកនោះ គាត់ត្រូវតែដើរស្វែងរកគាត់ត្រូវតែចេញទៅដើម្បីចែករំលែកនូវចំណុចថ្មីៗទាំងឡាយទៅដល់អ្នកដទៃ ។ ខ្ញុំនៅចងចាំនៅលើ

លោក កាំង ហ្គេកអ៊ាវ ហង់ ពិន ឬក៏ ឌុច នេះ គឺគាត់បានអាននូវគម្ពីរ ហើយគាត់ធ្វើទៅតាមគម្ពីរ ដូច្នេះ ហើយគឺគាត់រៀនទៅលើបន្ទូលរបស់ព្រះ ហើយគាត់ធ្វើទៅតាមបន្ទូលទាំងអស់នោះ ។ នៅក្នុងជំពូកទី ២៨ គឺមានការថែងអំពីចំណុចទាំងអស់នោះ ។

**ស៖** ដើម្បីនិយាយឲ្យជាក់លាក់ថា តើវាជាករណីដែរឬទេ? ដែលថាគ្រប់បុរស និងគ្រប់ស្ត្រីទាំងអស់ គឺគាត់នឹងយល់ឃើញអំពីអតីតកាលរបស់គាត់ ហើយគាត់នឹងត្រូវការគិតទៅលើចំណុចនោះ ហើយនិងព្រះរបស់គាត់ ។

**ឆ៖** ខ្ញុំបានជួបអ្នកដែលជឿទៅលើសាសនានេះជាច្រើន នៅពេលដែលពួកគេទាំងអស់នោះគាត់ចាប់ផ្តើមសិក្សាអំពីព្រះ ហើយយល់ស្វែងយល់អំពីព្រះ។ ដូច្នេះ ពួកគេអាចស្វែងយល់នូវអ្វីដែលគាត់បានធ្វើនៅពេលអតីតកាល ។ គាត់មិនរីករាយទេនៅពេលដែលគាត់បានប្រព្រឹត្តអំពើនៅក្នុងអតីតកាល ។ ដោយសារតែអ្នកទាំងអស់នោះ គាត់មិនចង់ធ្វើនូវអំពើអាក្រក់ទាំងឡាយទេ ។ គាត់ចង់ធ្វើតែអំពើល្អ ប៉ុន្តែគាត់មិនអាចធ្វើទៅបាន ។ ក្រោយពីអ្នកទាំងអស់នោះក្លាយទៅជាអ្នកគោរពសាសនា គាត់ចាប់ផ្តើមធ្វើអំពើល្អនោះ មិនត្រឹមតែសម្រាប់ខ្លួនគាត់ទេ គាត់ព្យាយាមធ្វើការលះបង់និងពលីដើម្បីព្រះរបស់គាត់ទៅលើអ្នកដទៃផងដែរ ។

ដូច្នេះ ខ្ញុំអាចយល់ឃើញថា លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ឬក៏ ហង់ ពិន នោះ ។ ខ្ញុំអាចយល់ឃើញថា គាត់គឺជាបុរសមួយរូបដែលខ្ញុំអាចនិយាយបានថា គឺជាបុរសដែលគោរពទៅលើព្រះ ហើយគាត់មានទឹកចិត្តបម្រើព្រះ ហើយមានឆន្ទៈស្ម័គ្រចិត្តក្នុងការបម្រើព្រះ និងសហគមន៍របស់គាត់ ហើយចែករំលែកសេចក្តីស្រឡាញ់ គោរពរបស់ព្រះទៅដល់អ្នកដទៃ ។

[១០:១៩:០១]

**ស៖** លោកបានលើកឡើងថា ឌុច ក្រោយមកបានធ្វើការនៅជំរំជនភៀសខ្លួន ថាតើលោកបានដឹងទៅលើអំឡុងពេលនោះដែរឬទេ? ហើយលោកអាចជម្រាបទៅលើអំឡុងពេលដែលគាត់បានផ្លាស់ប្តូរសាសនានោះដែរឬទេ?

[១០:១៩:២៥]

**ឆ៖** ក្រោយពីគាត់បានផ្លាស់ប្តូរសាសនា ខ្ញុំទទួលបានដំណឹងថាគាត់បានចូលរួមនៅក្នុងបេសកកម្មសាសនាមួយចំនួន ដូចជាការបង្រៀនអប់រំទៅលើអ្នកស្ម័គ្រចិត្ត ហើយគាត់ធ្វើការនៅសម្រាប់អង្គការធ្វើការឲ្យអង្គការមួយចំនួន។ ហើយខ្ញុំនៅចាំថា ប្រហែលជានៅចុងឆ្នាំ១៩៩៨ នៅពេលដែលខ្ញុំទទួលបាន

លិខិតរបស់គាត់មួយច្បាប់តាមរយៈអ្នកធ្វើបេសកកម្មសាសនា បញ្ជូនមកការិយាល័យរបស់ខ្ញុំ។ នៅក្នុងលិខិតនោះ គឺគាត់បានសុំឲ្យខ្ញុំបួងសួងរបស់គាត់ និងគ្រួសាររបស់គាត់ និងបួងសួងទៅដល់បេសកកម្មសាសនារបស់គាត់ ។ នោះហើយជាពាក្យចុងក្រោយដែលខ្ញុំទទួលបានពីគាត់ មុនពេលដែលខ្ញុំជួបគាត់សាជាថ្មីនៅចុងឆ្នាំ២០០៨ ។

**ស៖** ដូច្នេះលោកបានជួបគាត់សាជាថ្មីនៅពេលដែលលោកមកជួបគាត់នៅមន្ទីរឃុំឃាំង ។ ដូច្នេះលោកបានទទួលការរៀបចំឲ្យជួបជាមួយនឹងគាត់ពីខាងសហចៅក្រមស៊ើបអង្កេត ។ បន្ទាប់ពីការជួបប្រទះទៅលើហេតុការណ៍ទាំងឡាយក្រោយពីការទទួលនូវពិធីជ្រមុជទឹករហូតមកដល់ពេលដែលលោកជួបគាត់ចុងក្រោយក្នុងប៉ុន្មានខែមុននេះ ។ តើលោកអាចជម្រាបអង្គជំនុំជម្រះបានដែរឬទេថា ឥរិយាបថ របស់លោក ឌុច នេះគឺជាឥរិយាបថដែលសំដែងចេញពីភាពស្មោះត្រង់របស់គាត់?

**ឆ៖** ជាការពិត ក្រោយពីខ្ញុំទទួលបាននូវការអនុញ្ញាតពីតុលាការឲ្យចូលជួបគាត់ ។ ក្នុងកំឡុងពេលដែលខ្ញុំចូលជួបគាត់ ពេលវេលាដែលខ្ញុំមកលេងគាត់ភាគច្រើននោះ គឺនៅថ្ងៃអាទិត្យដើម្បីធ្វើការធ្វើពិធីគោរពសាសនាបន់ស្រន់ ដើម្បីឲ្យយើងពិនិត្យទៅលើអតីតកាល ហើយធ្វើការឧទ្ទិសឋានទៅដល់ព្រះ ចូលរួមចំណែកចែករំលែកនិងគោរពទៅដល់ព្រះ ។ ធ្វើការឧទ្ទិសឋាន ហើយពេលវេលាជាច្រើនខ្ញុំសង្កេតឃើញថាលោក កាំង ហ្គេក អ៊ាវ ឬក៏លោក ឌុច គាត់បានជម្រាប និងប្រាប់ខ្ញុំថា គាត់មានការសោកស្តាយចំពោះអ្វីដែលគាត់បានធ្វើនៅក្នុងពេលអតីតកាល ។ ហើយគាត់ពិតជាមិនមានភាពសប្បាយចិត្តនូវអ្វីដែលគាត់បានធ្វើពីអតីតកាលនោះទេ ។ ហើយគាត់មានការសោកស្តាយជាខ្លាំង ហើយសូមទោសខ្ញុំ និងសូមទោសទៅលើប្រជាជនកម្ពុជាទាំងពួង ។

នៅពេលដែលខ្ញុំចូលមកជួបគាត់ដើម្បីថ្វាយបង្គំព្រះនោះ ខ្ញុំជំរុញឲ្យគាត់មានភាពរឹងមាំនិងគោរពទៅលើព្រះ ហើយខ្ញុំអាចជម្រាបថា នៅពេលដែលយើងឃើញបុគ្គលម្នាក់ដែលគាត់ប៉ានឈានជើងចូលមកសារភាពនូវពិរុទ្ធភាពរបស់គាត់ ហើយមានចិត្តក្នុងការទទួលខុសត្រូវទៅលើឧក្រិដ្ឋកម្មដែលគាត់បានប្រព្រឹត្តក្នុងអំឡុងពេលរបបខ្មែរក្រហម ឬសម័យវាលពិឃាដនោះ ។ ហើយគឺខ្ញុំជឿទៅលើគាត់នូវអ្វីដែលគាត់បានទទួលនូវឧក្រិដ្ឋកម្មដែលគាត់បានប្រព្រឹត្ត ហើយនិងការដាក់ទោសចំពោះគាត់ ។ ហើយខ្ញុំក៏បានជំរុញឲ្យគាត់បន្តការអប់រំបង្រៀន ហើយនិងចែករំលែកសេចក្តីស្រឡាញ់របស់ព្រះទៅដល់អ្នកដទៃផ្សេងទៀត ដោយសារតែព្រះយ៉េស៊ូគ្រិស្ត គឺអាចដែលជាព្រះមួយរូបដែលផ្តល់ចម្លើយទៅដល់យើង ដោយសារតែគាត់មានភាពស្ងប់ស្ងាត់ និងសន្តិភាពនៅក្នុងខ្លួន ។ ដូច្នេះហើយខ្ញុំបានជំរុញនិងអូសទាញ

ឌុច ឲ្យធ្វើការបន្តនូវបេសកកម្មសាសនារបស់គាត់បន្តទៀត ។

**ស៖** ខ្ញុំគិតឃើញថា ឌុច ប្រហែលជាបានបង្ហាញលោកនូវសៀវភៅមួយក្បាល ដែលគាត់ទទួលបានពី *ដេសមិន ទូទូ* (Desmond Tutu) ។ ខ្ញុំគិតថា ប្រហែលជាគាត់បានបង្ហាញលោកអំពីហត្ថលេខាដែល *ដេសមិន ទូទូ* បានចុះហត្ថលេខានៅពេលដែលគាត់ជួបជាមួយនិង *ដេសមិន ទូទូ* ហើយប្រហែលជាលោកអាចអាននូវចម្លើយរបស់លោក *ដេសមិន ទូទូ* ដែលគាត់បួងសួង ឧទ្ទិសឋាន ទៅដល់គាត់ ហើយនិងទទួលស្គាល់ទៅលើការសារភាពទោសរបស់គាត់ ។

**ឆ៖** ជាការពិត លោកមេធាវីការពារក្តី ។ គាត់បានបង្ហាញនូវសៀវភៅនេះជូនខ្ញុំមើល ហើយគាត់បានបង្ហាញទំព័រដែលមានចុះហត្ថលេខាពីលោក *ទូទូ* ហើយគឺខ្ញុំជំរុញឲ្យគាត់បួងសួង និងអធិដ្ឋានក្នុងនាមជាអ្នកជឿព្រះនោះផងដែរ ។ នៅក្នុងប្រទេសកម្ពុជា រួមទាំងនៅក្នុងពិភពលោកទាំងមូល ហើយជំរុញឲ្យគាត់មានភាពរឹងមាំនៅក្នុងការជឿទៅលើព្រះ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធានជាទីគោរព! ខ្ញុំពុំមានសំណួរបន្តទៀតនោះទេ ។ សូមអរគុណច្រើនលោកគ្រូគង្វាលដែលលោកបានមកចូលរួមនៅចំពោះមុខ នៅទីនេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តអង្គជំនុំជម្រះផ្តល់ឱកាសដល់ជនជាប់ចោទក្នុងការធ្វើការកត់សម្គាល់នូវសក្ខីកម្មរបស់សាក្សីរូបនេះ ប្រសិនបើជនជាប់ចោទមានបំណង ។

សូមអញ្ជើញ ។

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន! ខ្ញុំសូមអរគុណព្រះជាម្ចាស់ដែលប្រទានពរឲ្យខ្ញុំបានជួបលោកគ្រូ គង្វាលគ្រីស្តូហ្វឺ ឌឺឡាប៉ែល ដែលជាគ្រូគង្វាលរបស់ខ្ញុំ ។ ឯចំណែកជំនឿរបស់ខ្ញុំចំពោះព្រះជាម្ចាស់យ៉ាងម៉េច ខ្ញុំនឹងដាក់ខ្លួនជូនអង្គជំនុំជម្រះសួរបញ្ជាក់ខ្ញុំថែមទៀត នៅពេលណាដែលអង្គជំនុំជម្រះលោកត្រូវការ ។ សូមអរព្រះគុណព្រះជាម្ចាស់ ។

[១០:២៧:៤៩]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដំណើរការប្រព្រឹត្តិទៅនៃសវនាការស្តាប់សក្ខីកម្មសាក្សី គ្រីស្តូហ្វឺ ឡាប៉ែល ឃើញថា

ដល់ទីបញ្ចប់ហើយ ។ អង្គជំនុំជម្រះសូមថ្លែងអំណរគុណចំពោះ សាក្សី គ្រីស្តូហ្វឺ ឡាប៉ែល ដែលបានអញ្ជើញចូលរួមផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះតាមការកោះហៅ ។

មន្ត្រីតុលាការសម្របសម្រួលដល់សាក្សីរូបនេះ ដើម្បីទាក់ទងជាមួយនិងផ្នែកខាងគាំពារសាក្សី និងអ្នកជំនាញ ដើម្បីឲ្យគាត់ត្រឡប់ទៅលំនៅដ្ឋាន ឬក៏ទិសដៅដែលគាត់ចង់ទៅ ហើយនិងជាបន្តនេះក្រឡាបញ្ជីសវនាការសូម បញ្ជាក់សាជាថ្មីម្តងទៀត អំពីស្ថានភាពវត្តមាន ឬក៏អវត្តមានសាក្សីមួយរូបទៀត *រ៉ូប៊ីត ពីឆេ* តើយ៉ាង ម៉េចដែរ ឬសាក្សី *រ៉ូប៊ីត ពីឆេ* ដែលត្រូវធ្វើសវនាការបន្ទាប់នេះ-- ធ្វើការផ្តល់សក្ខីកម្មបន្ទាប់ពីនេះទៅនេះ?

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន ។ សាក្សី *រ៉ូប៊ីត ពីឆេ* អវត្តមាន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ហ្វ្រង់ស្វ័រ រូ យើងម៉េចទៅអំពីសាក្សី *រ៉ូប៊ីត ពីឆេ*?

**លោក ហ្វ្រង់ស្វ័រ រូ៖**

រ៉ូប៊ីត ពីឆេ គឺគាត់មិនមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជានោះទេ ។ ដូច្នេះហើយគាត់មិនអាចមកចូលរួមនៅព្រឹកនេះនោះទេ ។ ខ្ញុំបានផ្តល់ព័ត៌មាននេះកាលពីសប្តាហ៍មុនរួចហើយ។ លោកប្រធាន ខ្ញុំក៏សូមឆ្លៀតឱកាសនៅទីនេះ លើកឡើងថាមេធាវីការពារក្តីស្នើសុំដាក់នូវឯកសារសៀវភៅបន្ថែមមួយនេះដែរ សូមឲ្យវាដាក់ជាផ្នែកនៃសំណុំរឿងរបស់យើង ដូចដែលយើងបានលើកនៅក្នុងសំណើរបស់យើងថ្ងៃទី២៧ ខែមករា ២០០៩ គឺវាមានលេខ E5/9 ។ ដូច្នេះហើយខ្ញុំស្នើសុំឲ្យដាក់សៀវភៅនេះនៅក្នុងសំណុំរឿងរបស់យើង ។ សៀវភៅនេះមានជាភាសាបារាំង និងភាសាអង់គ្លេស ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក់ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំចង់ឲ្យលោកបំភ្លឺថា ចំពោះជំហររបស់មេធាវីការពារចំពោះសាក្សី *រ៉ូប៊ីត ពីឆេ* គាត់មិននៅប្រទេសកម្ពុជាទេ ។ តើលោកមានបំណងចង់ៗដកសាក្សីហ្នឹងចេញពីបញ្ជីដែលលោកស្នើដែរឬទេ? ហើយយើងក៏ចង់ស្តាប់ជំហររបស់ភាគីផ្សេងទៀតដែរ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

អង្គភាពជនរងគ្រោះបានស្នើប្រាប់យើង ហើយយើងបានជម្រាបថា យើងលះបង់សិទ្ធិក្នុងការអញ្ជើញសាក្សីនេះ ពីព្រោះថា វាមានការលំបាកបញ្ជូនមក ហើយមិនស្នើសុំឱ្យអង្គជំនុំជម្រះកោះហៅលោក *រ៉ូប៊ឺត ពីឆេ* ទេពីព្រោះគាត់មិននៅក្នុងកម្ពុជាទេ នៅពេលបច្ចុប្បន្ននេះ ។ ដោយហេតុថា យើងមានវត្តមានរបស់លោកគ្រូគង្វាល *បាស្ទ័រ ឡាប៉ែល* រួចហើយ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះយើងបានព័ត៌មានហើយថា ការវិភាគដែលត្រូវធ្វើសវនាការចំពោះសាក្សី *រ៉ូប៊ឺត ពីឆេ* បន្ទាប់ពីសាក្សីអម្បាញ់មិញនេះ គឺ *គ្រីស្តូហ្វឺ ឡាប៉ែល* នៅព្រឹកនេះ ។ ដូច្នេះអង្គជំនុំជម្រះសម្រេចជំនួសនៃដំណើរការសវនាការ ពេលវេលាសម្រាប់ស្តាប់សក្ខីកម្មសាក្សី *រ៉ូប៊ឺត ពីឆេ* ក្រោយពេលសម្រាក ឈប់សម្រាកនេះទៅ គឺជំនួសដោយការស្តាប់នូវចម្លើយរបស់ជនជាប់ចោទ ពាក់ព័ន្ធជាមួយនឹងអត្តចរិតរបស់ជនជាប់ចោទ ដែលការដំណើរការសវនាការពីមុនគឺនៅបន្តដោយអង្គជំនុំជម្រះសាលាដំបូង ហើយនិងភាគី ។

សូមអញ្ជើញ លោក ហ្សង់ម៉ាក តើមានបញ្ហាអីទេ?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំមានសំណួរមួយទៀតចំពោះមេធាវីការពារ ។ លោកបាននិយាយថា លោកចង់ដាក់ឱ្យមានកំណត់ត្រានៅក្នុងដំណើរការនីតិវិធីនេះ នូវសៀវភៅមួយដោយលោក *ដេសមិន ទូទូ* តើគោលបំណងក្នុងការដាក់នេះ លោកចង់បានអ្វី? តើជាគំនិតចង់ដាក់សៀវភៅនោះដើម្បីដេញដោលចំពោះមុខតុលាការ ឬក៏យ៉ាងដូចម្តេច?

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកចៅក្រម។ យើងខ្ញុំបានស្នើសុំដាក់ជូនអង្គជំនុំជម្រះដើម្បីដេញដោលនូវសៀវ-ភៅមួយចំនួន ដោយរាប់ទាំងសៀវភៅ ដែលសរសេរឡើងដោយ *ហ្វីលីព សត* ដែលមានចំណងជើងថា "ប៉ុល ពត" ហើយនិង នៅក្នុងបញ្ជីនោះមានសៀវភៅមួយនេះដែរ ដែលជាសៀវភៅបោះពុម្ពចុងក្រោយដោយ *ដេសមិន ទូទូ* ដែលមានបកប្រែទៅជាភាសាបារាំងផងដែរ ដែលមានអត្ថបទមួយចំនួនដែលមេធាវីការពារនឹងប្រើនៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួន ។ ដូច្នេះ ជាសំណើដ៏គួរសមមួយ នេះជាការសមស្របដើម្បីឱ្យអង្គជំនុំជម្រះពិចារណា ហើយនិងមេធាវី ហើយនិងសហព្រះរាជអាជ្ញាក៏គប្បីជ្រាបដែរថា ខ្ញុំ

នឹងប្រើសៀវភៅនេះនៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្ញុំ ។

នៅពេលដែលខ្ញុំមានវេទិកាហើយខ្ញុំចង់ស្នើថា តើយើងអាចប្រើពេលវេលានេះដើម្បីអាននូវសំបុត្ររបស់សាក្សីមួយដែលបានទទួលមរណភាពក្នុងពេលនេះ គឺលោក *ហេនរី យើង* ។ លោកសាស្ត្រាចារ្យ *ហេនរី យើង* ក៏នៅក្នុងបញ្ជីសាក្សីរបស់ដែលយើងខ្ញុំស្នើដែរ ហើយយើងបានជ្រាបហើយថា គាត់បានទទួលមរណភាព ។ លោក ហេនរី យើង គឺជា គាត់ជាអតីតសហព្រះរាជអាជ្ញាមួយនៅក្នុងសាលាក្តីនូរឹមប៊ឺក ហើយនៅក្នុងរឿងក្តី *ឡូកឃើរិច* គាត់បានរៀបចំលិខិតមួយដើម្បីផ្តល់ជាសក្ខីកម្ម ។ មេធាវីការពារសុំការអនុញ្ញាតដើម្បីអានសំបុត្ររបស់គាត់នៅក្នុងតុលាការ ។ យើងអាចប្រើសំបុត្រនេះនៅក្នុងសេចក្តីសន្និដ្ឋាន ហើយសំបុត្រហ្នឹងមានតែមួយទំព័រទេ ។

[១០:៣៦:០៣]

**ប្រធានអង្គជំនុំ៖**

ម៉េចទៅខាងសហព្រះរាជអាជ្ញា តើមានមតិយោបល់អ្វីទេនៅលើបញ្ហាទាំងពីរ? បញ្ហាមួយគឺការស្នើសុំដាក់នូវសៀវភៅដែលមានលេខ E5/49 ដែលស្នើឡើងដោយមេធាវីការពារក្តីអម្បាញ់មិញនេះ ហើយមួយទៀត គឺលិខិតរបស់សាក្សីមួយរូបដែលបានទទួលមរណភាព ហើយបញ្ហានេះគឺអង្គជំនុំជម្រះបានទទួលការស្នើសុំរបស់មេធាវីការពារក្តី ហើយចាត់ទុកថាដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ ហើយកាលនោះ គឺភាគីទាំងអស់មិនការជំទាស់អ្វីទេ ។

**លោកស្រី ជា លាង៖**

សូមអរគុណលោកប្រធាន ហើយក្នុងនាមជាសហព្រះរាជ្ញាគឺថាសូមឲ្យមានការចូលរួមយោបល់បន្តិចអំពីបញ្ហាចំណុចទីមួយ ។

ចំណុចទីមួយ លោកមេធាវីការពារជនជាប់ចោទ បានស្នើសុំឲ្យដាក់សៀវភៅនៅក្នុងសំណុំរឿង ហើយមេធាវីការពារជនជាប់ចោទបានលើកហើយថា សៀវភៅនេះមានតែពីរភាសាទេ គឺភាសាបារាំង និងភាសាអង់គ្លេស តើយើងគួរពិចារណាថា អ្វីដែលមេធាវីជនជាប់ចោទចង់លើកនិងយកមកសំអាងក្នុងសេចក្តីសន្និដ្ឋាននៅពេលបញ្ចប់នោះ យើងគប្បីមានភាសាខ្មែរដែរឬអត់? ព្រោះចៅក្រមភាគច្រើននៅក្នុងអង្គជំនុំជម្រះនេះគឺសុទ្ធតែចៅក្រមខ្មែរ ហើយយើងគួរគប្បីនូវយល់អ្វីដែលបានសរសេរនៅក្នុងសៀវភៅដើម្បីយើងបានយល់ទាំងអស់គ្នា។

ខ្ញុំយល់ថា នៅចំណុចដែលសំខាន់ត្រង់ទំព័រណានោះ ដែលមេធាវីមានបំណងចង់ប្រើប្រាស់នៅ

ពេលធ្វើសន្និដ្ឋានបញ្ចប់ចុងក្រោយហ្នឹងគួរតែមានខ្មែរដែរ ដើម្បីយើងយកសេចក្ដីសម្រេចហ្នឹង យល់ថាអាហ្នឹងវាចង់និយាយទៅផ្នែកអីមួយ ដែលយើងគួរតែយល់ទាំងអស់គ្នា មិនមែន-- ខ្ញុំយល់ថាចៅក្រមក៏ដូចជាសហព្រះរាជអាជ្ញាខ្មែរដែរ គឺថា មិនអាចយល់នូវភាសាពីរនេះទាំងអស់គ្នាបានទេ ។ អានេះខ្ញុំគ្រាន់តែជាការមួយផ្ដល់យោបល់ឲ្យអង្គជំនុំជម្រះពិចារណានៅលើចំណុចនេះ ហើយបើយើងគិតថាត្រូវតែមានភាសាខ្មែរទាំងអស់នោះ ក៏វាជាការពិបាកដែរ ដោយសារសៀវភៅនេះមានទំហំមួយក្រាសហើយ យើងបកប្រែវាពិបាកក្នុងការបកប្រែ ។ នេះចំណុចមួយ ។

[១០:៣៨:៣៤]

ដោយឡែកចំណុចទីពីរ ដែលថាសាក្សីបានមរណភាពហើយនោះ ខ្ញុំក៏ឯកភាពទៅនឹងប្រធានអង្គជំនុំជម្រះដែលបានលើកឡើងហើយថា ការដាក់-- នៅមាននៅក្នុងសំណុំរឿងហើយ ដូច្នេះចាត់ទុកថានេះអង្គជំនុំជម្រះអាចយកជាការសម្រេចក្នុងសាលក្រមចុងក្រោយ ក៏យើងអនុវត្តបានដែរ ។ ដូច្នេះដោយសារឯកសារនោះមាននៅក្នុងសំណុំរឿងស្រេចហើយដែរ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីការពារក្ដី ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន! ដើម្បីឆ្លើយតបទៅនឹងសំណើដោយលោកជំទាវសហព្រះរាជអាជ្ញានោះ ខ្ញុំសូមបញ្ជាក់ពីចំណុចទីមួយថា នៅពេលដែលខ្ញុំពិនិត្យមើលសៀវភៅដោយ *ហ្វីលីព សត* គឺសៀវភៅនេះភាសាបារាំងទេ មិនមានអត្ថបទភាសាខ្មែរដែលបកប្រែ ប្រសិនបើលោកស្រីសហព្រះរាជអាជ្ញាចង់បានលោកស្រី ជា លាង គឺថាយើងអាចបានជួប ហើយខ្ញុំមិនបានជួបលោកស្រីក្នុងរយៈពេលយូរដែរមកហើយ។ តើលោកស្រីចង់លើកឡើងទឡ្ហីករណ៍បែបនេះមែនឬទេ? ខ្ញុំនឹងតវ៉ាចំពោះការដាក់ជូនតុលាការរាល់ដែលឯកសារដែលមិនបានបកប្រែទៅជាភាសាបារាំង គឺឯកសារជាងពីររយដែលដាក់ទៅជូនតុលាការដែលថាមេធាវីការពារមិនបានជំទាស់ទេ ដោយសារថា-- នូវឯកសារដែលបានដាក់នោះ ។ អ៊ីចឹងមេធាវីការពារមានការបត់បែនទាក់ទងទៅការលំបាកនៃការបកប្រែ ហើយខ្ញុំមិនរំពឹងថាឲ្យខាងសហព្រះរាជអាជ្ញាធ្វើអ្វីដែលលើសពីសម្បទានដែលយើងបានផ្ដល់នោះទេ ។

**អ្នកបកប្រែ៖**

ការកែតម្រូវពីអ្នកបកប្រែ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញ ដើម្បីបន្តដំណើរការសវនាការ ។

*[សវនាការសម្រាកពីម៉ោង១០:៤១នាទី ដល់ម៉ោង ១១:០៦នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយសូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិចង់មានបញ្ហា មានយោបល់អីទៅ?

**លោក វីលៀម ស្មីត៖**

អរុណសួស្តីលោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព ខ្ញុំសូមលើកឡើងយោបល់ខ្លីមួយមុនពេលសម្រាក គឺលើបញ្ហាអំពីការបកប្រែទាក់ទងទៅនឹងសៀវភៅរបស់ ទូទូ ។ ការព្រួយបារម្ភរបស់សហព្រះរាជអាជ្ញាជាតិនោះ គឺថាយើងខ្លាចមានការដកស្រង់ចេញពីសៀវភៅនោះច្រើនដាក់ចូលទៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់នៅក្នុងសារណារបស់មេធាវីការពារក្តី ។ ដូច្នេះ ហើយចំពោះសហមេធាវី--សហព្រះរាជអាជ្ញាជាតិនោះ ក៏បានលើកឡើងបញ្ហានេះ ហើយយើងបាននិយាយជាមួយមេធាវីការពារក្តី គឺឲ្យមេធាវីការពារក្តីជួយបញ្ជាក់ជូនយើងខ្ញុំអំពីទំព័រ ឬក៏ចំណុចជាក់លាក់ដែលគាត់ចង់សរសេរនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់របស់គាត់ ។ ដូច្នេះ ហើយយើងមិនបដិសេធនៅក្នុងការទទួលយកសៀវភៅដែលដាក់ជូនជាពីរភាសានោះទេ ដូច្នេះ ហើយខ្ញុំគិតថា វាជាការយល់គ្នាខុសទេទៅលើចំណុចហ្នឹង តាមពិតមិនមានការជំទាស់គ្នាទៅលើចំណុចហ្នឹងទេ គ្រាន់តែឲ្យមេធាវីការពារក្តីជួយបញ្ជាក់ទៅលើទំព័រដែលគាត់នឹងដកស្រង់ដាក់ចូលក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ហ្វ្រង់ស្វ័រ រូ អាចបញ្ជាក់បានទេអំពីសំណូមពររបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិដែលបានលើកឡើងអម្បាញ់មិញនេះ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

ដូច្នេះ ខ្ញុំគិតថា ខ្ញុំបានស្តាប់ឮហើយ គឺពីខាងតំណាងសហព្រះរាជអាជ្ញា គ្រាន់ជាការយល់គ្នា

ខុសទៅលើបញ្ហានេះតែប៉ុណ្ណោះ ។ ដូច្នេះ ហើយខ្ញុំនឹងទទួលយកទៅលើការស្នើឡើងនេះ ហើយខ្ញុំនឹងជូនព័ត៌មានទៅលើព័ត៌មានរឿងកន្លែងដែលខ្ញុំដកស្រង់ចេញពីសៀវភៅ ហើយខ្ញុំនឹងជម្រាបទៅខាងតំណាងសហព្រះរាជអាជ្ញាឲ្យបានជ្រាបទៅលើបញ្ហាហ្នឹង ដើម្បីឲ្យមានការបកប្រែទៅលើផ្នែកពាក់ព័ន្ធ ។

សូមអរគុណលោកប្រធាន ។

[១១:០៩:១៨]

**ប្រធានអង្គជំនុំ៖**

ដើម្បីបញ្ជាក់បន្ថែមឲ្យបានច្បាស់ក្នុងការអនុវត្តដាក់ឯកសារតាមវិធាន៨៧.៤ ហើយនិងកាលវេលានៃការកំណត់ឲ្យភាគីដាក់ឯកសារចុងក្រោយសម្រាប់ ក្នុងកិច្ចដំណើរការសំណុំរឿងលេខ០០១នេះ ខ្ញុំសូមប្រគល់ភារៈជូនទៅលោកចៅក្រម ហ្សង់ម៉ាក ដើម្បីបញ្ជាក់ជូនភាគីឲ្យបានជ្រាបអំពីបញ្ហាការអនុវត្តនូវវិធាន៨៧.៤ ហើយនិងការកំណត់ពេលវេលាចុងក្រោយសម្រាប់ដាក់ សម្រាប់កំណត់ឲ្យភាគីដាក់ឯកសារនានា ដែលខ្លួនប៉ុនប៉ងលើកឡើងដាក់ចំពោះមុខអង្គជំនុំជម្រះ ដែលឯកសារដែលនៅសេសសល់មិនទាន់បានលើកឡើងនោះ ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជឿថាគោលបំណងរបស់អង្គជំនុំជម្រះ គឺយើងចង់រំឭកទៅលើវិធានមួយចំនួនដែលវាពាក់ព័ន្ធទៅនឹងការបង្កើតនូវឯកសារផ្សេងៗដាក់ដេញដោលដែលមិនមានដាក់ជូននៅក្នុងសំណុំរឿងរបស់យើង ។ វិធាន៨៧.៤ នៃវិធានផ្ទៃក្នុងចែងថា អង្គជំនុំជម្រះអាចស្នើសុំភាគី--អាចទទួលយកនូវភស្តុតាងថ្មីៗដែលមានប្រយោជន៍នូវការស្តាប់នូវ-- សម្រាប់នាំមកនូវសេចក្តីស្វែងរកការពិត ។ ដូច្នេះ ហើយអង្គជំនុំជម្រះនឹងធ្វើការពិនិត្យទៅលើឯកសារទាំងអស់នោះ ដោយផ្អែកទៅលើលក្ខណៈវិនិច្ឆ័យដូចមានចែងនៅក្នុងវិធាន អនុវិធានទី៣ ដែលមានចែង ហើយក៏មិនវិធីសាស្ត្រដើម្បីពន្យារពេលវេលាណាមួយនៅក្នុងការដាក់ឯកសារ ។ ដូច្នេះ ហើយគឺខ្ញុំសូមបញ្ជាក់ថា ការបង្កើតធាតុផ្សំព័ត៌មានទាំងឡាយណា គឺវាកើតចេញពីសំណើរបស់ភាគី ហើយអង្គជំនុំជម្រះគឺចង់ធ្វើយ៉ាងណាដាក់ឲ្យទាន់វេលា ដើម្បីឲ្យយើងអាចពិនិត្យទៅលើសំណើទាំងអស់នោះ និងឯកសារដែលបានដាក់ជូន ។

ដូច្នេះ ហើយទើបយើងឃើញមានចែងនៅក្នុងវិធានផ្ទៃក្នុងរបស់យើង ហើយនងតម្រូវឲ្យយើងដាក់ឯកសារទៅតាមវិធានផ្ទៃក្នុងរបស់យើង ។ យើងខ្ញុំនឹងធ្វើការពិនិត្យឯកសារទាំងអស់នោះនៅក្នុង

ពេលសមស្រប ។

ដូច្នេះ លិខិតរបស់លោកសាស្ត្រាចារ្យ ហេនរី ឃើង ដែលស្នើសុំឲ្យអាននោះ លិខិតនោះ គឺជាលិខិតដែលបានដាក់ចូលទៅក្នុងសំណុំរឿងហើយ ហើយអង្គជំនុំជម្រះមិនបានពិចារណាថា ឲ្យអាននូវលិខិតនោះទេ ។ មេធាវីការពារក្តីអាចមានឱកាសក្នុងការពិនិត្យនិងអានឯកសារទាំងអស់នោះ ហើយមានឱកាសក្នុងការដកស្រង់ខ្លឹមសារចេញពីសៀវភៅទាំងអស់នោះដាក់នៅក្នុងសន្និដ្ឋានរបស់ខ្លួន ។

[១១:១២:៤៣]

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត អង្គជំនុំជម្រះបន្តកិច្ចដំណើរការនីតិវិធីសួរចម្លើយជនជាប់ចោទ ពាក់ព័ន្ធជាមួយនឹងអត្តចរិតរបស់គាត់ ដោយអង្គជំនុំជម្រះ ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទមកកាន់ឈើរាងវង់ក្រចកសេះ ដែលរៀបចំទុកសម្រាប់ជនជាប់ចោទនៅចំពោះមុខអង្គជំនុំជម្រះ ។

ដោយហេតុនីតិវិធីនៃការសួរសំណួរកាលពីពេលមុន អំពីអត្តចរិតរបស់ជនជាប់ចោទនេះ គឺដល់អង្គជំនុំជម្រះ ដែលមានលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ជាអ្នកសួរ ហើយដោយសារកាលនោះ ពេលវេលាអស់ទៅ យើងមិនអាចបន្តដំណើរការនីតិវិធីសវនាការបាន ហើយសវនាការបន្តបន្ទាប់សុទ្ធតែអ្នកជំនាញដែលចាំបាច់ត្រូវតែស្តាប់ ដូចជាការពីចម្ងាយ ដែលគាត់មានពេលវេលាកំណត់ជាក់លាក់ ដូច្នេះយើងមិនអាចធ្វើចប់កាលនោះ។ ឥឡូវនេះ អង្គជំនុំជម្រះប្រគល់វេទិកានេះទៅចៅក្រម ហ្សង់ម៉ាក ដើម្បីបន្តសំណួរចំពោះជនជាប់ចោទ អំពីអត្តចរិតរបស់គាត់ដែលលោកមិនទាន់បានសួរ។សូមអញ្ជើញ ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន ។

**ស៖** នៅក្នុងការសួរសំណួរចុងក្រោយរបស់ខ្ញុំទៅកាន់ជនជាប់ចោទ គឺខ្ញុំបានសួរអំពីអំពើហិង្សាផ្នែកនយោបាយ ដូច្នេះ ហើយគឺខ្ញុំចង់ឆ្លៀតឱកាសយកចំណុចដែល វ៉ាអ៊ីល ចេនណា បានលើកឡើងម្សិលមិញ ដើម្បីសួរសំណួរទៅកាន់លោក ទាក់ទងទៅនឹងការបណ្តុះបណ្តាល ដូចដែលលោកបានជ្រាបហើយកាលពីម្សិលមិញ មានការពិភាក្សាដេញដោលយ៉ាងច្រើនអំពីការជំនុំជម្រះនៅសហភាពសូវៀត គឺម៉ូស្គូ គឺនៅទីនោះមានការរៀបចំជំនុំជម្រះដែលរៀបចំឡើងដោយគម្រោងលទ្ធិកុម្មុយនីស្ត ។ តើលោកត្រូវបានទទួលព័ត៌មាន និងដឹងអំពីការមានការជំនុំជម្រះដែរឬទេ នៅពេលដែលលោកទទួលបាននូវការ

បណ្តុះបណ្តាលនៅពេលនោះ?

[១១:១៥:២៦]

**ជនជាប់ចោទ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ការរៀនសូត្ររបស់ខ្ញុំមិនដែលបានឮពាក្យ *ប្រ៉ូសេឌីម៉ូស្គូ ប្រ៉ូសេឌីប្រាក* ទាល់តែសោះ ។ ខ្ញុំសូមជម្រាបដោយត្រង់ថា នៅឆ្នាំ១៩៧៧ ពេលដែលជជែកគ្នាជាមួយនឹង សុន សេន អំពីរឿងឈ្មោះបក្សតាមរយៈទូរស័ព្ទ ខ្ញុំឮ សុន សេន គាត់បញ្ជាក់ថា *ម៉ានីហ្វេស ឌុយ ប៉ាកទី កុម្មុយនីស្ត* គឺ *និវេត* (និយាយភាសាបារាំង) នៃបក្សកុម្មុយនីស្ត មិនមែន *និវេត* របស់បក្សពលករទេ ។ នៅពេលហ្នឹង គឺសុន សេន និយាយអំពីបក្សពលករដែលវៀតណាមដាក់ ។ ខ្ញុំនិយាយនេះចង់ជម្រាបថា សូម្បីតែ *និវេត* របស់បក្សកុម្មុយនីស្តកម្ពុជានោះក៏ខ្ញុំទើបនឹងឮនៅក្នុងឆ្នាំ១៩៧៧ អត្ថបទ *និវេត* ហ្នឹងអត់ទាន់បានឃើញទេ ទើបនឹងឃើញដោយខ្ញុំសុំអ្នកជំនាញ វ៉ាអ៊ែល ម៉ាកចេនណា គាត់ឲ្យខ្ញុំមួយច្បាប់ប៉ុន្មានខែនេះ ។

សរុបមក ខ្ញុំអត់ដែលឮ *ប្រ៉ូសេឌីម៉ូស្គូ ប្រ៉ូសេឌីប្រាក* ហើយនិង *ម៉ានីហ្វេសឌុយប៉ាក់ទីកុម្មុយនីស្ត* ទេ ពីជំនាន់ខ្ញុំទើបនឹងកសាងខ្លួនជាកុម្មុយនីស្តនោះ ។ គ្មាននរណាគេយកឯកសារនោះមកអប់រំខ្ញុំទេ ។

**ស៖** តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេ លោកបានអានទៅលើស្នាដៃរបស់ ស្តាលីន និង លេនីន និងបក្សកុម្មុយនីស្តបារាំងដែរឬទេ? ឬក៏លោកបានអានស្នាដៃរបស់អ្នកកុម្មុយនីស្ត ម៉ៅ សេទុង នៅចិនដែរឬទេ? ថាតើលោកបានសិក្សា និងទទួលការអប់រំអ្វីខ្លះឲ្យបានជាក់លាក់?

[១១:១៩:១៣]

**ឆ៖** ខ្ញុំសូមជម្រាបអំពីការអានរបស់ខ្ញុំជាដំណាក់ដូចតទៅ៖

នៅពេលដែលខ្ញុំបោះសៀវភៅ *អ៊ីមហ្សេប៉េ* គឺ *ម៉ាតេម៉ាទិចហ្សេណេរ៉ាល់* ទៅកៀនជញ្ជាំង ខ្ញុំរើសយកសៀវភៅបដិវត្តន៍មករៀន ។ សៀវភៅបដិវត្តន៍ដែលខ្ញុំអានដំបូង គឺសៀវភៅមកពីស្រុកចិនដែលគេគូរផង ហើយគេដាក់ចំណងជើងជាអក្សរបារាំងតិចៗនោះ ។ ក៏ប៉ុន្តែ សៀវភៅដែលខ្ញុំចាប់អារម្មណ៍ ខ្ញុំទិញពីបណ្ណាគារយកមកមើលហ្នឹងសៀវភៅមួយឈ្មោះថា "អ្វីៗដើម្បីបក្ស" និពន្ធដោយអ្នកនិពន្ធម្នាក់ឈ្មោះ *វ្ល៉ាយិនទូ* ។ គាត់គឺជាក្មេងម្នាក់កូនកម្មករនៅក្នុងតំបន់អណ្តូងធ្យូងថ្ម ។ គាត់ចូលបដិវត្តន៍ដំបូង គាត់ទៅធ្វើការនៅខាងក្រសួងយន្តយុទ្ធផ្ត័ត្រ គាត់នៅក្នុងរោងជាងជួសជុលអាវុធ ។ ដល់ថ្ងៃក្រោយមកគាត់ខំតាំងពីធ្វើ*បាយយូណែត* មិនកើត រហូតទៅដល់ធ្វើ*ឡង់ក្រូណាត់* កើត ។

ហើយដល់ចុងបញ្ចប់គាត់របួសភ្នែក របួសដាច់ដៃ ដាច់អី ប៉ុន្តែបានទៅព្យាបាលនៅសហភាពសូវៀត ។ ហើយគាត់បានត្រូវតែងតាំងជាសាស្ត្រាចារ្យគំនូរឧស្សាហកម្មនៅមហាវិទ្យាល័យមួយ ។ ខ្ញុំគិតថាបដិវត្តន៍បើគេអ៊ីចឹង ខ្ញុំធ្វើកើត ។ ដល់ចុងបញ្ចប់ខ្ញុំទៅជាសាស្ត្រាចារ្យវិញ ។

ហើយទន្ទឹមនេះ ខ្ញុំក៏បាន ដូចខ្ញុំបានជម្រាបលោកចៅក្រមរួចមកហើយ គឺខ្ញុំបានអានសៀវភៅមួយឈ្មោះថា "បឋមវិជ្ជា ទស្សនវិជ្ជា" ដែលបារាំងចំណងជើងគេដាក់ថា *"ប្រ៊ាំងស៊ីប អេឡេម៉ង់ទែ ឌឺ ឡាហ្វេលេ ហ្វីឡូសូហ្វី"* ដែលនិពន្ធឡើងបារាំងម្នាក់ឈ្មោះ *ហ្សកសឺ ប៉ូលីតហ្សឺ* ហើយបោះពុម្ពនៅក្នុង *អេឌីស្យុង សូស្យាល់* ។ នេះជាបញ្ហាមួយទៅ ។

បញ្ហាមួយទៀត ខ្ញុំយកសៀវភៅ ម៉ៅ សេទុង មកអាន គឺខ្ញុំចាប់អារម្មណ៍នឹងសៀវភៅមួយដែលមានចំណងជើងថា "ប្រជាធិបតេយ្យថ្មី" ដែលនិពន្ធដោយ ម៉ៅ សេទុង ។ ដោយខ្ញុំនិយាយទ្រឹស្តីពីរម៉ាត់ដែលខ្ញុំចាប់អារម្មណ៍ខ្លាំងជាងគេជូនលោកចៅក្រមហើយ គឺថា "គ្មានទស្សនៈណាមួយអត់ចរិតវណ្ណៈទេ" ដែលបារាំងគេថា *"អូគឺនីស កុងស៊ិបស្យុង សង់ អង់ប្រាំង ឌឺ ក្លាស្ស"* ។ ហើយពាក្យមួយទៀតរបស់ ម៉ៅ សេទុង ដែលខ្ញុំពេញចិត្ត គឺថា "សេចក្តីស្នេហាប្រជាជនពិតប្រាកដ គឺត្រូវប្រគល់លទ្ធភាពអនុវត្តផ្តាច់ការទៅឲ្យវណ្ណៈអធន ។ ការអនុវត្តផ្តាច់ការនៅក្នុងប្រជាធិបតេយ្យថ្មី គឺត្រូវអនុវត្តទៅលើចោរលួច គឺត្រូវអនុវត្តទៅលើចោរប្លន់ គឺត្រូវអនុវត្តទៅលើអ្នកដែលដុតបំផ្លាញ ហើយនិងអនុវត្តទៅលើអ្នករកស៊ីចងការដែលហុតឈាមគេ" ។ ដូច្នេះ ខ្ញុំយល់ថាទ្រឹស្តីនេះអនុវត្តកើត ។

[១១:២៧:០៥]

ឯចំណែកពេលនោះ ខ្ញុំសូមនិយាយដោយត្រង់ទៅចុះ ខ្ញុំមើលទៅ *សារតេក្រេជាង* អនុវត្តមិនកើត ។ សេចក្តីស្រលាញ់ដែលព្រះយេស៊ូ លោកអប់រំ កាលនោះខ្ញុំដឹងតិចណាស់អត់បានមើលសៀវភៅទេ គឺខ្ញុំឮគេនិយាយថា "បើគេទះកំផ្លៀងឆ្វេងអ្នកឯង ត្រូវហុចកំផ្លៀងស្តាំទៅឲ្យគេទះទៀត" ។ ដូច្នេះខ្ញុំយល់ថា អ៎!សេចក្តីស្រលាញ់បែបនេះអនុវត្តទៅមិនកើតទេ មានតែសេចក្តីបែបម៉ៅសេទុងទេដែលអនុវត្តទៅកើត ។

ខ្ញុំសូមជម្រាបបញ្ជាក់លោកចៅក្រមថា ខ្ញុំក៏បានមើលស្នាដៃរបស់ *ហ្គាន់ធី* ខ្លះដែរ ។ ខ្ញុំគិតថា ហ៊ឺ! ធ្វើតាម ហ្គាន់ធី ម៉េចកើត គាត់ជាមនុស្ស ពាក់កណ្តាលមនុស្ស ពាក់កណ្តាលអាទិទេពអ៊ីចឹង ។ ខ្ញុំគោរព ហ្គាន់ធី ខ្ញុំធ្វើ *អាប្រាង់ ឌីសឺម៉ង់ អាហ្គុប អាការូ* រូបគាត់ទុកនៅឯផ្ទះ ។

ហើយដល់ក្រោយមកខ្ញុំនៅជាប់ចិត្តទ្រឹស្តី ម៉ៅ សេទុងហ្នឹងជាងគេ នេះខ្ញុំនិយាយមុនឆ្នាំ១៩៧០។

ដល់ឆ្នាំ១៩៧០ ខ្ញុំជាប់គុក ។ ខ្ញុំទិញបានសៀវភៅមួយ ។ សៀវភៅនោះមានចំណងជើងថា ខ្ញុំនិយាយជាបារាំងចុះ *"អេគ្រីស៍ ហ្វីឡូហ្សូហ្វិក-- កាត្រឹស អេគ្រីស៍ ហ្វីស្សូហ្វិក ឌឺ ម៉ៅ សេទុង"* អត្ថបទសរសេរទស្សនវិទូរបស់ ម៉ៅ សេទុង ។ ក្នុងនុំងមានអត្ថបទបួនគាត់សរសេរ អំពីទំនាស់ ជាអត្ថបទមួយបារាំងគេថា *"អា ប្រ៉ូប៉ូស ឌឺឡា កុងត្រាឌីស្យុង"* ។ ហើយអត្ថបទទីពីររបស់គាត់សរសេរចំណងជើងជាបារាំងខ្ញុំនិយាយជាបារាំងចុះ *"ដឺឡា ហ្សឺស្ដ កុងត្រា ឌីស្យុង អូសាំង ឌុយ ពើប"*។ អត្ថបទទីបីរបស់គាត់ខ្ញុំសូមនិយាយចំណងជើងជាភាសាបារាំងដដែល *"អា ប្រ៉ូប៉ូស ឌឺ ឡា ប្រាទិក"* ។ ហើយអត្ថបទទីបួនខ្លីជាងគេបំផុត ចំណងជាភាសាបារាំងថា *"ឌូយ៉េនលេត ឌឺ ហ្សេឌីស្ដ"* ។

**ស៖** តើគំនិតត្រឹមត្រូវចេញមកពីណា?

**ឆ៖** បាទ ខ្ញុំមើល ខ្ញុំរៀននៅក្នុងគុកធំ ខ្ញុំរៀនអាហ្នឹង ។ ខ្ញុំចេញពីគុកធំទៅ ខ្ញុំអត់មានបានពាល់សៀវភៅ ម៉ៅ សេទុង អីទៀតទេ គឺរៀនឯកសារបក្ស ។ នៅក្នុងឆ្នាំ១៩៧៦ ខ្ញុំបានគេឲ្យសៀវភៅមួយដែលមានចំណងជើងថា *"ឡឺ លេនីនីស្មើស "* ដែល ស្តាលីន គាត់និពន្ធឡើង ដែលបោះពុម្ពនៅស្រុកចិនដោយបណ្ណាគារ *គូស៊ី ជូគៀន* ។ ខ្ញុំមើលបានតិចណាស់ បានពីរបីទំព័រតែប៉ុនណ្នុំង ព្រោះអត់មានពេល ។ ដូច្នេះនិយាយអំពីការរៀនសូត្ររបស់ខ្ញុំទ្រឹស្តីដែលមកពីចិនជាភាគច្រើន បន្ទាប់ពីឯកសារបក្សកុម្មុយនីស្ដកម្ពុជា ។ ខ្ញុំសូមសរុបជូនអំពីការរៀនសូត្ររបស់ខ្ញុំប៉ុណ្ណេះ ។

[១១:៣៣:៣៨]

**ស៖** ខ្ញុំគិតថាយើងអាចយល់បានអំពីការអប់រំ អំពីការសិក្សារបស់លោកតាមការអាន ប៉ុន្តែខ្ញុំចូលទៅដល់ប្រធានបទមួយដែលទាក់ទងទៅនឹងក្រុមគ្រួសាររបស់លោក លោកបានប្រាប់យើងថា នៅក្នុងគ្រួសារបដិវត្តន៍កូនមិនមែនជាកូនរបស់គ្រួសារទេគឺជាកូនរបស់អង្គការ ។ ខ្ញុំចង់ឲ្យលោកប្រាប់យើងថា តើនេះជាបទពិសោធន៍ដែលលោកបានឆ្លងកាត់ឬទេ? ទាំងទាក់ទងទៅនឹងឪពុកម្ដាយរបស់លោកហើយនិងចំពោះកូនៗរបស់លោក? តើលោកអនុវត្តគោលការណ៍នេះដែរឬទេនៅក្នុងជីវិតក្រុមគ្រួសារទំនាក់ទំនងគ្រួសាររបស់លោកនោះ? តើបានផ្លាស់ប្ដូរពីទំនាក់ទំនង ប្រាស្រ័យទាក់ទងទៅនឹងឪពុកម្ដាយរបស់លោកដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ចិត្តគំនិតវាត្រូវតែបត់ទៅតាមលក្ខខណ្ឌសម្ភារៈ។ សម្ភារៈវាកើតមុន ចិត្តគំនិតវាកើតក្រោយ ។ សម្ភារៈបារាំងគេហៅថា *ឡាម៉ាតដ៍ែ* ។ ពាក្យបារាំងគេនិយាយថា *ឡា សែ ឡាម៉ាតដែ* ឬក៏ *ដេទែមីននីស វេស្ត្រី* គឺជាសម្ភារៈជាអ្នកកំណត់នូវចិត្តគំនិត ។

សម្ភារៈវាកើតហើយ ខ្ញុំចូលបដិវត្តន៍ ខ្ញុំត្រូវចាត់ទុកមាតាបិតាខ្ញុំថាជាបុគ្គលម្នាក់ ជាគ្រួសារមួយដែលជាកម្មសិទ្ធរបស់បក្ស ។ ដូច្នេះហើយបានជាប្រាក់ខែខ្ញុំប្រាំពីរពាន់ ខ្ញុំអត់មានបានជូនមាតាបិតាខ្ញុំម៉ាគ្រាប់ទេ ខ្ញុំជូនបដិវត្តន៍ ជាងប្រាំពាន់ៗប្រាំពីររយ ខ្ញុំទុកតែមួយពាន់ប្រាំរយទេ ។

ខ្ញុំចង់ឲ្យមាតាបិតាខ្ញុំលោកស្រលាញ់បដិវត្តន៍ លោកចូលរួមធ្វើបដិវត្តន៍ ។ ខ្ញុំចង់ឲ្យប្អូនស្រីខ្ញុំទាំងបួននាក់ ចូលធ្វើបដិវត្តន៍ស្រលាញ់បដិវត្តន៍ដូចខ្ញុំ។ តែខ្ញុំគ្មានគោលគំនិតចាប់បង្ខំអ្នកណាឲ្យធ្វើតាមគំនិតខ្ញុំទេ ចង់ឲ្យគេភ្ញាក់រឭក ។ ដល់មកកូនខ្ញុំក៏ដូច្នោះ ដូចខ្ញុំបានជម្រាបអង្គសវនាការថ្ងៃមុនហើយ កូនខ្ញុំគឺជាកូនរបស់អង្គការ ត្រូវថ្នាក់ថ្នមវាដើម្បីបម្រើបដិវត្តន៍ នេះជាគោលគំនិតរបស់ខ្ញុំកាលនោះ ។

ទន្ទឹមនេះខ្ញុំសូមអនុញ្ញាតជម្រាបបញ្ជាក់ជូនលោកចៅក្រមថា ពាក្យមនុស្សដែលនិយាយថា “កូនជាកូនរបស់អង្គការ កូនត្រូវរាយការណ៍អំពីម៉ែឪជូនអង្គការ” ខ្ញុំមិនយល់ ខ្ញុំមិនដែលឮ ។

សរុបមកវិញ ខ្ញុំចូលធ្វើបដិវត្តន៍វាជាលក្ខខណ្ឌសម្ភារៈមួយ។ ចិត្តគំនិតខ្ញុំចង់ឲ្យវង្សត្រកូលខ្ញុំទាំងមូលស្រលាញ់បដិវត្តន៍ដែរ ជាលក្ខខណ្ឌខាងគំនិតដែលខ្ញុំមានពិតកាលនោះ ។

[១១:៣៩:៣៤]

**ស៖** លោកបានជម្រាបអង្គសវនាការថាលោកជាកូនច្បងនៅក្នុងចំណោមបងប្អូនប្រាំនាក់ ហើយលោកប្រាប់ថា នៅក្នុងគ្រួសារលោកចង់ឲ្យម្នាក់ចូលបដិវត្តន៍។ តើលោកអាចប្រាប់យើងបានទេថាតើមានប៉ុន្មាននាក់នៅក្នុងក្រុមគ្រួសាររបស់លោក ក្នុងចំណោមសាច់ថ្លៃ ឬក៏សាច់ខាងប្រពន្ធរបស់លោក? តើមានប៉ុន្មាននាក់នៅក្នុងគ្រួសារនោះ ដែលបានស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬក្នុងរយៈពេលក្រោយរបបនោះ តើលោកអាចប្រាប់ជាចំនួនអ្នកដែលស្លាប់នោះបានដែរឬទេ?

**ឆ៖** អរគុណលោកចៅក្រមដែលបានលើកបញ្ហានេះ ។ ប្អូនខ្ញុំម្នាក់ ប្អូនថ្លៃ មកស្លាប់នៅមន្ទីរស-២១ ឈ្មោះ កៅលី ផុងហួត មានឈ្មោះនៅក្នុងបញ្ជី *អេសថ្វិនធីវ័នព្រីសិនណឺលីស* ។ ឯចំណែកប្អូនថ្លៃខ្ញុំមួយទៀត បងពក គាត់ឲ្យគេលួចចាប់ហើយយកទៅសម្លាប់មិនឲ្យខ្ញុំដឹងឈ្មោះ សៀប សាខន។ ដូច្នេះ ក្នុងរយៈកាលពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ខ្ញុំអស់ប្អូនថ្លៃពីរនាក់ ។

ចំណែកខាងគ្រួសារខ្ញុំវិញ ខាងប្រពន្ធខ្ញុំ ប្រពន្ធខ្ញុំមានបងប្រុសម្នាក់ឈ្មោះ ជួប ត្រូវស័ក្តិ៤ ហេងដៃជើង លន់ នល់ សម្លាប់តាំងពីឆ្នាំ១៩៦៨ ។ គាត់ជាអ្នកលេងភ្លេងខ្មែរ ពួក លន់ នល់ ចាប់ពួកអ្នកលេងភ្លេងខ្មែរប្រាំពីរនាក់នោះ សម្លាប់ចោលហើយកប់រណ្តៅតែមួយ។ នេះជាសោកនាដកម្មមួយតូចនៅក្នុងឃុំពាម ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ នេះគឺសូមបញ្ជាក់ជូនប៉ុណ្ណោះ ។

ឯចំណែកក្រោយ ៧មករា ១៩៧៩ នៅពេលរត់ ។ នៅក្នុងពេលរត់មួយឆ្នាំនេះ ខ្ញុំស្តាប់អស់បុគ្គលិកចាស់ៗ ដែលធ្វើការជាមួយនឹងខ្ញុំយុទ្ធជនកម្មាភិបាល ដែលធ្វើការជាមួយខ្ញុំពី៧៥ រហូតដល់៧៩ ស្លាប់អស់ ។ ស្លាប់ប្អូនថ្លៃខ្ញុំម្នាក់ទៀត ប្អូនថ្លៃខ្ញុំប្រុសម្នាក់ទៀត។ ប្អូនថ្លៃប្រុសខ្ញុំម្នាក់ក៏ស្លាប់ ប្អូនស្រីខ្ញុំពីរនាក់ក៏ស្លាប់ ហើយក្មួយខ្ញុំប្រុសស្រីប្រាំមួយនាក់ក៏ស្លាប់ ។ រួមទាំងអស់រួមទាំងប្រពន្ធមិត្តប៉ុនផង រួមទាំងប្រពន្ធបង ម៉ម ណៃ ផង កូនមិត្តប៉ុនផង កូនបង ម៉ម ណៃ ផង ធ្វើឲ្យខ្ញុំវេទនាក្នុងចិត្តក្រៃលែង ។

ខ្ញុំសូមបញ្ចប់អំពីសោកនាដកម្មនៅចំពោះគ្រួសារខ្ញុំប៉ុណ្ណេះ ។

**ស៖** ដើម្បីសង្ខេបនូវអ្វីដែលលោកបានបញ្ជាក់នោះ លោកបាននិយាយបងពីរនាក់គឺ កៅលី ចុងហួត, សៀប សាខន ជាប្អូនថ្លៃរបស់លោក នេះជាប្តីពីររូបនៃប្អូនស្រីរបស់លោក ឬក៏ជាសាច់ថ្លៃខាងប្រពន្ធលោកនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! សៀប សាខន ជាប្តីរបស់ប្អូនស្រីខ្ញុំ ។ ប្អូនស្រីនេះកើតបន្ទាប់ខ្ញុំ ឯចំណែក កៅលី ចុងហួត ជាប្តីរបស់ប្អូនស្រីខ្ញុំទីពីរ ។ ដូច្នេះ រាប់ពីខ្ញុំទៅវាគឺទីបីហើយ ។ ហើយនៅពេលរត់នេះ រត់ប្តីរបស់ប្អូនស្រីរបស់ខ្ញុំម្នាក់ទៀតឈ្មោះ ពេជ្រ ជាប្អូនស្រីទីបីរបស់ខ្ញុំ បើរាប់ពីខ្ញុំទៅដល់ប្អូនស្រីនេះ គឺវាជាទីបួន ។ ដោយឡែក បងជួប ជាបងទីពីររបស់ប្រពន្ធខ្ញុំ ដែលស្លាប់នៅក្នុងឃុំពាម ។

**ស៖** បងឬក៏ប្អូនថ្លៃប្រុសរបស់លោក តើពួកគាត់នោះគោរពទៅតាមគោលការណ៍បដិវត្តន៍ដែរទេ? តើគេជាអ្នកបដិវត្តន៍ដែរ? ហើយហេតុអីបានជាគេត្រូវគេសម្លាប់? ហើយហេតុអ្វីបានជាគេចាប់បញ្ជូនគាត់មកស-២១? តើបញ្ហាអ្វីដែលកើតឡើងចំពោះគាត់? ហើយខ្ញុំសំដៅដល់ កៅលី ចុងហួត និង សៀប សាខន នោះ ។

[១១:៤៧:៤០]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ប្អូនថ្លៃទាំងពីររូបនេះចូលបដិវត្តន៍នៅឆ្នាំ១៩៧០គឺក្រោយរដ្ឋប្រហារ។ ដល់ក្រោយមកវាបានចូលបក្ស។ កៅលី ចុងហួត វាធ្វើការនៅមន្ទីរសន្តិបាលតំបន់កំពង់ធំ។ ដល់ក្នុងរវាងឆ្នាំ១៩៧៧ ខ្ញុំចាំមិនច្បាស់ទេ ស្រាប់តែឃើញសំបុត្រមួយវាលួចផ្ញើមកខ្ញុំដោយសម្ងាត់។ ខ្ញុំបានសំបុត្រនេះ ខ្ញុំរាយការណ៍សំបុត្រហ្នឹងទៅជូន សុន សេន ភ្លាម ។

បន្ទាប់មកបីថ្ងៃ ខ្ញុំឃើញប្អូនថ្លៃខ្ញុំប្អូនស្រីខ្ញុំបង្កើត ហើយនិងកូនប្រុសវាពីរនាក់មកដល់ផ្ទះខ្ញុំ ។ ខ្ញុំក៏ទុកទៅ ។ បន្ទាប់មក មួយថ្ងៃបន្ទាប់មកនោះ សុន សេន ហុចសំបុត្រមកបង្ហាញខ្ញុំ ហើយប្រាប់ថា ប្អូន

មកដល់ទុកទៅ ទុកឲ្យវានៅជាមួយនឹងទៅ ។ សំបុត្រដែល សុន សេន ដែលបង្ហាញមកខ្ញុំហ្នឹង មានសំបុត្របងពក គឺ កែ ពក លេខាភូមិភាគកណ្តាលហ្នឹង ។

[១១:៥០:00]

បងពក គាត់សរសេរថា "ខ្ញុំទើបតែនឹងដឹងថា កៅលី ថុងហួត នេះ គឺជាប្អូនថ្លៃរបស់ ឌុច ។ ឥឡូវនេះ ខ្ញុំសូមប្រគល់ជូនអង្គការ គឺវានូវឈ្មោះ កៅលី ថុងហួត ប្រពន្ធនិងកូន" ។ ខ្ញុំក៏ទុកប្អូនថ្លៃ ហើយនិងប្អូនបង្កើតដោយអត់ប៊ានប្រើចាត់តាំងឲ្យធ្វើអីទេ ។ បន្ទាប់មកប្រហែលជាពីរបីខែ សុន សេន គាត់ប្រាប់ ឈ្មោះ កៅលី ថុងហួត នេះ បងនួន គាត់ឲ្យសួរចម្លើយទៅ ។ ខ្ញុំដឹងៗថា គេឲ្យខ្ញុំចាប់ប្អូនថ្លៃ ខ្ញុំដាក់ខ្នោះ វាយសួរចម្លើយ ហើយកម្ទេចចោល ។ តែខ្ញុំមិនធ្វើអ៊ីចឹង ខ្ញុំឲ្យវាសរសេរចម្លើយធម្មតាដោយមិនដាក់ខ្នោះ ។ ខ្ញុំហុចចម្លើយហ្នឹងជូនទៅខាងលើតាមរយៈ សុន សេន ។ ប៉ុន្មានថ្ងៃក្រោយមកទៀត សុន សេន ផ្តៀតឱកាសស្តីឲ្យខ្ញុំ ។ នៅពេលជួបគ្នាតាមទូរស័ព្ទ គាត់ថាគ្រោះថ្នាក់ណាស់ណ៎ា ឌុច ដែលតាំងខ្លួនជាមនុស្សម្នាក់ហ្នឹងគេដែរន៎ែ ។

"តាំងខ្លួនជាមនុស្សម្នាក់" តើមានន័យថាម៉េច? បើសិនជាខ្ញុំប្រែវិញ ខ្ញុំសូមនិយាយថា "*ហ្សឺ កុងស៊ីដេរ៉េព្យែហ្គ អេតង់អង់នុង អ៊ែត្រែ ដង់ហ្សឺរ៉ឺ*" (និយាយភាសាបារាំង) ដើម្បីឲ្យមានមោទនភាពខ្លួនឯង គឺជាការគ្រោះថ្នាក់ណាស់ ។ ខ្ញុំក៏មិនធ្វើមាត់ ។ ដល់ក្រោយមកអា កៅលី ថុងហួត នេះធ្វើការខុសឆ្គងច្រើនទៀត ខ្ញុំទ្រាំមិនបាន ខ្ញុំថា បើទុកវាស្រួលមិនស្រួល គ្រោះថ្នាក់ទាំងខ្ញុំ ងាប់អស់មួយពូជ ។ ខ្ញុំក៏ឲ្យគេចាប់វាដាក់ខ្នោះ វ៉ៃសួរចម្លើយទៅ ហើយហៅប្អូនខ្ញុំបង្កើតមកប្រាប់ ។ នេះចំពោះបញ្ហា កៅលី ថុងហួត ខ្ញុំសូមបញ្ជាក់ជូនពេលនេះប៉ុណ្ណោះ ។

**ស៖** ខ្ញុំចង់ព្យាយាមយល់ពីរឿងរ៉ាវនេះឲ្យច្បាស់ជាងនេះ ។ ប៉ុន្តែ ខ្ញុំមិនទាន់ច្បាស់ទេកន្លែងនេះ។ ប្អូនប្រុសរបស់លោកធ្វើការឲ្យសន្តិបាលមួយ តើមុខងាររបស់គាត់ជាក់ស្តែងអ្វី? គាត់ជាប្រធាននៃមន្ទីរសន្តិសុខ ឬគាត់ជាអ្នកទទួលបន្ទុកកន្លែងហ្នឹង? តើគាត់មានការទទួលខុសត្រូវអ្វីជាក់លាក់ទេនៅកន្លែងនោះ? ហើយខ្ញុំចង់ដឹងផងដែរ ហេតុអីបានគាត់សរសេរសំបុត្រមកលោក? តើគាត់សរសេរមកមានន័យដូចម្តេច? តើគាត់ស្នើសុំឲ្យលោកជួយធ្វើអ្វីនៅពេលដែលគាត់មកទាំងកូនប្រពន្ធផងនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! កៅលី ថុងហួត នេះជាអនុប្រធាននៃមន្ទីរសន្តិបាលកំពង់ធំ ។ សំបុត្រដែលវាសរសេរមកឲ្យខ្ញុំ គឺវាសរសេរនៅពេលដែលគេចាប់វាដាក់គុកនៅកំពង់ធំរួចទៅហើយ ។ ហើយវាផ្ញើសំបុត្រនេះមកខ្ញុំដំបូងតាមអ្នកយាមគុករបស់វាហ្នឹងឯង ។ ហើយឲ្យយកមក

ឲ្យខ្ញុំតាមរយៈក្រសួងថាមពល បុគ្គលិកក្រសួងថាមពល ព្រោះក្រសួងថាមពលគេពង្រាយបុគ្គលិកគេពាសពេញប្រទេស ។ ហើយក្រសួងថាមពលនេះ គេឲ្យទៅមេគេ មេគេហុចមកឲ្យខ្ញុំ ។

[១១:៥៦:៣២]

**ស៖** ហេតុអ្វីបានជាប្អូនថ្លៃប្រុសរបស់លោកត្រូវបានគេចាប់ខ្លួន? តើគាត់បានប្រព្រឹត្តកំហុសអ្វីឬក៏មានបញ្ហាអ្វី?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ខ្ញុំអត់ប៉ានដេញដោលសួរមេ ហើយក៏មិនបានសួរវាដែរ ហើយផ្ទាល់ខ្លួនវាក៏ខ្ញុំអត់បានសួរដេញដោលដែរ ។

**ស៖** ពេលនោះ តើប្អូនថ្លៃប្រុសរបស់លោកបានសុំឲ្យលោកជួយអ្វី? ឬក៏ប្រាប់លោកអំពីរឿងអីខ្លះនៅក្នុងសំបុត្រនោះ?

**ឆ៖** សំបុត្រនេះវារាយការណ៍ប្រាប់ខ្ញុំថា ខ្ញុំត្រូវគេចាប់ដាក់មន្ទីរនគរបាលហើយ ហើយកំពុងតែមានជំងឺរាកមួលផង សូមបងជ្រាបជាព័ត៌មាន ។

**ស៖** អ៊ីចឹងប្អូនថ្លៃប្រុសរបស់លោកត្រូវបានគេចាប់ខ្លួន ហើយឃុំខ្លួននៅមន្ទីរសន្តិសុខមួយ តាមដែលខ្ញុំយល់នោះ ហើយបន្ទាប់មកលោកបាន-- ក្រោយមកបានឃើញប្អូនថ្លៃប្រុស ហើយនិងប្រពន្ធគាត់មកជួបលោក ។ នៅពេលដែលគេមកជួបលោកហ្នឹង តើគេជាអ្នកមានសេរីភាព? គេដោះលែងហើយឬក៏នៅក្នុងការឃុំខ្លួនរបស់គេនៅឡើយទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! វាមកដល់ពេលព្រលប់ៗប្រហែលជាម៉ោងប្រាំមួយជាង។ ប្អូនខ្ញុំវាស្រែក “បងអើយ! ខ្ញុំមកដល់ហើយ បងពក ឲ្យខ្ញុំមក អ៊ំពក ឲ្យខ្ញុំមក” ។ អត់មានអ្នកណាចងទេ ទាំងអស់គ្នារីករាយស្មានតែបានរួចខ្លួនហើយ ។

**ស៖** អ៊ីចឹងនៅពេលដែលគេមកកន្លែងរបស់លោក គឺថា ដោយថាអត់មានចងអត់មានអីទេ គឺថាគេអាចនឹងមកកន្លែងសុវត្ថិភាពដែលជាជម្រកមួយ ។ អ្វីដែលខ្ញុំយល់ពីលោកពីខាងដំបូងហ្នឹង ចាប់ពីពេលដែលគេមកដល់ហ្នឹង លោកបានរាយការណ៍ពីស្ថានភាពហ្នឹងទៅ សុន សេន ។ តើអ្វីជាកត្តាបង្ខំឲ្យលោកធ្វើការរាយការណ៍ហ្នឹង?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ប្អូនខ្ញុំហើយនិងប្អូនថ្លៃខ្ញុំដូចមិនទុកកន្លែងជាកន្លែងលាក់ខ្លួនទេ ។ គ្នាជឿថា បក្សឲ្យមកនៅជាមួយនឹងខ្ញុំវិញ នេះជាបញ្ហាមួយ ។ ឯចំណែកបញ្ហាទីពីរ ខ្ញុំសូមបញ្ជាក់ថា ក្នុងផ្ទៃបក្សរឿងអីក៏ដោយ យើងកើតទុក្ខយ៉ាងម៉េចក៏ដោយ ត្រូវរាយការណ៍ប្រាប់មេ ឲ្យមេ

ដោះស្រាយ ។

ដូច្នេះ ខ្ញុំបានទទួលសំបុត្រពីប្អូន ខ្ញុំធ្វើដីកាអមមួយ លិខិតអមមួយជូនទៅមេខ្ញុំ ឲ្យគាត់ដោះស្រាយ ឲ្យគាត់ជ្រាប ។ មិនមែនឲ្យគាត់ដោះស្រាយទេ ឲ្យគាត់ជ្រាប ។

[១២:០០:៤៩]

**ស៖** នៅពេលដែលលោកធ្វើដូច្នោះ ថាតើលោកស្ថិតនៅក្រោមការគាបសង្កត់ ឬក៏សម្ពាធណាមួយដែរឬទេ ដែលលោកអាចធ្វើឲ្យស្ថានភាពប្អូនថ្លៃប្រុសរបស់លោកកាន់តែរឹតរវើឡើង? ឬក៏លោកគិតថា វាធ្វើឲ្យស្ថានភាពហ្នឹងល្អជាងហ្នឹង?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ជាសាច់ ជាឈាម កាត់អត់ដាច់ទេ ហើយការខុសឆ្គងរបស់ប្អូនមិនដឹងជាស្អីផង ។ ខ្ញុំមិននៅព្រងើយកន្តើយទេ ។ ក៏ប៉ុន្តែ វិធីដែលយើងខ្ញុំអាចដោះស្រាយបានមានតែប៉ុណ្ណឹង រាយការណ៍ឲ្យមេជ្រាប ថាឥឡូវប្អូនថ្លៃវាបានសរសេរសំបុត្រមកអ៊ីចេះ ឥឡូវខ្ញុំសូមជូនសំបុត្រនេះជូនបង សូមបងជ្រាបជាព័ត៌មាន ។

**ស៖** លោកទទួលលិខិតមួយច្បាប់ពីប្អូនថ្លៃប្រុសរបស់លោក។ ថាតើគាត់ឲ្យលោកជួយគាត់នៅក្នុងស្ថានភាពលំបាក ដែលគាត់ជាប់ឃុំ ឬក៏យ៉ាងម៉េច? ហើយលោកអត់ដឹងថា គាត់ត្រូវជាប់ឃុំដោយរបៀបណា? ហើយវាហាក់ដូចលោកធ្វើការយ៉ាងសាមញ្ញ រាយការណ៍បញ្ហានេះទៅដល់មេរបស់លោក ថាតើលោកយល់យ៉ាងម៉េច? តើលោកសន្និដ្ឋានយ៉ាងម៉េចពីលិខិតរបស់ប្អូនថ្លៃប្រុសរបស់លោកនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! បក្ខជនម្នាក់ៗ អត់មានសិទ្ធិអីទៅតវ៉ានឹងខាងលើ ម៉េចបានចាប់បុគ្គលនេះទេ នេះជាក្រឹត្យក្រមធម្មតា ។ ទុក្ខវេទនាវាធ្លាក់មកដល់គ្រួសារខ្ញុំហើយ ខ្ញុំត្រូវតែដោះស្រាយ ។ មានតែខ្ញុំទេជាបង្គោលគ្រួសារដែលមានលទ្ធភាពដោះស្រាយបញ្ហានេះ ។ ហើយវិធីដោះស្រាយមានតែប៉ុណ្ណឹង គឺភ្ជាប់សំបុត្រវា ហើយនិងសំបុត្រខ្ញុំរាយការណ៍ជូនមេ ឲ្យមេជ្រាប ។ នេះគឺជាក្រឹត្យក្រមដែលយើងខ្ញុំដំណើរការក្នុងការដោះស្រាយទុក្ខសោកផ្ទាល់ខ្លួនក្នុងគ្រួសារអ៊ីចឹង ។

**ស៖** ខ្ញុំហាក់ដូចជាមិនយល់ច្បាស់ចំពោះខ្ញុំ ។ ខ្ញុំចង់ដឹង ហេតុអ្វីបានជាប្អូនថ្លៃរបស់លោក ត្រូវបានគេចាប់ខ្លួន? ហេតុអ្វីគេធ្វើទារុណកម្មគាត់? លោកនិយាយថា គេធ្វើទារុណកម្មគាត់ ហើយហេតុអ្វីបានជាគាត់ស្លាប់? ថាតើប្អូនថ្លៃប្រុសរបស់លោកនោះបានធ្វើអ្វីខ្លះតាមក្រសែភ្នែករបស់បក្ស ដែលទទួលទណ្ឌកម្មបែបនោះ?

[១២:០៤:៤៧]

**ឆៈ** ជម្រាបប្រសាសន៍លោកចៅក្រម! សេចក្ដីសម្រេចរបស់បក្ស មានអំណាចណាស់ មិនអាចអ្នកណាទប់បានទេ ។ បងពក គឺ កែ ពក គាត់ជាលេខាភូមិភាគកណ្ដាល ។ គាត់មានសិទ្ធិសម្រេចចាប់អ្នកណា ទុកអ្នកណា ឱ្យអ្នកណារស់ ឱ្យអ្នកណាស្លាប់ ។ សេចក្ដីសម្រេចចិត្តថ្ងៃ៣០ មីនា១៩៧៦ ជាភស្តុតាងស្រាប់ ។ ខ្ញុំជាបក្ខជនធម្មតាអត់មានសិទ្ធិតវ៉ាទេ ។ សុន សេន ឬក៏ ប៉ុល ពត និយាយឱ្យចំទៅទៀតនោះ ប៉ុល ពត ក៏មិនឱ្យ កែ ពក បាក់មុខក្នុងរឿងសម្រេចបញ្ហាមួយហ្នឹងដែរ ។ និយាមដែល ប៉ុល ពត ប្រគល់ឱ្យ កែ ពក គឺនិយាមថ្ងៃ៣០ មីនា ១៩៧៦ នេះ ។

សូមបញ្ជាក់ថា សេចក្ដីសម្រេចថ្ងៃ៣០ មីនា ១៩៧៦ វាជានិយាមដែលបាវាំងគេហៅថា *ឡាណាម* ។ ដូច្នេះ កែ ពក គេមានសិទ្ធិសម្រេច ប៉ុល ពត ប្រគល់សិទ្ធិឱ្យគេសម្រេច ។ កែ ពក មានសិទ្ធិសម្រេច ប៉ុល ពត អត់ប៊ានធ្វើអីឱ្យគេក្នក់ចិត្ត ឬក៏គេទាល់ចិត្តទេ ព្រោះនិយាមនេះៗ ប៉ុល ពត ខ្លួនឯងប្រគល់ឱ្យរួចទៅហើយ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំគិតថា យើងអាចឈប់នៅទីនេះសិន ដើម្បីយើងឈប់សម្រាក ហើយញ៉ាំអាហារថ្ងៃត្រង់ ហើយបន្ទាប់មកយើងអាចតសំណួររបស់យើងបន្ថែមទៀត ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់ពេលត្រូវពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាថ្ងៃត្រង់ ហើយរហូតដល់ម៉ោងមួយកន្លះ យើងចាប់បន្តដំណើរការនីតិវិធីសវនាការរបស់យើងទៅទៀត ។

អនុរក្សមន្ទីរឃុំឃាំង ឱ្យនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ ហើយឱ្យនាំគាត់មកកាន់សាលសវនាការវិញ ឱ្យបានមុនម៉ោងមួយនិងសាមសិបនាទី ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១២:០៨នាទី ដល់ម៉ោង ១៣:៣៧នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។ ហើយនៅរសៀលនេះយើងនឹងធ្វើសវនាការដោយស្ដាប់នូវសក្ខីកម្មរបស់អ្នកជំនាញ ស្ដេហ្វិន ហាស្ទែល ដោយការចូលរួមពីចម្ងាយ ។ ខាងផ្នែកសោតទស្សន៍សូមភ្ជាប់ប្រព័ន្ធវីដេអូ ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកអ្នកជំនាញ! តើនាមត្រកូល និងនាមខ្លួនរបស់អ្នកជំនាញ ឈ្មោះ ស្តេហ្វិន ហាស្បែល អ៊ីចឹងពិតមែនដែរឬទេ?

**ឆ៖** បាទ, លោកប្រធាន មែន ។

(លោកប្រធាន តើលោកស្តាប់យើងខ្ញុំឮដែរឬទេ?)

**ស៖** បាទ, ខ្ញុំស្តាប់ឮហើយ ។ តើលោកអ្នកជំនាញមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ខ្ញុំមានអាយុ ៩១ឆ្នាំ ហើយនិង ៦ខែ ។

**ស៖** តើលោកអ្នកជំនាញមានទីលំនៅសព្វថ្ងៃនៅទីកន្លែងណា?

**ឆ៖** អាសយដ្ឋានបច្ចុប្បន្នរបស់ខ្ញុំ គឺនៅទីក្រុងប៉ារីស នៅផ្លូវ-- នៅសង្កាត់ទី១៤ ផ្ទះលេខ៦ ផ្លូវអាំងទ័រហ្សាតាំង ។

**ស៖** តើលោកអ្នកជំនាញ តើលោកមានចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងភាគីនៃរឿងក្តី ដែលអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក កំពុងតែដំណើរការនេះដែរឬទេ?

**ឆ៖** ទេ, មិនមានទេ លោកប្រធាន ។

**ស៖** ក្នុងនាមលោកជាអ្នកជំនាញ អង្គជំនុំជម្រះតម្រូវការឲ្យលោកធ្វើសម្បថនៅចំពោះមុខអង្គជំនុំជម្រះមុននឹងផ្តល់សក្ខីកម្មពីភាពជំនាញរបស់លោក តើលោកយល់ព្រមដែរឬទេ?

**ឆ៖** បាទ, លោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជី កញ្ញា ណាតាចា រៀបចំឲ្យលោក ស្តេហ្វិន ហាស្បែល ធ្វើសម្បថតាមជំនឿសាសនារបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះ ។

**កញ្ញា ណាតាចា វីស៊ែល វីសឺ៖**

សូមជម្រាបសួរលោកប្រធាន! ហើយខ្ញុំនឹងអានសម្បថជាភាសាបារាំង ហើយសូមថាតាមខ្ញុំនីមួយៗ ។ ខ្ញុំសូមស្បថថា នឹងសហការជួយដល់អង្គជំនុំជម្រះដោយស្មោះត្រង់ រក្សាការសម្ងាត់ និងខិតខំប្រឹងប្រែងឲ្យអស់ពីសមត្ថភាពរបស់ខ្ញុំ ។

[១៣:៤២:២៧]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ អង្គជំនុំជម្រះប្រគល់ភារៈទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីតាំងសំណួរដាក់លាក់ចំពោះអ្នកជំនាញរូបនេះ ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន ។

**ស៖** សូមជម្រាបសួរលោក ហាស្សែល! ខ្ញុំចៅក្រម ឡាវែន៍ ហើយខ្ញុំចង់ពន្យល់លោកមុនពេលនឹងស្តាប់សក្ខីកម្មរបស់លោកគឺថា គឺជាទម្លាប់របស់អង្គជំនុំជម្រះ ដើម្បីសួរបញ្ហាមួយចំនួនទាក់ទងទៅនឹងជីវប្រវត្តិរបស់លោក ដែលអាចធ្វើឱ្យអង្គជំនុំជម្រះអាចកំណត់បានថា លោកមានសមត្ថភាពនៅក្នុងការផ្តល់សក្ខីភាពដល់អង្គជំនុំជម្រះ ។ ហើយខ្ញុំពិនិត្យមើលឃើញថា លោក មានអាជីពយូរជាងអ្នកការទូត ហើយប្រហែលជាលោកនៅតែមានជាអគ្គរដ្ឋទូត ។

**ឆ៖** បាទ, ពិតហើយខ្ញុំនៅតែជាអគ្គរដ្ឋទូត ។

**ស៖** ហើយលោកគឺជាអតីតអ្នកតស៊ូបារាំងមួយ ហើយលោកត្រូវបានចាប់ខ្លួនដោយ *កេស្តាប៉ូ* ហើយបានបញ្ជូនទៅជំរំឃុំខ្លួន ហើយលោកបានចូលរួមជាមួយការកែន-- ក្នុងការរៀបចំសេចក្តីប្រកាសជាសាកលនៃសិទ្ធិមនុស្សឆ្នាំ១៩៤៨ ហើយលោកបានធ្វើការជាមួយនឹង *រ៉ឺណេកាស្សាំង* ។ ហើយខ្ញុំបានបន្ថែមថា លោកនៅតែមានសកម្មភាពនៅឡើយ ហើយលោកជាសមាជិកនៃអាជ្ញាធរជាន់ខ្ពស់មួយនៅប្រទេសបារាំង ហើយដែលលោកបានធ្វើសេចក្តីប្រកាស ហើយនិងចូលរួមជាច្រើនឆ្នាំ ។

លោក ហាស្សែល លោកត្រូវបានកោះអញ្ជើញតាមសំណើរបស់មេធាវីការពារថា ជាអ្នកសាក្សីជំនាញ ។ មេធាវីការពារបានចង្អុលបង្ហាញថា ក្នុងសមត្ថភាពរបស់លោកគឺជាអតីតសមាជិកនៃអ្នកតស៊ូដែលត្រូវបានគេជម្លៀស ។ ហើយក្រោយមកបានធ្វើការទៅឱ្យអង្គភាពមួយខាងផ្សះផ្សាជាតិបារាំង-អាល្លឺម៉ង់ ហើយដែលទាក់ទងទៅនឹងបញ្ហាការលើកលែងទោស ឬក៏ការអភ័យទោស ។ ហើយខ្ញុំនឹងជូនវេទិកាទៅឱ្យលោក ហើយនិងនិយាយអំពីបញ្ហាបទពិសោធន៍នៃការលើកលែងទោស ឬក៏ការអភ័យទោស ដែលទាក់ទងទៅនឹងរឿងក្តីដែលយើងកំពុងតែពិចារណានៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ថាតើក្នុងរបៀបណាមួយដែលជាបទពិសោធន៍ ដែលអាចមានប្រយោជន៍ដល់យើងខ្ញុំនៅក្នុងដំណើរការនីតិវិធី ដែលយើងកំពុងតែដំណើរការ? ឥឡូវនេះ ខ្ញុំជូនវេទិកាទៅលោក ។

[១៣:៤៦:០៥]

**ឆ៖** លោកចៅក្រម! គឺជាការភ្ញាក់ផ្អើលមួយដែលឮពាក្យហ្នឹង ។ ប៉ុន្តែ ខ្ញុំរីករាយនឹងឆ្លើយឲ្យបានត្រឹមត្រូវតាមដែលខ្ញុំអាចធ្វើបានទៅតាមសំណួរ ។ តាមពិត ខ្ញុំបានធ្វើជាសាក្សីនូវសកម្មភាពនៃការជំនុំជម្រះនៅនូរីមប៊ឺក ដែលបន្ទាប់ពីនៅចុងសង្គ្រាមលោកលើកទីពីរបានព្យាយាមធ្វើការកាត់ទោសឧក្រិដ្ឋជនរបបណាហ្ស៊ី ។ នៅពេលនោះខ្ញុំគិតថា ការជំនុំជម្រះបែបនោះ អាចធ្វើឲ្យមានលទ្ធភាពមួយ ដើម្បីឲ្យសម្រេចបាននូវការកសាងឡើងវិញនូវទំនាក់ទំនងរវាងប្រទេសនានា ដែលរួចចេញផុតពីសង្គ្រាមលោកលើកទី២ ជាអ្នកទទួលជ័យជម្នះ ហើយមិនមែនជាអាល្លឺម៉ង់ ដែលជាអ្នកទទួលបរាជ័យដ៏ធ្ងន់ធ្ងររបស់ភាគីផ្សេង ។ ហើយខ្ញុំគិតថានេះជាចំណុចចាប់ផ្ដើមមួយ ។ គឺការចាប់ផ្ដើមនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិដែលនៅកាលនោះមិនទាន់បានរកឃើញនូវអត្ថបទ ឬក៏លិខិតុបករណ៍អន្តរជាតិ ដែលតុលាការនោះអាចយកទៅប្រើសម្រាប់ជាគោលការណ៍ណែនាំទៅអនាគតនោះទេ ដើម្បីនឹងធ្វើការជំនុំជម្រះបុគ្គលមួយចំនួនដែលជាអ្នកមានពិរុទ្ធភាពអំពីបទឧក្រិដ្ឋសង្គ្រាម ប្រល័យពូជសាសន៍ ហើយនិងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ។

ខ្ញុំពិនិត្យឃើញថា ហេតុការណ៍ទាំងអស់នោះដែលបានកើតនៅកម្ពុជា អ្វីដែលយើងពិភាក្សាថ្ងៃនេះ គឺជាចរិតលក្ខណៈដ៏ជាក់ស្ដែងនៃបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ហើយយើងត្រូវតែកំណត់ថាតើការជំនុំជម្រះដូចកាលជំនុំជម្រះ ដែលលោក លោកស្រីចៅក្រម កំពុងដំណើរការហើយ និងការកាត់ទោស ឬក៏សាលក្រម ដែលបម្រុងនឹងចេញនោះវានឹងមានអនុភាពដូចគ្នាចំពោះការស្វែងទៅរកនូវការកសាងជាតិ ប្រទេសជាតិកម្ពុជាឡើងវិញ ។ ដោយសារនោះ គឺជាករណីដែលថា ការងារមួយរបស់សាលាក្ដីនូរីមប៊ឺក នោះ ដែលវាមានវិភាគទានដល់ការផ្សះផ្សាទំនាក់ទំនងរវាងអាល្លឺម៉ង់ ហើយនិងប្រជាជាតិ ដែលទទួលជ័យជម្នះនៅកាលនោះ ។

[១៣:៤៩:៣៤]

នៅក្នុងន័យនេះដែរ សាលក្រមដែលអង្គជំនុំជម្រះរបស់អស់លោក លោកស្រី នឹងចេញនោះ គឺនឹងមានលក្ខណៈឯករាជ្យទាំងស្រុង ហើយផ្អែកទៅលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ។ សាលក្រមនេះអាច ប្រសិនបើការប្រព្រឹត្តទៅនៃនីតិវិធីធានាដល់សិទ្ធិទូទៅ ឬសិទ្ធិរបស់ជនជាប់ចោទ អាចជាផ្លូវមួយជាការកែលម្អនូវទំនាក់ទំនងរវាងពលរដ្ឋកម្ពុជាទាំងអស់ ។

**ស៖** សូមអរគុណលោក ហាស្ស៊ែល តាមដែលដែលខ្ញុំយល់បើសិនជាមិនខុសទេនោះ លក្ខខណ្ឌទី១គឺថាការជំនុំជម្រះគឺត្រូវតែការជាជំនុំជម្រះប្រកបដោយយុត្តិធម៌ ។

**ឆ៖** ត្រឹមត្រូវហើយ ។

**ស៖** ក្រៅពីហ្នឹង ឬលើសពីហ្នឹងទៅទៀត ដោយសារសក្ខីភាពរបស់លោកអាចនឹងនិយាយអំពីស្ថានភាពនៃការខមាទោស អភ័យទោស តើលោកគិតថា-- កាលណាយើងចូលទៅដល់បញ្ហានេះគឺវាមានរៀនមួយចំនួនដែលយើងអាចដកស្រង់ពីបទពិសោធន៍របស់លោកដែរឬទេ?

**ឆ៖** បាទ, ខ្ញុំនឹងចាប់ផ្ដើមដោយនិយាយថា ពាក្យថា "ខមាទោស ឬអភ័យទោស" នោះ គឺអាចអនុវត្តចំពោះតែករណីទាំងឡាយ ឬក៏ជនទាំងនោះដែលជាជនរងគ្រោះនៃអំពើដ៏រន្ធត់ ដែលថាស្លាកស្នាមដែលនៅសេសសល់នៅក្នុងប្រវត្តិសាស្ត្រកម្ពុជានោះជិតដាមដោយអំពើនោះ ដែលថាជនរងគ្រោះកម្ពុជាត្រូវតែអនុវត្ត ត្រូវតែពិនិត្យមើលបញ្ហាមួយចំនួនទាក់ទងទៅនឹងពិរុទ្ធភាពដែលនឹងកំណត់ដោយសាលក្រមដែលនឹងត្រូវចេញ ។ ថាតើគេមានអាកប្បកិរិយាថាគេនឹងបដិសេធនៃប្រភេទណាមួយនៃការខមាទោសដែលស្ថិតនៅក្នុងសិទ្ធិរបស់គេ ឬក៏គេពិចារណាថាសាលក្រមនឹងត្រូវបានចេញដែលអនុញ្ញាតឱ្យពួកគេក្នុងឋានៈជាជនរងគ្រោះ ដើម្បីបំភ្លេច ឬក៏ជម្នះលើការឈឺចាប់របស់គេ ហើយឲ្យគេចាប់ផ្ដើមឡើងវិញនូវទំនាក់ទំនងមិត្តភាព ទំនាក់ទំនងរាប់អានគ្នារវាងជនរួមជាតិទាំងអស់របស់គេបាន ។ ក្នុងន័យនេះដែរគឺធ្វើឲ្យស្ថានការណ៍មួយធ្វើទៅបានបន្ទាប់ពីការជំនុំជម្រះនៅទួរីមប៊ឺក គឺរវាងអ្នកឈ្នះហើយនិងអ្នកដែលបរាជ័យ ឬក៏ជនរងគ្រោះនៃសង្គ្រាមលោកលើកទីពីរ ។

[១៣:៥៣:២០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោក ហាស្បែល ខ្លួនខ្ញុំផ្ទាល់មិនមានសំណួរអ្វីទៀតជូនលោកទេ ។ ខ្ញុំគិតថា ខ្ញុំប្រគល់វេទិកាទៅលោកចៅក្រម ឬក៏សហព្រះរាជអាជ្ញាដើម្បីបន្ត ។

**ប្រធានអង្គជំនុំ៖**

អស់លោកលោកស្រីចៅក្រមមានសំណួរអ្វីទេ? បើមិនមានទេ អង្គជំនុំជម្រះសូមប្រគល់វេទិកានេះទៅសហព្រះរាជអាជ្ញា ដើម្បីមានឱកាសសួរសំណួរដល់អ្នកជំនាញរូបនេះ ហើយអង្គជំនុំជម្រះសូមជម្រាបថា សហព្រះរាជអាជ្ញាមានពេលវេលាដប់នាទី ក្នុងការសួរសំណួរទៅអ្នកជំនាញរូបនេះ ។ សូមអញ្ជើញ ។

[១៣:៥៤:១០]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក តាន់ សេណារ៉ុង៖**

អរគុណលោកប្រធានអង្គជំនុំជម្រះ ។ ខ្ញុំសូមស្វាគមន៍លោក ហាស្បែល ។

**ស៖** សំណួរទីមួយរបស់ខ្ញុំជូនលោកនៅពេលនេះ មានដូចខាងក្រោម--

**លោក ស្តេហ្វិន ហាស្បែល៖**

**ឆ៖** សូមជម្រាបសួរលោកសហព្រះរាជអាជ្ញា ។

**លោក តាន់ សេណារ៉ុង៖**

អរគុណលោកដែលបានអញ្ជើញមកផ្តល់ចម្លើយនៅថ្ងៃនេះ ។

**ស៖** សំណួរទីមួយរបស់ខ្ញុំជូនលោកមានដូចខាងក្រោម៖

ក្នុងនាមលោកដែលធ្លាប់បានធ្វើជាអ្នកផ្សះផ្សា ដើម្បីរកសន្តិភាពនោះ តើលោកអាចផ្តល់ដំបូន្មានអ្វីខ្លះដល់ជនជាប់ចោទ និងជនរងគ្រោះនៅក្នុងរបបខ្មែរក្រហមនោះ?

**ឆ៖** ខ្ញុំមិនយល់ច្បាស់ តើខ្ញុំត្រូវមានឱវាទ ឬក៏យោបល់អ្វី ប៉ុន្តែខ្ញុំ ខ្លួនខ្ញុំយល់ឃើញថា អ្វីដែលជាកត្តាសំខាន់នោះ គឺដំណើរការនីតិវិធីដូចដែលមានដំណើរនៅក្នុងតុលាការ ។ ហើយម្យ៉ាងវិញទៀត គឺថាខាងអយ្យការ ហើយនិងខាងមេធាវីការពារត្រូវតែមានលទ្ធភាពពេញលេញដើម្បីធ្វើការងាររបស់ខ្លួន ហើយមួយទៀតជនរងគ្រោះក៏ត្រូវមានលទ្ធភាពដើម្បីប្រមូលនូវការយល់ដឹង ចំណេះដឹងអំពីអង្គហេតុទាំងឡាយដែលប៉ះពាល់ទៅលើពួកគេផ្ទាល់ផង ហើយអំពីអ្វីៗដែលអង្គជំនុំជម្រះដែលបញ្ជាក់អំពីការរកឃើញទាំងឡាយរបស់ខ្លួន ។

[១៣:៥៦:៥៧]

**ស៖** អរគុណលោក ហាស្បែល ។ សំណួរទីពីរជូនលោក ។ ឆ្លងកាត់តាមបទពិសោធន៍ដែលលោកធ្លាប់ជាប់ឃុំឃាំងនៅក្នុងសម័យសង្គ្រាមនោះ ហើយលោកក៏អ្នកធ្លាប់ធ្វើជាអ្នកសម្របសម្រួលសំណួរសួរថាតើលោកយល់ថា អ្នករងគ្រោះអាចទទួលបាននូវការសូមទោសពីជនដែលប្រព្រឹត្តបទល្មើសដែរឬទេ? ប្រសិនបើជនប្រព្រឹត្តបទល្មើសនោះមិនព្រមនិយាយការពិត និងមិនព្រមបង្ហាញពីការទទួលខុសត្រូវរបស់ខ្លួនទេនោះ?

**ឆ៖** ពាក់ព័ន្ធនឹងបញ្ហានេះ ខ្ញុំមានសេចក្តីរីករាយក្នុងការកត់សម្គាល់ថា សាលាក្តីរបស់លោកគឺកំពុងតែព្យាយាមផ្តែកទៅលើការងាររបស់អយ្យការ ហើយក៏ផ្អែកលើមូលដ្ឋានរបស់មេធាវីការពារផងដែរ ។ ដើម្បីនាំមកនូវអ្វីៗគ្រប់យ៉ាងដែលអាចនាំឲ្យចៅក្រមអាចនឹងចេញសាលក្រមមួយដែលវាមាន

លក្ខណៈរឹងមាំគ្រប់គ្រាន់ផ្អែកទៅលើអង្គហេតុដែលថា ជនជាប់ចោទបានទទួលស្គាល់ពិរុទ្ធភាពរបស់គាត់។ តាមធម្មតាមិនមានលក្ខណៈគ្រប់គ្រាន់ ដើម្បីធានាថាជនរងគ្រោះអាចនឹងអភ័យទោសឲ្យគាត់នោះទេ ។ ប៉ុន្តែវាអាចមានន័យថាជាការនាំឲ្យឈានទៅដល់ការពិចារណាដែលបានផ្តល់បញ្ជូនទៅដល់អ្នកទាំងនោះ ជាពិសេសទៅអតីតកាលហើយនិងអនាគតរបស់គេខាងមុខ ។ នៅក្នុងការផ្តល់ការសំអាងហេតុ ឬក៏បញ្ជាក់ហេតុផលរបស់ចៅក្រមនានានោះ ។

[១៣:៥៩:៥៨]

**លោក តាន់ សេណារ៉ុង៖**

សូមអរគុណលោក ហាស្នែល ខ្ញុំអស់សំណួរដើម្បីនឹងសួរទៅលោកទៀតហើយ និងបង្វែរសំណួរបន្ទាប់ទៅជូនសហការីអន្តរជាតិរបស់ខ្ញុំ ។ អរគុណលោកប្រធានអង្គជំនុំជម្រះ ។

**សួរដោយលោក វាំងសង់ វ៉ាយជ៍ ដេស្សាងលេ៖**

**ស៖** លោក ហាស្នែល ជាបឋមខ្ញុំសូមជម្រាបលោកថា ខ្ញុំមានកិត្តិយសណាស់ដែលបានសួរសំណួរទៅកាន់អតីតសមាជិកនៃអ្នកតស៊ូ និងបុគ្គលដែលមកនូវសន្តិភាពសម្រាប់ប្រទេសគេមួយនោះ ហើយខ្ញុំមានសំណួរតែមួយចំនួនតិចតែប៉ុណ្ណោះ ។

ខ្ញុំចង់សួរទៅកាន់លោកថា តើមានដំណាក់កាលប៉ុន្មាន? ហើយវាមានការប្រឈមប៉ុនណាដែរ ដែលវានាំទៅដល់ការផ្សះផ្សាជាតិនៅក្នុងប្រទេសមួយដូចនៅក្នុងប្រទេសកម្ពុជា លោកបានលើកឡើងអម្បាញ់មិញអំពីតួនាទីរបស់ការជំនុំជម្រះនៅគ្រប់ដំណាក់កាលទាំងអស់? សូមអរគុណ ។

**ឆ៖** ខ្ញុំគិតថា អ្វីដែលយើងបានជួបប្រទះនិងមើលឃើញនៅទីនេះ គឺមានការវិវត្តន៍ដ៏ធំធេងមួយនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។ ដូច្នេះ យើងត្រូវតែទាញយកបទពិសោធន៍ទាំងឡាយមកពីអតីតកាលដែលបានកន្លងផុតទៅប៉ុន្មានឆ្នាំក្រោយនេះ ដើម្បីធ្វើយ៉ាងណាធានាថាយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិវាដើរតួនាទីនៅក្នុងការកសាង និងដើម្បីឲ្យប្រជាជនគាត់បានដឹងអំពីការភ័យខ្លាចដែលបានកើតឡើង ។ អតីតកាលទាំងអស់នេះធ្វើយ៉ាងណាឲ្យស្វែងរក ហើយមិនឲ្យមានការប៉ះពាល់នឹងអត់ខិនទៅលើបុគ្គលដែលទទួលខុសត្រូវទៅលើព្រឹត្តិការណ៍ទាំងអស់នេះ ។ ប៉ុន្តែក្រៅតែពីចំណុចនេះ ដំណើរការជំនុំជម្រះរបស់តុលាការគួរតែមានអនុភាពដែលវាអាចប្រៀបប្រដូចនូវអ្វីដែលគេធ្លាប់បានធ្វើនៅប្រទេសផ្សេងៗទៀត។ បានន័យថា នៅប្រទេសគេ គេមានការបង្កើតទៅលើគណៈកម្មការស្វែងរកការពិត និងបទឈប់បាញ់គ្នាដូចដែលខ្ញុំបានលើកឡើងករណីនៅប្រទេសអាហ្វ្រិកខាងត្បូង ។

ចំណុចទាំងអស់នេះខ្ញុំចង់មានន័យថា ដើម្បីអាចឲ្យយើង-- ជាពិសេសប្រជាជនដែលគាត់ជាជនរងគ្រោះនៃរបបដ៏តក់ស្លុតទាំងអស់នេះ ។ ដើម្បីឲ្យពួកគាត់អាចបន្តនូវការទទួលបាននូវជីវិតសន្តិភាពរបស់គាត់នាពេលអនាគតនៅក្នុងប្រទេសរបស់ពួកគាត់ ។

[១៤:០៣:៤១]

ជាពិសេស នៅក្នុងបរិបទនៃប្រទេសដែលចារីមួយចំនួនបានប្រព្រឹត្តឧក្រិដ្ឋកម្ម ហើយនិងបរិបទទាំងឡាយដែលវាកើតឡើងមានចំពោះជនរងគ្រោះ ។ ដូច្នេះ ចំណុចទាំងអស់នេះ គឺវាមានការពិបាកណាស់ ប៉ុន្តែការងារទាំងអស់នោះក៏វាមានសារសំខាន់ផងដែរ ។ ខ្ញុំយល់ឃើញថា ទស្សនទាននៃការខមាទោស ឬការអត់ឱនទោស គួរតែពិចារណាឲ្យបានត្រឹមត្រូវតាមដែលតុលាការអាចធ្វើទៅបាន ។ យើងមិនអាចអនុវត្តបានទេ ប្រសិនបើវាមិនត្រឹមត្រូវ ។ ខ្ញុំនិយាយអំពីការងារនិងស្នាដៃរបស់ទស្សនវិទូមួយរូបដែលមានឈ្មោះ ប៉ូល រីហ្គ័រ ដែលស្នាដៃរបស់គាត់ និងការលើកឡើងរបស់គាត់មានសារសំខាន់ទៅដល់ភាគីទាំងឡាយដែលជាប់ពាក់ព័ន្ធនៅក្នុងនេះ យើងត្រូវពិចារណា ។

**ស៖** ខ្ញុំសូមអរគុណ ។ សំណួរទីពីរ ។ តើលោកយល់ស្របដែរឬទេ ថាប្រសិនបើខ្ញុំនិយាយថាការផ្សះផ្សាជាតិនៅក្នុងប្រទេសកម្ពុជា គឺជាផ្លូវមួយដ៏វែងឆ្ងាយដែលយើងត្រូវធ្វើដំណើរ ហើយយើងត្រូវតែគិតថាវាភាពចាំបាច់ក្នុងការពាក់ព័ន្ធទៅនឹងការបញ្ចប់នូវនិទ្ទណ្ឌភាព និងការស្វែងរកការពិត ហើយវាមិនគ្រប់គ្រាន់នោះទេ បើសិនយើងបំភ្លេចអតីតកាលរបស់យើង ។

[១៤:០៥:២៨]

**ឆ៖** ខ្ញុំយល់ស្របទៅលើចំណុចនេះទាំងស្រុងតែម្តង ដូចដែលសហព្រះរាជអាជ្ញាបានលើកឡើង។ និទ្ទណ្ឌភាពគឺយើងមិនអាចទទួលយកបាននោះទេ ។ ហើយដំណើរការផ្សះផ្សាជាតិយើងមិនត្រូវធ្វើយ៉ាងណាស្វែងរកក្នុងភាពតក់ក្រហល់នោះទេ ទោះបីករណីណាក៏ដោយ ។ ដំណើរការផ្សះផ្សាជាតិគួរតែមានការពាក់ព័ន្ធគ្នានឹងការបំភ្លឺទៅលើការឈឺចាប់ទាំងឡាយដែលបានធ្វើការឡើងចំពោះប្រជាជន។

**ស៖** សូមអរគុណ ។ ខ្ញុំចង់សួរសំណួរនេះចុងក្រោយ ។ តើលោកយល់ស្របដែរឬទេ? ចំពោះអង្គហេតុដែលថាគ្មានបុគ្គលអាចរំពឹងនិងគិតឃើញថា ជនរងគ្រោះ ឬក៏អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នឹងអត់ឱនទៅដល់ពេជ្ឈឃាដ ហើយគឺថាអ្នកផ្សះផ្សាជាតិ-- ការផ្សះផ្សាជាតិក៏មិនអាចមានដែរ ប្រសិនបើមិនមានការអត់ឱនទោសនេះដែរ ។

**ឆ៖** ខ្ញុំគាំទ្រទៅលើការយល់ឃើញរបស់លោកត្រង់ចំណុចនេះ។ វាមានភាពចាំបាច់ និងវាមានសារសំខាន់ ដែលយើងមិនគិតពិចារណាទៅលើការខមាទោស ឬក៏អត់ឱនទោសពីជនរងគ្រោះនោះទេ។ ហើយនិងការដែលយើងឈានទៅដល់ការផ្សះផ្សានៅក្នុងប្រទេសជាតិ ដោយយើងមិនបានពិចារណាទៅលើការបំភ្លេចចោលនូវអតីតកាលដែលបានប្រព្រឹត្តឡើងនោះ ។

**លោក វាំងសង់ ដឺវាយដ៍ ដេស្បាឯល៖**

សូមអរគុណលោកច្រើន ។ ខ្ញុំពុំមានសំណួរបន្ថែមទៀតនោះទេ លោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

កិច្ចបន្ត អង្គជំនុំជម្រះប្រគល់វេទិកាទៅតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនក្រុម ដែលអាចតាំងសំណួរចំពោះអ្នកជំនាញរូបនេះ ហើយអង្គជំនុំចម្រះសូមជម្រាបថា អង្គជំនុំជម្រះផ្តល់ពេលវេលាសរុបសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនដប់ប្រាំនាទី ។ សូមអញ្ជើញ ។

[១៤:០៨:៣៤]

**ការតាំងសំណួរដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយ លោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

ខ្ញុំឈ្មោះ ម៉ាទីណូ ខ្ញុំជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ សូមគោរព និងសួស្តីលោកសហសេវិករបស់ខ្ញុំ គឺលោក គឹម ម៉េងឃី ដែលយើងតំណាងដើមបណ្តឹងរដ្ឋប្បវេណីម្ភៃប្រាំបីរូប ។ ខ្ញុំមានសេចក្តីរីករាយណាស់ដែលបានស្តាប់នូវសក្ខីកម្មរបស់លោក ។ ខ្ញុំមានកិត្តិយសណាស់ដែលបានតាំងសំណួរទាំងអស់នេះទៅកាន់លោក ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីនិងសហសេវិករបស់ខ្ញុំ យើងខ្ញុំកំពុងជួបប្រឈមទៅនឹងបញ្ហាដែលកើតឡើងបន្ទាប់ពីសាមសិបឆ្នាំ។ វាខុសពីនូរីមប៊ឺក ដែលវាកើតឡើងតុលាការវាកើតឡើងក្រោយពីពេលដែលបានបញ្ចប់ ហើយនៅករណីនេះ គឺវាកើតឡើងហើយនិងវាបានបើកការជំនុំជម្រះចំពោះបុគ្គលម្នាក់នៅក្នុងរយៈពេលមួយផ្សេង ។ នៅទីនេះ យើងដឹងថាមានការបើកការជំនុំជម្រះ ដែលវាកើតឡើងក្រោយពីពេលសាមសិបឆ្នាំជាង ហើយវាទាក់ទងទៅនឹងបញ្ហានិទ្ទណ្ឌភាព។ ដូច្នេះហើយ គឺខ្ញុំចង់សួរសំណួរមួយចំនួនទៅកាន់លោក ។ ដើមបណ្តឹងរដ្ឋប្បវេណីបានខិតខំប្រឹងប្រែងដើម្បីចូលរួមជាសាធារណៈ ហើយលើកឡើងនូវសេចក្តីខ្វាយខ្វល់របស់ខ្លួន ហើយនិងបានរៀបរាប់អំពីជីវិតដែលគាត់រងគ្រោះដោយឈឺចាប់ខ្លោចផ្សា មិនថាពួកគាត់ជាជនរងគ្រោះដោយផ្ទាល់ ឬក៏ជាជនរងគ្រោះដោយប្រយោលនោះទេ ។

ហើយនៅថ្ងៃនេះ នៅក្នុងការជំនុំជម្រះរបស់យើងយើងឃើញមានជនជាប់ចោទ ដែលគាត់ជនដំបូងត្រូវបានយកមកកាត់ទោស ។ តាំងពីឆ្នាំ១៩៧៩ នៅពេលដែលគាត់ត្រូវបានគេចាប់ខ្លួន គាត់ត្រូវបានធ្វើការទទួលស្គាល់ការពិត ទទួលស្គាល់នូវពិរុទ្ធភាពរបស់គាត់ក្នុងលក្ខណៈទូទៅ។ ដើមបណ្តឹងរដ្ឋ-ប្បវេណីយើងខ្ញុំនៅមានសំណួរមួយចំនួន ហើយពេលខ្លះជនជាប់ចោទគាត់មិនពេញចិត្តទៅលើការសារ-ភាពរបស់គាត់ ។

ជាថ្មីម្តងទៀត ខ្ញុំសូមបញ្ជាក់ឡើងវិញ ដើមបណ្តឹងរដ្ឋប្បវេណីបានពិចារណាថា ជនជាប់ចោទគាត់បានបង្ហាញនូវអង្គហេតុប្រហែលជាហាសិបភាគរយ ហើយអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីចង់បាននិងលើកឡើង គឺគាត់គិតថាវាមានសារសំខាន់ណាស់ដែលថា អង្គហេតុ និងសេចក្តីការពិតទាំងឡាយត្រូវតែលាតត្រដាងឲ្យដឹង ហើយពួកគាត់ពេលខ្លះមិនបានដឹងទៅលើអង្គហេតុទាំងអស់នេះ ។ លោកបានឆ្លើយនូវសំណួរទាំងអស់នេះមួយចំនួនហើយ ទាក់ទងទៅនឹងការទទួលស្គាល់នូវពិរុទ្ធភាព ។ មេធាវីការពារក្តីបានពឹងផ្អែក ឬក៏បានបង្ហាញ និងបង្កើតនូវភស្តុតាងដែលលោកក៏បានជ្រាបផងដែរ គឺគាត់បានលើកឡើងបង្ហាញអំពីករណី អាល់ប៊ឺត ស្ពៀ នៅក្នុងតុលាការនូរីមប៊ឺក នៅពេលដែលគាត់នោះត្រូវបានគាត់បានសារភាពអំពីពិរុទ្ធភាព ។ ហើយនៅពេលនោះ គេបានគិតថាវាជាវិធីសាស្ត្រនូវការលាតត្រដាងនូវការពិត នៅពេលដែលគាត់បានទទួលស្គាល់ពិរុទ្ធភាពរបស់គាត់ ហើយលោក ស្ពៀ គាត់មានការចាប់អារម្មណ៍ ហើយនិងទាញចំណាប់អារម្មណ៍ទៅដល់សហ-- ទៅដល់ព្រះរាជអាជ្ញា ចៅក្រម និងអ្នកកាសែត ។ លោក អាល់ប៊ឺត ស្ពៀ គាត់ទទួលបានផលប្រយោជន៍ដែលគាត់-- ដោយសារតែមុនពេលដែលគេចាប់ខ្លួនគាត់ គឺគាត់បានចាត់នូវវិធានការវិជ្ជមានមួយចំនួន ហើយគាត់បានធ្វើការងារប្រឆាំងនឹងរបបដែលកើតឡើងនាសម័យនោះ ។ ដូច្នេះ ការសារភាពពិរុទ្ធភាពរបស់គាត់គឺមានលក្ខណៈគ្រប់គ្រាន់ ។

ហើយប្រសិនបើយើងលើកឡើងថា ខ្ញុំទទួលស្គាល់នូវអង្គហេតុ ។ ខ្ញុំទទួលស្គាល់នូវអ្វីដែលបានបង្ហាញដាក់ជូននេះ គឺវាគ្រប់គ្រាន់ទៅលើអ្វីដែលលោកបានធ្វើឡើង ។ នេះជាដំណាក់កាលឈានទៅរកការផ្សះផ្សាជាតិ ។ ដូច្នេះហើយ វាមិនមែនជាចំណុចដែលថាយើងត្រូវបំភ្លេចចោលនោះទេ យើងត្រូវតែដឹងតុលាការនេះ ត្រូវតែដឹងថាមានអ្វីកើតឡើងនៅក្នុងប្រទេសកម្ពុជា ។ ប្រសិនបើមិនមានការឆ្លើយតបចេញមកពីសុទ្ធចិត្ត និងដោយឯង១ពីជនជាប់ចោទ និងមិនមានការគាំទ្រពីជនជាប់ចោទនោះទេ ដែលផ្តល់ជូនទៅដល់ភាគីទាំងអស់នៅក្នុងដំណើរការក្តីនេះ ។

**ស៖** តើលោកគិតថា ដើមបណ្ដឹងរដ្ឋប្បវេណី គាត់អាចទទួលយកបាននូវការអត់ឱនទោសនេះដែរឬទេ? ដោយសារតែនាពេលបច្ចុប្បន្ន ដើមបណ្ដឹងរដ្ឋប្បវេណី ហាក់ដូចជាមិនបានទទួលស្គាល់ទៅលើកការអភ័យទោសនោះទេ ។ ដូច្នេះហើយ វាហាក់ដូចជាមិនមានអាចជួយទៅដល់ដំណើរការផ្សះផ្សាជាតិ ។ ខ្ញុំសូមអភ័យទោស ដែលសំណួរខ្ញុំសួរវែងពេក ។

**ឆ៖** សូមអរគុណចំពោះសំណួរដែលលោកស្រីបានសួរដែលសំខាន់មួយនេះ ។

យើងអាចសរសេរនូវរឿងរ៉ាវជាច្រើនទៅលើចំណុចទាំងអស់នេះ ។ គឺសរសេរយ៉ាងច្រើន ដូចដែលលោក ហ្គាល់ឡាំផន បានសរសេរ ដែរថាឧក្រិដ្ឋកម្មទាំងអស់នេះ គឺមិនអាចគេដាក់ទោស ឬក៏មិនអាចយើងធ្វើការអត់ឱនឲ្យបាន ។ ខ្ញុំសូមទាញនូវឧទាហរណ៍ពីលោក អាល់ប៊ឺត ស្ពៀ ។ ឧទាហរណ៍ទាំងអស់នោះ គឺវាស្ថិតនៅក្នុងចិត្តរបស់ខ្ញុំ ហើយវាដូចនូវអ្វីដែលខ្ញុំគិត ដោយសារតែសកម្មភាពវិជ្ជមានរបស់គាត់ចំពោះអ្នកដែលជាអ្នកអកុសល និងអ្នកដែលមិនសប្បាយចិត្តទាំងឡាយ ដែលគាត់ជាប់ឃុំនៅក្នុងជំរំ *ឪរភ៍* ដែលខ្ញុំក៏ជាប់នៅទីនោះដែរ នៅក្នុងសង្គ្រាមលោកលើកទីពីរ ។

លោក ស្ពៀ គាត់បានបង្ហាញថា វាសារសំខាន់ដែលយើងត្រូវពិចារណាទៅលើលក្ខខណ្ឌការងារដែលមិនអាចទ្រាំបាន ជាពិសេសដែលកើតឡើងចំពោះបុគ្គលដែលត្រូវបានគេដឹកជញ្ជូនទៅដាក់នៅក្នុងជំរំប្រមូលផ្ដុំទាំងអស់នោះ ។

ដូច្នេះ នៅក្នុងគំនិត និងការគាំទ្ររបស់លោក ស្ពៀ គឺគាត់បានបោះជំហានធ្វើឲ្យចៅក្រមនៅតុលាការ នូរឹមប៊ឺក មិនគិត ហើយមានភាពអធ្យាស្រ័យទៅលើគាត់ និងទៅដល់ជនជាប់ចោទផ្សេងទៀតដែលប្រឈមមុខនៅក្នុងតុលាការនោះ ។

[១៤:១៦:៤៨]

ខ្ញុំមិនគិតថា ចំណុចទាំងអស់នេះវាគួរតែអនុវត្តដូចគ្នានោះទេ ។ ចំពោះបុគ្គលមួយរូបដែលគាត់បានទទួលស្គាល់នូវពិរុទ្ធភាពរបស់គាត់ ។ ប៉ុន្តែ គាត់បែបជាមិនបានផ្ដល់នូវភស្តុតាងសម្ភារៈយ៉ាងច្បាស់លាស់ដើម្បីជួយជ្រោមជ្រែងទៅដល់តុលាការ ដើម្បីបង្ហាញអំពីការយល់ឃើញទាំងឡាយដែលគាត់បានជំទាស់និងការតវ៉ា ។ ជាពិសេសទៅលើការណែនាំទាំងឡាយដែលគាត់បានស្នើសុំ និងទៅលើការណែនាំទាំងឡាយដែលគាត់ទទួលបាន នៅពេលដែលគាត់បានប្រព្រឹត្តនូវឧក្រិដ្ឋកម្មទាំងអស់នោះ ។ ដូច្នេះ ចំណុចនេះវាមានន័យថា ទោះបីជាជនរងគ្រោះទាំងឡាយគាត់ពុំអាចអភ័យទោសក៏ដោយ ពួកគាត់អាចពិចារណាទៅលើកាលៈទេសៈដែលជនជាប់ចោទគាត់បានឆ្លើយសារភាព ។ ជាដំបូង គឺពួកគេត្រូវស្នើឲ្យ

បង្ហាញអំពីការទទួលខុសត្រូវរបស់គាត់ឲ្យបានច្បាស់លាស់ ហើយនិងបង្ហាញនៅលើអ្វីដែលគាត់បានធ្វើ ។ បន្ទាប់ពីនោះមក ជនរងគ្រោះអាចពិចារណា-- ពួកគាត់អាចពិចារណាថាតើពួកគាត់អាចរស់រានឬក៏រស់នៅជាមួយគ្នាដែរឬទេ? ក្នុងនាមជាប្រជាពលរដ្ឋ និងជនរួមជាតិតែមួយ ។

**លោកស្រី ត្រឺស្ទីន ម៉ាទីណូ៖**

សូមអរគុណលោក ខ្ញុំពុំមានសំណួរសួរបន្ថែមទៅកាន់លោកទៀតទេ ។

**ប្រធានអង្គជំនុំ៖**

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមផ្សេងទៀត តើមានសំណួរអ្វីអាចចង់សួរដល់អ្នកជំនាញរូបនេះដែរឬទេ? សូមអញ្ជើញ បាទ ។

**សួរដោយលោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន ។

ខ្ញុំសូមជម្រាបសួរលោក ស្តេហ្វិន ហាស្សែល ។ ខ្ញុំបាទមេធាវី ហុង គឹមសួន ជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីផងដែរ ។

**ស៖** សូមសួរសំណួរទៅលោកថា លោកមានបទពិសោធន៍ទៅលើខាងលើការផ្សះផ្សា ដើម្បីស្វែងរកការត្រូវរ៉ូវគ្នា ឬបញ្ចៀសឲ្យបាន ឬក៏បានខ្លះនូវការគំនុំទាក់ទងនឹងអំពើប្រល័យជីវិតមនុស្សនេះ។ នៅក្នុងតុលាការ អ.វ.ត.ក នេះក៏លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច គាត់បានលើកឡើងច្រើនដងហើយអំពីការសុំអភ័យទោស ។ ក៏ប៉ុន្តែអ្វីដែលខ្ញុំចង់សួរនោះ គឺជនរងគ្រោះភាគច្រើន គាត់នៅរង់ចាំមើលថាតើការកាត់ទោស ឬក៏ការស្វែងរកយុត្តិធម៌របស់តុលាការនេះ ថាតើលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច មានទោសក្នុងការចោទប្រកាន់ឬទេ? ដូច្នេះ ក្នុងទឹកចិត្តជនរងគ្រោះភាគច្រើន គឺមិនទាន់ថាទទួលយកការសុំអភ័យទោសនោះទេ ។

[១៤:២០:៥៧]

ដូច្នេះ សំណួរខ្ញុំសួរថា នៅឆ្នាំ១៩៤៨ ដោយសារលោកបានចូលរួមនិពន្ធសេចក្តីថ្លែងការណ៍សាកលស្តីពីសិទ្ធិមនុស្ស នេះគឺចេញមកអំពីបទពិសោធន៍ដែលលោកធ្លាប់ជាអ្នកទោស ឬអ្នកដែលធ្លាប់ទទួលរងទុក្ខនៅក្នុងមន្ទីរឃុំឃាំង ក្នុងសម័យសង្គ្រាមលោកលើកទីពីរ រវាងប្រទេសបារាំង និងប្រទេសអាល្លឺម៉ង់ ។ ដូច្នេះ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលជារបបមួយមានអំពើប្រល័យជីវិតមនុស្សជាច្រើន។ លោកបានដឹងហើយថា អ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យបានចុះហត្ថលេខាជាមួយនឹងអង្គការ

សហប្រជាជាតិស្តីអំពីសន្ធិសញ្ញា ឬកតិកាសញ្ញា ការទប់ស្កាត់អំពើប្រល័យពូជសាសន៍ផងដែរ ។

ក្រោយមកទៀត មានការសម្លាប់រង្គាលនៅប្រទេស រ្វ៉ាន់ដា រវាងជនជាតិ ហ៊្វូទូ និង ទុតស៊ីទាំងនេះ ក៏មានការផ្សះផ្សាជាតិ ឬក៏ស្វែងរកសន្តិភាពតាមរយៈការកាត់ទោសពួកអ្នកប្រព្រឹត្ត ឬមេដឹកនាំទាំងនោះដែរ ។ ដូច្នេះ ខ្ញុំក្នុងនាមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សូមឲ្យលោកជួយបំភ្លឺបន្តិចថា បើសិនជាមានឧទាហរណ៍ ការសម្លាប់រង្គាលជាច្រើនលើកច្រើនសានៅលើពិភពលោក ដែលបានដឹងបានឮហើយហើយពេលវេលាបន្តមកទៀត ចេះតែមានអំពើប្រល័យពូជសាសន៍ ឬក៏ប្រល័យជីវិតមនុស្សរបៀបតាមរយៈដឹកនាំរបស់ប្រទេសនីមួយៗទាំងនេះ តើការលើកឡើងពីគោលការណ៍ផ្សះផ្សាជាតិ ឬក៏ស្វែងរកយុត្តិធម៌ ដើម្បីលុបបំបាត់នូវការចងគំនុំអាឃាតនេះ វានៅតែជាគោលការណ៍មួយប្រើបានជាទូទៅទៅមុខទៀត ដោយយកតែគោលការណ៍ផ្សះផ្សាទាក់ទងតែជាមួយអ្នកដឹកនាំនេះបានជាប្រយោជន៍តទៅទៀតដែរឬទេ? សូមអញ្ជើញលោកមានប្រសាសន៍ ។

[១៤:២៣:២៧]

**ឆ៖** លោកមេធាវី! វាជាសំណួរមួយដែលមានលក្ខណៈស្មុគស្មាញ ដែលលោកមេធាវីបានសួរមកបុរសមួយរូបដែលមានបទពិសោធន៍យ៉ាងច្រើន ដែលវាទាក់ទងទៅនឹងដំណើរការវិវឌ្ឍន៍ទៅនៅក្នុងប្រព័ន្ធច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។ ប៉ុន្តែ បុរសនេះមិនទាន់បានដឹងច្បាស់លាស់អំពីស្ថានភាពជាក់លាក់នៅក្នុងប្រទេសកម្ពុជា ហើយអំពើ ឬក៏របបខ្មែរក្រហមដែលបានឆ្លងកាត់មកនេះ ។ បានន័យថា គឺបុរសម្នាក់ដែលគាត់មិនបានដឹងអំពីចំណុចទាំងអស់នេះ ។ ដូច្នេះហើយ គាត់មិនអាចនិយាយថា តើពួកគេបានប្រព្រឹត្តនូវអ្វីខ្លះនៅក្នុងប្រទេសរបស់លោក និងការយោងពិនិត្យមើលទៅដល់ប្រទេសទាំងឡាយដែលបានកើតឡើងនៅក្នុងពិភពលោក ។ យើងបានសិក្សាមកពីប្រវត្តិសាស្ត្ររបស់យើងថា រាល់ប្រទេសនីមួយៗមានលក្ខណៈសម្បត្តិ និងលក្ខណៈជាក់លាក់របស់ខ្លួន ។ ហើយយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិគួរតែមានការប្រុងប្រយ័ត្ន យកចំណុចបុគ្គលិកលក្ខណៈទាំងអស់នេះ យកមកពិចារណា ។

អ្វីដែលយើងអាចនិយាយក្នុងលក្ខណៈសាមញ្ញនោះ គឺទស្សនទាននៃការផ្សះផ្សាជាតិ អាចកើតឡើងដោយមានការអនុវត្តស្របគ្នាទៅនឹងទស្សនទាននៃការលាតត្រដាងនូវការពិត ។ ជាឧទាហរណ៍ នៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង យើងឃើញថា មានការបង្កើតគណៈកម្មាការស្វែងរកការពិត និងគណៈកម្មាធិការផ្សះផ្សាជាតិ ។ ហើយយើងដឹងយ៉ាងច្បាស់ថា យើងពិតជាមិនអាចបញ្ចប់នូវនិទ្ទណ្ឌភាពនោះទេ ប៉ុន្តែប្រសិនបើយើងមិនអាចនោះ វាធ្វើឲ្យស្ថានភាពនេះវាកាន់តែមានភាពអាក្រក់ទៅៗ ។

នៅពេលដែលយើងអាចលុបចោលនូវនិទ្ទណ្ឌភាពតាមរយៈការជំនុំជម្រះ ឬក៏តាមរយៈការចេញសាលក្រមពីតុលាការ ដែលសាលក្រមនេះនឹងធ្វើការចេញ និងសម្រេចទៅលើជនជាប់ចោទ មិនត្រឹមតែមួយរូបនោះទេ ។ ហើយយើងដឹងហើយថាបុគ្គលផ្សេងៗទៀតនឹងត្រូវយកមកជំនុំជម្រះផងដែរ ។ ដូច្នេះ នៅពេលដែលយើងអាចបញ្ចប់បាននូវនិទ្ទណ្ឌភាព នៅពេលនេះហើយដែលយើងអាចយល់ឃើញថា ដំណើរការផ្សះផ្សាជាតិ យើងអាចពិចារណា ហើយវាអាចកើតមានទៅបាន ។ ដូច្នេះ ខ្ញុំសូមនិយាយសាថ្មី ការផ្សះផ្សាជាតិនេះមិនមែនថាវាទាល់តែជនរងគ្រោះគាត់អភ័យទោសឲ្យនោះទេ ។ ហើយការផ្សះផ្សាជាតិនេះ គឺវាមានន័យថា ការកសាងនូវប្រទេសមួយដែលពោរពេញទៅដោយសន្តិភាព ។

**លោក ហុង គីមសួន៖**

សូមអរគុណ ស្តេហ្វិន ហាស្មែល ខ្ញុំមានតែសំណួរមួយនេះទេ ។

សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

[១៤:២៨:១៥]

ជាកិច្ចបន្ត អង្គជំនុំជម្រះផ្តល់វេទិកាទៅមេធាវីការពារក្តី ដើម្បីមានឱកាសក្នុងការតាំងសំណួរចំពោះអ្នកជំនាញ ហាស្មែល ប្រសិនបើមេធាវីការពារក្តីមានសំណួរត្រូវសួរ ហើយអង្គជំនុំជម្រះផ្តល់ឱកាសពេលវេលាដប់ប្រាំនាទីសម្រាប់ការសួរនេះ ។ សូមអញ្ជើញ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន។ ប្រហែលនៅពេលនេះយើងអាចចាប់ផ្តើម ធ្វើយ៉ាងណាឲ្យរូបភាពពីសាក្សីអ្នកជំនាញ ឲ្យធ្វើយ៉ាងណាឲ្យរូបភាពនេះវាដើរឡើងវិញ ដោយសារតែយើងឃើញថា រូបភាពនោះហាក់ដូចជាមិនដំណើរការនោះទេ ។ រូបភាពហាក់ដូចជានឹង ប៉ុន្តែយើងបានឮតែសំឡេង ។ ដូច្នេះហើយសូមឲ្យខាងផ្នែកសោតទស្សន៍ គាត់អាចជួយចាក់ផ្សាយរូបភាពនោះឲ្យមានចលនា ហើយប្រសិនអាចធ្វើទៅបានសូមដំណើរការរូបភាពនោះឲ្យវាមានលក្ខណៈប្រសើរជាងមុន ដើម្បីឲ្យយើង វាអាចចងចាំទៅលើដំណើរការរបស់យើងផងដែរ ។

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍ សូមចាត់ចែងរៀបចំ សូមកែសម្រួលនូវផ្នែកខាងបច្ចេកទេស ដើម្បីឲ្យដំណើរការល្អ ។ ហើយប្រហែលជាត្រូវចំណាយពេលមួយនាទី ឬពីរនាទី សូមមេធាវីការពារក្តីអង្គុយ

សិនចុះ ចាំរៀបចំរួចរាល់ សឹមអញ្ជើញដំណើរការសួរសំណួរដល់ ចំពោះអ្នកជំនាញ ។

ការដែលរៀបចំនេះអាចប្រើពេលវេលាលើសពីពីរនាទី ប្រហែលជារហូតដល់ប្រាំនាទីឯណោះ។ សូមភាគី និងសាធារណៈជនជ្រាប!

*(សម្រាក រង់ចាំផ្នែកខាងសោតទស្សន៍ធ្វើការកែសម្រួលរូបភាព)*

**លោក ស្ដេហ្វិន ហាស្មែល ៖**

ឥឡូវនេះ យើងមានការតភ្ជាប់ជាមួយប៉ារីសវិញហើយ ។ តើសាលាក្ដីបានរូបភាពច្បាស់ទេ? បើសិនជាច្បាស់សូមមេត្តាជម្រាបយើងខ្ញុំផង ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះបានទទួលរូបភាពច្បាស់ហើយ ឥឡូវហ្នឹងយើងចាប់ដំណើរការសវនាការតទៅទៀត ដោយប្រគល់វេទិកាទៅមេធាវីការពារក្ដីដើម្បីតាំងសំណួរជាក់លាក់ចំពោះអ្នកជំនាញ ។ សូមអញ្ជើញលោកមេធាវី ។

[១៤:៣៥:៤៥]

**ការតាំងសំណួរដោយមេធាវីការពារក្ដី**

**សួរដោយលោក ហ្រ្វង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ សូមជម្រាបសួរលោក ស្ដេហ្វិន ហាស្មែល ហើយសូមអរគុណយ៉ាងគុណយ៉ាងកក់ក្ដៅចំពោះលោកដែលបានចំណាយពេលជួយដល់ការជំនុំជម្រះ ហើយនៅទីនោះគឺថានៅពេលយប់ជ្រៅទាបភ្លឺ ដែលលោកបានព្យាយាមចំណាយពេលបង្ហាញខ្លួនតាមវីដេអូ ខន់ហ្វើរិន ដល់តុលាការ ហើយសូមអរគុណលោកសាក្សី ។

ដូចដែលលោកបានយល់ពីសំណួរដែលបានសួរទៅលោកដល់ពេលនេះនោះ ដែលសួរដោយតំណាងការិយាល័យសហព្រះរាជអាជ្ញា ហើយនិងមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ហើយមានព័ត៌-មានមួយចំនួនច្រើន ដែលជម្រាបទៅលោកអំពីជនរងគ្រោះ ហើយដូចជារឿងដែលថា *រ៉ូប៊ែរ បាដិនទែ* ដែលលោកបានដឹងរឿងរ៉ាវរបស់គាត់នោះ ដែលគាត់បានសរសេរនៅក្នុងទស្សនាវដ្ដី *ដេលីឡឺម៉ុងដ៍* ដែលថាយើងមិនត្រូវមានការច្រឡំថាយុត្តិធម៌ ហើយនិងការព្យាបាលទៅដល់ជនរងគ្រោះ ។

*រ៉ូប៊ែរ បាដិនទែ* បានសរសេរថា យុត្តិធម៌ព្រហ្មទណ្ឌ គឺមិនមានបេសកកម្មដើម្បីព្យាបាលនូវការឈឺចាប់នូវការឈឺចាប់របស់ជនរងគ្រោះនោះទេ ។ ដូច្នេះ គំនិតនេះតាមពិតគឺជាការយល់ច្រឡំមួយដែល

លោកអាចនឹងយល់ឃើញបែបនោះ នៅក្នុងផ្នែកមួយដែលស្ថិតនៅក្នុងចិត្តរបស់ជនរងគ្រោះ យ៉ាងហោចណាស់ដោយថា តាមការរំពឹងរបស់គេពីការជំនុំជម្រះនេះ ។ ចំពោះខ្ញុំ ខ្ញុំជាមេធាវីការពារនៅម្ខាងទៀត ហើយមិនទាន់គ្រប់គ្រាន់ទៅតាមអង្គហេតុទេ នៅដល់ពេលនេះនៅកម្ពុជានៅក្នុងការជំនុំជម្រះនេះ ។ ឌុច គឺជាជនទីមួយនៃកម្មាភិបាលខ្មែរក្រហម ដែលទទួលស្គាល់ជាសាធារណៈនូវការទទួលខុសត្រូវរបស់គាត់។

ជនរងគ្រោះទាំងឡាយមានការពិបាកក្នុងការទទួលយកនូវអ្វីដែលគាត់និយាយនៅពេលដែលគាត់បញ្ជាក់ថា ខ្ញុំគោរពតាមបញ្ជាគេ ។ ហើយគាត់តែងតែបន្ថែមទៀតថា ទោះបីជាខ្ញុំបញ្ជាតាមតែបញ្ជាគេហ្នឹងក៏ដោយ ដែលតាមពិត គឺជាកត្តាជាញឹកញាប់ដែលបញ្ជាក់ដោយអ្នកជំនាញគាត់តែងតែបញ្ជាក់ថា កត្តានេះគឺមិនធ្វើឲ្យខ្ញុំមានដកខ្លួនចេញពីការទទួលខុសត្រូវនោះទេ គឺជាការទទួលខុសត្រូវទាំងស្រុងចំពោះអ្នកដែលស្ថិតនៅក្រោមការបញ្ជារបស់ខ្ញុំ ។

ដូច្នេះ ដើម្បីបញ្ជាក់ឲ្យបានច្បាស់ថាមុននឹងខ្ញុំសួរទៅនឹងសំណួរទៅលោក ។ ខ្ញុំក៏សូមអានជូនលោកនូវកថាខណ្ឌពីរនៃដីកាដំណោះស្រាយដែលបានរៀបចំឡើងដោយសហចៅក្រមស៊ើបអង្កេត ដែលបានស្តាប់ ឬក៏បានស្តាប់ ឌុច ក្នុងរយៈពេលពីរឆ្នាំ ដោយមានវត្តមានរបស់សហព្រះរាជអាជ្ញា ហើយសហចៅក្រមស៊ើបអង្កេតបានធ្វើសេចក្តីសន្និដ្ឋាននៅក្នុងការស៊ើបសួររបស់ខ្លួន ដោយបញ្ជាក់ថា “ឌុច តែងតែទទួលស្គាល់ការទទួលខុសត្រូវរបស់គាត់ក្នុងសមត្ថភាពរបស់គាត់ ក្នុងឋានៈជាប្រធានស-២១ចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅទីនោះ ។ ឌុច បានសម្តែងជាទៀងទាត់អំពីការសោកស្តាយ វិប្បដិសារីចំពោះជនរងគ្រោះ ក្រុមគ្រួសាររបស់គេ ហើយនិងចំពោះអតីតបុគ្គលនៃស-២១ ផងដែរ ដែលត្រូវបានស្ថិតនៅក្រោមបញ្ជារបស់គាត់” ។ ហើយចៅក្រមបន្ថែមទៀតថា “លើសពីនេះទៅទៀត ឌុច បានសហការដោយស្ម័គ្រចិត្តនៅក្នុងដំណាក់កាលនៃការស៊ើបអង្កេត ។

ការច្រានចោលនូវការឆ្លើយដាក់ទៅជនណាម្នាក់ដែលជាអ្នកក្រោមបញ្ជារបស់គាត់ ហើយគាត់បញ្ជាក់ទាំងស្រុងថា ការទទួលខុសត្រូវនៅត្រឹមគាត់ ហើយនិងមិនដកខ្លួនចេញទេ” គឺចំណុចមួយចំនួនដែលស្របគ្នានៅក្នុងចំណុចនេះ នៅក្នុងមតិរបស់ចៅក្រមស៊ើបអង្កេតនោះគឺថា គាត់បាន-- វាមានចំណុចខ្វែងគ្នាមួយចំនួន គឺកើតឡើងដោយសារការភ័យខ្លាច ហើយនិងការផ្លាស់ប្តូរ ដែលគាត់បានទទួល ហើយត្រូវបានរំឭកអំពីប្រវត្តិសាស្ត្រដ៏ឈឺចុកចាប់នៃបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងនោះ ។ ដូច្នេះ លោក ហាស្សែល នេះគឺជាបុរសម្នាក់ដែលត្រូវបានការពារដោយខ្ញុំ ហើយនិងមេធាវី ការ សាវុត្ថ ហើយគាត់ហ្នឹងក៏ជាអតីតអ្នកទោសខ្មែរក្រហមដែរ ដើម្បីឲ្យលោកយល់បានថាតើវាមានលក្ខណៈស្មុគស្មាញ

ដូចម្តេច? ហើយនៅទីបំផុតខ្ញុំចង់បន្ថែមថា នៅក្នុងក្របខ័ណ្ឌនៃកិច្ចសហការជាមួយយុត្តិធម៌បែបនេះ ឌុច បានទទួលស្គាល់ហើយនិងចូលរួមនៅក្នុងការសម្តែងឡើងវិញ នៅក្នុងទីកន្លែងជាក់លាក់មួយចំនួន ដូចជានៅស-២១ ហើយក៏នៅទីកន្លែងសម្លាប់ ឬក៏កន្លែងពិឃាដផ្សេងទៀតដែរ ។ ហើយនៅក្នុងឱកាសទាំងនោះគាត់បានធ្វើសេចក្តីថ្លែងការណ៍ដ៏ច្បាស់លាស់ដើម្បីជាអត្ថប្រយោជន៍ដល់ជនរងគ្រោះដើមបណ្តឹងរដ្ឋប្បវេណី ហើយគាត់បាននិយាយទៅកាន់ពួកទាំងនោះថា "ខ្ញុំសូមឲ្យលោកអភ័យទោសឲ្យខ្ញុំ ។ ខ្ញុំសូមឲ្យអ្នកឯងអភ័យទោសឲ្យខ្ញុំ ប៉ុន្តែមិនឲ្យ-- ប៉ុន្តែខ្ញុំមិនធ្វើបែបនោះទេ ខ្ញុំសូមឲ្យអ្នករក្សាទ្វារនៃការសុំទោសឲ្យនៅចំហ" ហើយនៅក្នុងនោះក៏មានកំណត់ហេតុនៃការសម្តែងឡើងនោះវិញដែរ ។

សម្រាប់ជូនព័ត៌មានទៅដល់តុលាការ ហើយឯកសារនោះគឺ 68/2 -- 48/2 ហើយបន្ទាប់ពីរគាត់ធ្វើសេចក្តីថ្លែងការណ៍នោះ ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ហើយនិង ប៊ូ ម៉េង បានសម្តែងការពេញចិត្តរបស់ពួកគាត់ ។

[១៤:៤៣:៣៥]

ដូច្នេះ សូមអភ័យទោសចំពោះការធ្វើសេចក្តីផ្តើមដ៏វែងនេះ ប៉ុន្តែលោករំឭកឡើងវិញនោះត្រឹមត្រូវហើយ ថាការពិត ហើយនិងការផ្សះផ្សាជាតិហ្នឹងគឺជា-- និយាយពីគណៈកម្មាធិការស្វែងរកការពិតនិងផ្សះផ្សាជាតិ ហើយលោកបានរំឭកឡើងវិញអំពីអង្គហេតុដែលថា ការផ្សះផ្សាជាតិដែលចាំបាច់នោះគឺត្រូវតែបង្ហាញឲ្យឃើញការពិត ហើយការពិតទីមួយដែលយើងនឹងបង្ហាញដល់លោកនោះគឺថា យើងចង់ជម្រាបលោកថា បាទ ជនជាប់ចោទបានសម្រេចចិត្តទទួលយកនិងការជំនុំជម្រះរបស់គាត់ ។ ប៉ុន្តែវាមិនទាន់គ្រប់គ្រាន់ចំពោះដើមបណ្តឹងរដ្ឋប្បវេណី ។ ប៉ុន្តែគាត់បានសម្រេចចិត្តថា ទទួលស្គាល់នូវបទល្មើស បទឧក្រិដ្ឋរបស់គាត់ ហើយថ្ងៃនេះគាត់គឺជាមនុស្សទីមួយ ដំបូងគេដែលបានធ្វើសេចក្តីសារភាពទទួលស្គាល់នោះ ។ ចំពោះការផ្សះផ្សាជាតិ បារាំង អាល្លឺម៉ង់ នោះគឺថាជាកត្តាមួយ ។ ខ្ញុំអាចពិនិត្យឃើញថាតើនៅក្នុងអាល្លឺម៉ង់ខ្លួនឯងនោះ គឺជាការចាំបាច់ដើម្បីឲ្យប្រជាជនអាល្លឺម៉ង់ ដែលត្រូវធ្វើការផ្សះផ្សាជាតិដោយខ្លួនឯង ។ ប៉ុន្តែ ខ្ញុំមិនអាចពិនិត្យមើលឃើញទេថា សម្រាប់ជាការផ្សះផ្សាជាតិនៅក្នុងប្រជាជនអាល្លឺម៉ង់ទាំងមូល ដែលស្ថិតនៅពីក្រោយអ្នកពិឃាដទាំងនោះ ។

**ស៖** ប៉ុន្តែ ក្នុងករណីកម្ពុជាថ្ងៃនេះគឺថា វាអាចជាលទ្ធភាពអាចប្រាប់យើងបាន ថាតើមានលទ្ធភាពណាមួយដែលឲ្យប្រជាពលរដ្ឋកម្ពុជាអាចផ្សះផ្សាជាតិដោយចំណោមខ្លួនឯងបាននោះ?

**ឆ៖** លោកមេធាវី ខ្ញុំបានស្តាប់ដោយយកចិត្តទុកដាក់បំផុតទៅពាក្យនីមួយៗដែលលោកទើបតែបាននិយាយ ។ ពាក់ព័ន្ធទៅនឹងការផ្សះផ្សាជាតិរវាងបារាំង និងអាល្លឺម៉ង់ វាគឺជាការចាំបាច់ ដែលថាអំពើឧក្រិដ្ឋត្រូវបានប្រព្រឹត្តឡើងដោយរបបហ៊ីត្លែ គឺជាការចាំបាច់ដែលថាអំពើទាំងនោះត្រូវតែបញ្ជាក់ប្រាប់ការពិតឲ្យគេដឹងទាំងស្រុង ។ នៅក្នុងដំណើរការនៃដំណើរការនីតិវិធីនៅសាលាក្តី នូរឹមប៊ឺក ហើយចំពោះខ្ញុំ ខ្ញុំគិតថា នេះហើយគឺជាលក្ខខណ្ឌដែលជាលក្ខខណ្ឌចាំបាច់បំផុត ដើម្បីឈានទៅដល់ការផ្សះផ្សាជាតិនោះ ។

[១៤:៤៦:៥៤]

អង្គហេតុ ឬក៏អង្គហេតុទាំងអស់ ត្រូវតែលាតត្រដាងឲ្យដឹង ឲ្យគេដឹង ។ ប្រសិនបើជនជាប់ចោទបានចូលរួមនៅក្នុងការលាតត្រដាងនូវអង្គហេតុ ឬការពិតទាំងនោះ ចំណុចទាំងនេះត្រូវតែជាកត្តាលើកមកពិចារណា ។ រហូតមកដល់ពេលនេះ (សូមកែតម្រូវ) ប៉ុន្តែជនជាប់ចោទ ដែលបានទទួលសារភាពពីពិរុទ្ធភាពនោះ មិនអាចផុតពីការជំនុំជម្រះបានទេ ចំពោះបទឧក្រិដ្ឋដែលជាបទឧក្រិដ្ឋដែលគាត់ទទួលស្គាល់ ឬក៏សារភាពថាគាត់បានប្រព្រឹត្តនោះ ។ តើវាអាចទៅរួចដែរឬទេ ប្រសិនបើ-- បើសិនជាយើងធ្វើការវិភាគអំពីអត្តចរិតរបស់គាត់ ដោយមានការជួយពីមេធាវីការពាររបស់គាត់ ខ្ញុំអាចទទួលស្គាល់យ៉ាងងាយស្រួលទៅលើទេពកោសល្យរបស់លោក ។ មានតែពេលនោះទេដែលយើងអាចនាំមកនូវសេចក្តីសន្និដ្ឋានបាន ដែលថាការជំនុំជម្រះនេះ គឺធ្វើឡើងស្របគ្នា ដែលថាវាមិនមែនជាអ្វីដែលជាឯកតោភាគីនោះទេ ។

ចំពោះខ្ញុំ ឬក៏ចំពោះគំនិតខ្ញុំ ឬក៏ចំពោះអង្គជំនុំជម្រះ ដើម្បីនឹងថ្លឹងថ្លែងឲ្យបានឯករាជ្យទាំងស្រុង គឺថ្លឹងថ្លែងនូវលក្ខណៈហើយនិងវិសាលភាពនៃបទល្មើសនានា គឺមិនត្រឹមតែផ្អែកទៅលើជនជាប់ចោទតែម្នាក់នោះទេ ប៉ុន្តែពួកមេដឹកនាំរបស់សម័យខ្មែរក្រហមនៅកម្ពុជាដ៏រន្ធត់នោះផងដែរ។ គឺដោយកំណត់នូវចរិតលក្ខណៈពិសេសចំពោះជនជាប់ចោទរូបនេះ ដើម្បីឲ្យឈានទៅដល់សេចក្តីសន្និដ្ឋានមួយដែលនឹងមានផលប៉ះពាល់ដោយចម្បង ក្នុងការធ្វើឲ្យមានការផ្សះផ្សាដ៏មានតម្លៃបំផុតអាចមានទៅបាននៅក្នុងប្រទេសមួយ ។ ដែលខ្ញុំយល់ថាមិនមាននរណាម្នាក់អាចនិយាយបានថា នៅទីបំផុតនោះ តើអ្នកណាដែលត្រូវបានឃុំខ្លួននៅកន្លែងមន្ទីរមួយ ឬក៏អ្នកណាមួយនៅកន្លែងណាមួយដើម្បីបញ្ជាក់ពីការពិតដែលកន្លងមកសាមសិបឆ្នាំមកហើយនេះ ។ សូមអរគុណ ។

**ស៖** លោកបានបញ្ជាក់យ៉ាងជាក់ស្តែង អំពីបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ ហើយខ្ញុំសូមអនុញ្ញាតនិយាយអំពីបុរសនេះ ។ អ្នកជំនាញទាំងខាងចិត្តសាស្ត្រ និងខាងជំងឺផ្លូវចិត្តបាននិយាយចំពោះមុខ តុលាការនេះរួចមកហើយ រួចបានរំឭកដល់យើងខ្ញុំថា ឌុច មុនដែលមានសម័យកាលដ៏រន្ធត់នោះ គាត់ជាគ្រូបង្រៀនដែលទទួលការគោរពសសើរពីអ្នកទាំងអស់ ហើយ ឌុច ត្រូវបានទាក់ទាញដោយលទ្ធិ *ស្តូអ៊ីស៊ីហ្សិន* ។

ហើយចាប់ផ្តើមពីគំនិតនោះមក ចាប់ពីសម័យកាលស៊ើបអង្កេតនោះមក គឺ ឌុច បានពន្យល់ទៅសហចៅក្រមស៊ើបអង្កេតថា នៅពេលដែលគាត់ទទួលបន្ទុកនៅគុកមួយហៅថាម-១៣ នោះ ។ ជាគុកមួយដែល ហ្វ្រង់ស្វ័រ ប៊ីហ្ស៊ូ ត្រូវបានគេឃុំខ្លួននៅទីនោះ។ គាត់មិនបានចូលចិត្តអ្វីដែលគាត់ធ្វើនោះទេ គាត់មិនចូលចិត្តតួនាទីដែលត្រូវបានប្រគល់ឲ្យគាត់ដោយមេ ដោយថ្នាក់លើរបស់គាត់ ។

ហើយ ឌុច បាននិយាយប្រាប់សហចៅក្រមស៊ើបអង្កេតថា ខ្ញុំនឹងត្រូវតែសម្របសម្រួលខ្លួនរបស់ខ្ញុំដើម្បីឲ្យគោរពទៅតាមឃ្លាមួយកំណាព្យនិយាយពីមរណៈរបស់ចចកនោះ ។ ហើយសុំឲ្យខ្ញុំ អនុញ្ញាតឲ្យខ្ញុំអានកំណាព្យចុងក្រោយនៃកំណាព្យអ្នកកវីនិពន្ធដែលលោកបានបោះពុម្ពផ្សាយកំណាព្យនោះ ។ និយាយឲ្យច្បាស់ទៅ គឺជាកំណាព្យដែលសរសេរឡើងដោយលោក *អាល់ហ្វ្រែត ឌឺ វិញី* គឺឃ្លាចុងក្រោយនៃកំណាព្យនោះ ខ្ញុំគិតថាក្រៅពីឈ្មោះនៃមនុស្សដ៏-- គឺថាតើយើងជាមនុស្សពូកែប៉ុនណា? តើខ្សោយប៉ុនណា? ហើយទុក្ខសោកប៉ុនណា? ហើយយើងត្រូវតែសម្របសម្រួលរស់ទៅតាមនោះ គឺយើងស្ថិតនៅក្នុងជំពូកមួយក៏ដូចជាសត្វនោះដែរ ។

នៅពេលដែលយើងមួយនៅលើដែនដី មួយទៀតនៅខាងក្រោយ ហើយគឺត្រូវតែរក្សាស្ងៀមស្ងាត់ បើមិនដូច្នោះទេ គេនឹងថាយើងកំសាក ។ ខ្ញុំអាចដឹងថា អាចនឹងស្តាប់បាន ហើយដឹងថា-- លោកចាំកំណាព្យនេះបានល្អ ។

ខ្ញុំយល់ពីគំនិតរបស់លោកអំពី *សាវិចស្ត្រាវ៉េលឡា* ដែលនិយាយពីកំណាព្យពីមរណភាពរបស់ចចកនោះ ។ ហើយយើងមើលចុងក្រោយនោះ គឺថាវាទាក់ទាញដល់ចិត្តរបស់ខ្ញុំ ហើយគាត់បាននិយាយប្រាប់ខ្ញុំថា ប្រសិនបើលោកអាចធានាថា ចិត្ត ឬក៏ព្រលឹងវិញ្ញាណរបស់លោកបានតាមការសិក្សា ហើយនិងតាមការគិតគូរ វាអាចនឹងឈានទៅដល់កម្រិតមួយខ្ពស់មួយអំពីមោនភាពនៃទ្រឹស្តី *ស្តូអ៊ីហ្ស៊ីម* គឺអំណត់អត់ធន់ ទ្រឹស្តីនៃអំណត់អត់ធន់ ។

គឺថាដោយមានគំនិតនិងដើម្បីឈានទៅដល់មោនភាពនៃទស្សនអំណត់អត់ធន់និយមនេះ គឺថា

ទោះបីជាការងារលំបាកធ្ងន់ធ្ងរយ៉ាងណា បើជោគវាសនាតម្រូវឲ្យយើងត្រូវតែធ្វើហើយនោះ ពេលនោះ ដូចជារូបខ្ញុំទោះជាឈឺចាប់ ធ្វើយ៉ាងណាក៏ដោយការយំសោកមិនមែនជួយបានទេ ត្រូវស្តាប់មិនមាននិយាយមួយម៉ាត់ ។ ដូច្នេះ តាមដែលយើងយល់តាមកំណាព្យនេះ ជាមនុស្សដែលគាត់ក្លាយទៅជាពេជ្ឈឃាដនោះ គឺថា គាត់បានរៀនអំពីគ្រូបារាំងរបស់គាត់ដែរ អនុញ្ញាតឲ្យគាត់អាចសម្របសម្រួលជាមួយនឹងការងារដែលគាត់ត្រូវតែទទួល។ លោក ហាស្បែល លោកយល់ច្បាស់អំពីកំណាព្យ អំពីទស្សនៈអធននិយមនេះ ។ តើលោកយល់ដូចម្តេចអំពីឃ្លាកាព្យចុងក្រោយនេះ?

[១៤:៥៦:៣៩]

**ឆ៖** ខ្ញុំធម្មតា ខ្ញុំតែមានភាពរសើបនៅក្នុងការបញ្ជាក់អំពីគំនិតនៃកំណាព្យវគ្គនេះ ប៉ុន្តែទោះជាយ៉ាងណាក្តីគ្រាន់តែជាការសម្តែងនូវសេចក្តីប្រាថ្នាមួយនៃកវីនិពន្ធ *អាល់ហ្វ្រែត ឌឺ វិញ្ញី* តែប៉ុណ្ណោះ ។ គឺគាត់ធ្វើដើម្បីឲ្យសម្រេចបាននូវទីតាំង ឬក៏ជំហរមួយដែលថា បើមិនដូច្នោះ គឺមិនបានស្ថិតជាបុរសដែលប្រកបដោយកិត្តិយសនោះទេ ។

គឺធ្វើឡើងក្នុងនាមនៃហេតុការណ៍មួយ ដែលថា ជាហេតុការណ៍ដែលឃោឃៅកើតឡើងក្នុងជីវិតរបស់ម្នាក់នោះ ជននោះ ។ បើសិនជាជនជាប់ចោទ ក្នុងករណីជាឧទាហរណ៍ មានអារម្មណ៍ ឬក៏គាត់យល់ស្របជាមួយអ្វីដែលគាត់បានសូត្រនៅក្នុងកំណាព្យនោះ ។ គាត់នឹងត្រូវតែទទួលនូវការឈឺចាប់ផ្លូវចិត្តក្នុងការទទួលនូវទោស ឬខាងផ្លូវចិត្តក្នុងរយៈពេលដែលមានអំពើឃោឃៅដូចនឹងឆ្កែចចក ដែលចចកនោះ គឺថាដែលនៅក្នុងកាព្យមួយឃ្លានេះ គឺត្រូវបានដាក់ឲ្យស្ថិតនៅក្នុងស្ថានភាពមួយនៅក្នុងដែលថាមានធ្មេញដែរ ប៉ុន្តែមិនមាន-- ត្រូវបានគេខាំឲ្យហូរឈាម ប៉ុន្តែខ្លួនមិនអាចដកខ្លួនចេញបាន គឺការប្រយុទ្ធប្រឆាំងរបស់គាត់នោះ គឺថាយើងត្រូវតទល់ទៅនឹងការវាយប្រហារពីក្រុមផ្សេង ។ ប៉ុន្តែ នេះជាចំណុចមួយប្រហែលជាលោកនឹងព្យាយាមយល់អ្វីដែលខ្ញុំចង់និយាយនោះ ។

វាប្រហែលជាមិនអនុញ្ញាតឲ្យយើងមានការកំណត់បានទៅតាមសម្តីរបស់ជនជាប់ចោទ ប្រសិនបើយើងត្រូវពិនិត្យមើលស្ថានភាពរបស់គាត់នៅក្នុងការទទួលខុសត្រូវដែលគាត់មានខ្លួនគាត់ ហើយនិងគាត់ចាត់ការដោយខ្លួននោះ ។

[១៤:៥៨:៣៦]

**ស៖** សូមអរគុណលោកច្រើន ហើយខ្ញុំសូមបញ្ជាក់លោកថា ជនជាប់ចោទបានបញ្ជាក់ជាច្រើនលើកច្រើនសាចំពោះអង្គជំនុំជម្រះ ។ ខ្ញុំទទួលស្គាល់ជាមុននូវសាលក្រមដែលនឹងចេញមកនោះ ។ ដូច្នេះ

និយាយដោយចំទៅ គឺថាវានឹងនាំឲ្យមានចំណុចមួយដែលស្ថិតនៅក្នុងគំនិតខ្ញុំលោក ហាស្សែល ។

លោកបានរស់នៅឆ្លងកាត់សតវត្សរ៍ចុងក្រោយ ។ គាត់បានសរសេរសៀវភៅមួយដ៏ល្អនៅក្នុងទសវត្សរ៍នេះ ហើយលោកនៅក្នុងដំណើរការមួយនៅក្នុង-- ធ្វើដំណើរនៅក្នុងសតវត្សរ៍ថ្មីនេះ ចុងក្រោយនេះ លោកបានទទួលឆ្លងកាត់នូវស្ថានភាពដ៏រន្ធត់មួយដែលរំឭកឡើងពីខាងដើម ។ លោកផ្ទាល់ហ្នឹង ត្រូវបានគេជម្លៀសចេញ ហើយក្រៅពីអ្វីជាហេតុការណ៍អាក្រក់នោះ លោកមិនដែលបានជួបការតស៊ូនៅក្នុងពិភពលោកដើម្បីគាំទ្រនូវសិទ្ធិមនុស្ស ។ តើនេះមានន័យថា ក្រៅពីអំពើដ៏រន្ធត់នោះដែលលោកបានជួបប្រទះបានឃើញ? តើដែលលោកខ្លួនលោកផ្ទាល់បានប្រឈម? តើមានន័យទេ លោកបន្តមានជំនឿទៅលើបុរសនោះ?

**ឆ៖** ជាការពិត គឺដូច្នោះមែន ។ ខ្ញុំក៏ជឿផងដែរថា វាពិតជាមានការលំបាកខ្លាំងណាស់នៅក្នុងចេញសាលក្រមដែលធ្វើយ៉ាងណាឲ្យមានភាពត្រឹមត្រូវនិងគ្រប់គ្រាន់ នៅពេលដែលយើងធ្វើការសម្រេចទៅលើបុគ្គលិកលក្ខណៈរបស់បុគ្គលមួយរូប ដែលលក្ខណៈរបស់វាមានភាពលំបាកនិងស្មុគស្មាញ ។ ហើយខ្ញុំជឿជាក់ទាំងស្រុងទៅលើសាលាក្តីមួយនេះ ដែលសាលាក្តីមួយនេះបានស្តាប់នូវមតិយោបល់ និងសេចក្តីសន្និដ្ឋានទាំងខាងអយ្យការ និងខាងមេធាវីការពារក្តី ហើយខ្ញុំមានសេចក្តីជឿជាក់ថា សាលាក្តីមួយនេះនឹងចេញសាលក្រមមួយដែលមានភាពយុត្តិធម៌ ។ ហើយសាលាក្តីរូបនេះនឹងផ្តល់ជាគំរូមួយថាជាគំរូដែលបានធ្វើឡើងនៅក្នុងដើមសតវត្សរ៍នេះ ហើយដែលវាជាការធ្វើឡើងនៅក្នុងការស្វែងរកនូវយុត្តិធម៌ក្នុងប្រព័ន្ធព្រហ្មទណ្ឌអន្តរជាតិ ។

[១៥:០២:៥៤]

**ស៖** ខ្ញុំសូមសួរនូវសំណួរចុងក្រោយមួយទៀត ដែលលោកចង់សួរទៅលើបុគ្គលជនជាប់ចោទរូបនេះ ។ អ្នកជំនាញខាងវិកលចរិតនិងខាងចិត្តសាស្ត្របានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះកាលពីលើកមុន ។ ហើយពួកគេបានសម្ភាសន៍ជនជាប់ចោទកាលពីពីរឆ្នាំមុន និងពេលបច្ចុប្បន្នផងដែរ ហើយបានបញ្ជាក់ថា ជនជាប់ចោទបានវិវត្តន៍ពីស្ថានភាព *ឌីណាយអល* គឺការបដិសេធលើដំណាក់កាលទីមួយ ហើយគាត់ចូលមកដល់ដំណាក់កាលចុងក្រោយ គឺការចោទប្រកាន់ទៅលើខ្លួនឯង ។

អ្នកជំនាញបាននិយាយថា ពួកគេ-- ថាតើយើងអាចជួសជុលនិងស្តារឡើងលទ្ធភាពផ្លូវចិត្តយ៉ាងម៉េច? ហើយគាត់ក៏បានឆ្លើយទៅនឹងសំណួររបស់ខ្ញុំដែលគាត់និយាយអំពីមនុស្ស ហើយអ្នកជំនាញបានឆ្លើយថា-- ។ ហើយខ្ញុំបានសួរទៅអ្នកជំនាញ ថាតើអាចឲ្យបុរសម្នាក់ គាត់អាចកែខ្លួនរបស់គាត់ឡើង

វិញដែរឬទេ? ហើយលទ្ធភាពណាមួយដែលអាចឲ្យគាត់កែតម្រូវដែរឬទេ? ហើយដែលការកែតម្រូវ និងការស្តារខ្លួនរបស់គាត់ឡើងវិញនោះមិនប៉ះពាល់ទៅដល់យុត្តិធម៌?

**ឆ៖** នេះគឺជាសំណួរមួយដែលមានការលំបាក ។ វាជាសំណួរមួយដែលមានភាពស្មុគស្មាញ ។ នៅពេលដែលយើងពិចារណាទៅលើការឈឺចាប់របស់ជនរងគ្រោះ ការគិត និងស្រមើស្រមៃរបស់ជនរងគ្រោះ យើងមិនត្រូវទុកចោលនោះទេ ហើយវាមិនអាចលុបបាត់ចេញពីក្នុងអារម្មណ៍ចងចាំរបស់ពួកគេឡើយ ។ ជាពិសេសនូវអំពើទាំងឡាយដែលវាមានលក្ខណៈសាហាវយង់ឃ្នង ប្រព្រឹត្តដោយជនជាប់ចោទ ។ ដូច្នេះហើយ ខ្ញុំយល់យ៉ាងច្បាស់ថា ជនជាប់ចោទនឹងទទួលបាននូវផលប្រយោជន៍នូវអ្វីដែលគេបានលើកឡើង និងនិយាយអំពីគាត់ ។ ហើយជាពិសេសចំពោះជនទាំងឡាយដែលនាពេលនេះហាក់ដូចជានៅជុំវិញគាត់ ។

ខ្ញុំនៅតែមិនប្រាកដថា បុគ្គលដែលមានលក្ខណៈអត់ធន់និងស្មោះត្រង់ គាត់មានបំណងចង់បាននូវការស្តារលទ្ធភាព និងការវិនិច្ឆ័យឲ្យបានត្រឹមត្រូវចំពោះឧក្រិដ្ឋកម្មដែលខ្លួនគាត់ គាត់បានដឹងថាគាត់មានពិរុទ្ធភាព ។

[១៥:០៦:៥៥]

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោក ហាសែល សូមអរគុណលោកច្រើន ។ ហើយនេះហើយជាចម្លើយដែលគាត់បានសួរទៅកាន់ខ្លួនឯងផងដែរ ។ ជនជាប់ចោទគាត់សួរថា តើគាត់ធ្វើការផ្តល់នូវសំណងរបស់គាត់យ៉ាងម៉េច? ដែលគាត់បានប្រព្រឹត្តឡើងចំពោះសង្គម ហើយគាត់ចង់សងទៅលើអ្វីដែលបានប្រព្រឹត្តឡើងនៅក្នុងសង្គម ហើយគាត់បានទទួលស្គាល់ទៅលើចំណុចទាំងអស់នេះ ។ លោក ហាស្សែល ខ្ញុំសូមសម្តែងនូវសេចក្តីថ្លែងអំណរគុណយ៉ាងកក់ក្តៅចំពោះលោក ដែលលោកបានចូលរួមចំណែកនៅក្នុងពេលនេះ ហើយនិងចែករំលែកនូវការគិតពិចារណារបស់លោកទៅលើចំណុចនេះ ។

លោកប្រធាន ខ្ញុំពុំមានសំណួរផ្សេងទៀតសួរទៅកាន់លោកសាក្សីនោះទេ ។ សូមអរគុណ ។

**លោក ស្តេហ្វិន ហាស្សែល៖**

ខ្ញុំសូមសម្តែង និងនិយាយមួយពាក្យ ខ្ញុំសូមសម្តែងនូវការគោរពរបស់ខ្ញុំយ៉ាងជ្រាលជ្រៅ ។ ដូចដែលលោក លោកស្រី និងមេធាវីការពារក្តីដែរ ខ្ញុំសូមសម្តែងនូវការគោរពដែលអស់លោក លោកស្រីបានសម្តែងនូវទេពកោលស្យរបស់លោកជួយទៅដល់ការងារនៅក្នុងនេះ ។ ហើយជាពិសេស ខ្ញុំសម្តែង

នូវការគោរពដល់មេធាវីការពារក្តី ដែលធ្វើការការពារនូវជនមួយរូបដែលគាត់មានលក្ខណៈពិបាកចំពោះឧក្រិដ្ឋកម្មដែលគាត់បានប្រព្រឹត្តឡើង ។ សូមអរគុណ ។

[១៥:០៨:៣៨]

**ប្រធានអង្គជំនុំ៖**

ជាកិច្ចនេះ អង្គជំនុំជម្រះផ្តល់វេទិកាទៅជនជាប់ចោទ ដើម្បីមានឱកាសក្នុងការធ្វើការសង្កេតនូវសេចក្តីថ្លែងការណ៍របស់អ្នកជំនាញ ប្រសិនបើលោកមានបំណង សូមអញ្ជើញ ។

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន ខ្ញុំសូមអរគុណប្រធានដែលបានអនុញ្ញាតឲ្យខ្ញុំនិយាយទៅរកព្រឹទ្ធាចារ្យ ស្តេហ្វិន ហាស្សែល ។ ខ្ញុំសូមថ្វាយបង្គំលោកព្រឹទ្ធាចារ្យ ស្តេហ្វិន ហាស្សែល ពីចម្ងាយ ដោយសេចក្តីគោរពយ៉ាងជ្រាលជ្រៅបំផុតចំពោះវិចារណញ្ញាណទាំងប៉ុន្មាន ដែលលោកបានធ្វើសក្ខីកម្មនៅទីនេះ ។ វាជាមេរៀនដ៏ថ្លៃថ្លាសម្រាប់ខ្ញុំ ខ្ញុំសូមគោរពទទួលដោយស្មោះ ។

សូមអរគុណលោកព្រឹទ្ធាចារ្យពីចម្ងាយ ។ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដំណើរការនៃការស្តាប់នូវសក្ខីកម្មសាក្សីអ្នកជំនាញ ហាស្សែល ឃើញថាដល់ទីបញ្ចប់ហើយ ។ ហើយអង្គជំនុំជម្រះសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកអ្នកជំនាញ ហាស្សែល ដែលបានផ្តល់សក្ខីកម្មក្នុងនាមជាអ្នកជំនាញ តាមការស្នើសុំ និងតាមការកោះអញ្ជើញរបស់អង្គជំនុំជម្រះ ហើយក៏សូមអរគុណផងដែរចំពោះលោកស្រីមេធាវីដែលនៅអមលោកជំនាញ ហាស្សែល ដែលបានសម្រួលឲ្យកិច្ចដំណើរការនៃការធ្វើសវនាការពីចម្ងាយរវាងទីតាំងដែល ទីកន្លែងសាក្សីស្នាក់នៅ ហើយជាមួយនឹងអង្គជំនុំជម្រះបានប្រព្រឹត្តទៅបានល្អ ។ ហើយអង្គជំនុំជម្រះសូមអរគុណ និងសូមជម្រាបលាអ្នកជំនាញ ។

**លោក ស្តេហ្វិន ហាស្សែល៖**

សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ម៉ោងប្រកាសសម្រាកម្ភៃនាទី គឺចាប់ពីពេលនេះទៅរហូតដល់ម៉ោងបីនិងសាមសិបនាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១៥:១១នាទី ដល់ម៉ោង ១៥:៣១នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការរបស់យើងតទៅទៀត ហើយសវនាការជាបន្តនេះ គឺបន្តស្តាប់ចម្លើយជនជាប់ចោទអំពីអត្តចរិតរបស់គាត់ ។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទមកកាន់ឈើរាងវង់ក្រចកសេះ រៀបចំទុកនៅចំពោះមុខអង្គជំនុំជម្រះនេះ ។

*(ជនជាប់ចោទធ្វើដំណើរទៅកាន់ឈើរាងក្រចកសេះ)*

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តអង្គជំនុំជម្រះសូមប្រគល់-- យើងខ្ញុំសូមប្រគល់នូវវេទិកាជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដែលកាលពីព្រឹកមិញ លោកមានសំណួរសួរចំពោះជនជាប់អំពីអត្តចរិតនេះ ឃើញថាមិនទាន់អស់សំណួរនៅឡើយទេ ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍ ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

សូមអរគុណលោកប្រធាន ។

**ស៖** ព្រឹកមិញនេះ យើងបានព្យាយាមបំភ្លឺនូវចំណុចមួយថា តើមានបញ្ហាអ្វីកើតឡើងចំពោះកៅលីថុងហ្គួត ជាប្អូនថ្លៃរបស់លោកដែលថានៅស-២១ ។ ខ្ញុំក៏បានព្យាយាមយល់អំពីមូលហេតុ ហេតុអ្វីបានជាប្អូនថ្លៃរបស់លោកត្រូវបានគេចាប់ខ្លួន ឃុំខ្លួន ហើយទទួលទារុណកម្ម ហើយត្រូវបានគេសម្លាប់នោះ ។

ចំណុចមួយដែលខ្ញុំមិនទាន់យល់ច្បាស់នៅព្រឹកមិញនេះ គឺថាចាប់ខ្លួនរបស់គាត់ត្រូវបានសម្រេចឡើងដោយលេខាភូមិភាគ គឺត្រូវធ្វើឡើងតាមនយោបាយរបស់កប្បកុម្មុយនីស្តកម្ពុជា ហើយលោកមិនបានតវ៉ានឹងការចាប់ខ្លួននោះទេ ។ តើយើងអាចនិយាយថា លោកមិនបានជំទាស់ក្នុងការចាប់ខ្លួនប្អូនថ្លៃលោកនោះ? ដែលថាការមិនបានតវ៉ានោះមានន័យថា លោកចូលរួមក្នុងការងារនោះទៀត គឺលោកបាន

បញ្ជូនរបាយការណ៍ទៅថ្នាក់លើរបស់លោក ។

នៅក្នុងការវិភាគចុងក្រោយ តើយើងអាចដឹងច្បាស់ទេ អំពីតើហេតុផលអ្វីជាក់លាក់ជាមូលហេតុនៃការចាប់ខ្លួនប្អូនថ្លៃរបស់លោកដែរឬទេ? ឬក៏មិនមានមូលហេតុអ្វីទេ? ហើយការចាប់ខ្លួននោះ គឺត្រូវបានសម្រេចឡើងដោយមេបញ្ជាការភូមិភាគ ឬក៏លេខាភូមិភាគនោះ ។

[១៥:៣៤:១៩]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ជាសតិអារម្មណ៍អង្គការវិន័យរបស់បក្ស បក្ខជនគ្រប់រូបមិនមានសិទ្ធិដេញដោលហេតុផលអ្វីបានជាលេខាភូមិភាគសម្រេចចាប់អ្នកណា ឬអ្នកណាទេ ។ នេះជាការពិត នេះជាកិច្ចប្រតិបត្តិ ។ គ្មានអ្នកណាល្មើសបានទេ ។ ខ្ញុំទទួលសំបុត្រពីប្អូន អត់មានគិតគូរថាតើត្រូវដេញដោលខុសរឿងអី? ត្រូវរឿងអីទេ? គិតតែថាធ្វើម៉េចលៃលកជួយប្អូនរួច ឬមិនរួច សង្ឃឹមថាជួយរួចតិចណាស់ ។ នេះជារឿងពិត ។

ខ្ញុំសូមអនុញ្ញាតជូនបញ្ហាមួយទៀត ក៏ប៉ុន្តែតែរឿងនេះវានៅក្នុងសំណុំរឿងលេខ០០២ ។ បើសិនជាលោកចៅក្រមអនុញ្ញាតឲ្យខ្ញុំនិយាយ ខ្ញុំសូមនិយាយបញ្ហានេះបន្តិច ។

**សៈ** ខ្ញុំចង់បញ្ចប់ពីរឿងរ៉ាវរបស់ប្អូនថ្លៃរបស់លោកសិន លោកបាននិយាយថា គេធ្វើទារុណកម្មគាត់នោះ ហើយខ្ញុំច្បាស់ថា លោកបានអានដោយយកចិត្តទុកដាក់អំពីសេចក្ដីលម្អិត ជាពិសេសគឺសេចក្ដីសារភាពរបស់ប្អូនថ្លៃលោកនោះ ។ តើចម្លើយសារភាពនោះ តើគាត់បានសារភាពពីរឿងអ្វីដែរ?

**ឆ៖** រឿងនេះខ្ញុំភ្លេចអស់ទៅហើយ ក៏ប៉ុន្តែខ្ញុំសូមរំឭករឿងដែលខ្ញុំនៅចាំខ្លះៗ ។ វាសារភាពថាវាជាបុគ្គលិកខ្មាំងមុនឆ្នាំ១៩៧០ ហើយត្រូវគេចាត់តាំងឲ្យមកដណ្ដឹងប្អូនខ្ញុំក្រោយពេលដែលខ្ញុំជាប់គុក ។ ដូច្នេះ វាក៏មកដណ្ដឹងប្អូនខ្ញុំហ្នឹងទៅ នេះរឿងដែលខ្ញុំនៅចាំ ។ ហើយរឿងដែលវាភ័យជាសំខាន់ដែរ នេះវាជាសតិអារម្មណ៍របស់មនុស្សម្នាក់ទៅវិញទេ ។ វាថា ពេលដែលគេចាប់វាដាក់ខ្នោះ វាសួរថា គេចាប់ខ្ញុំក៏អត់? បើគេចាប់ខ្ញុំ គឺអស់ហើយមួយពូជហ្នឹង ។ នេះនៅក្នុងស-២១ វាសរសេរចារប៉ុណ្ណឹង ក្រៅពីនោះខ្ញុំភ្លេចរឿងល្អិតអស់រលីងហើយ ។

**សៈ** តើៗនៅក្នុងខ្សែបណ្ដាញណាមួយ តើនៅក្នុង កាហ្សេបេ ឬក៏ សេអ៊ីអា? តើលោកគិតថាការសារភាពរបស់គាត់នោះ គួរឲ្យជឿបានទេ? តើលោកជឿទេកាលនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! បញ្ហានេះខ្ញុំពិបាកឆ្លើយណាស់ បើនិយាយឲ្យតាមពិត ខ្ញុំជឿប្រហែលត្រឹមសាមសិបភាគរយប៉ុនន៉ុងទេ មិនដល់ផង ម្ភៃភាគរយទេ ។ នេះសូមជម្រាបដោយ

ស្មោះត្រង់អ៊ីចឹង ។

**សៈ** តើមានបញ្ហាអ្វីកើតឡើងចំពោះប្អូនស្រីរបស់លោក ហើយនិងកូនរបស់គាត់នោះ?

**ឆៈ** ជម្រាបប្រសាសន៍លោកចៅក្រម! ប្អូនរបស់ខ្ញុំ ខ្ញុំទុក ។ ប្អូនរបស់ខ្ញុំមិនមែនជាបក្ខជនទេ តែជាសម្ព័ន្ធយុវកក ។ ដល់ក្រោយមក ខ្ញុំឱ្យទៅរៀនខាងវិធីចិញ្ចឹមកុមារ ហ្នឹងគេនិងឯង ឱ្យមានមុខការឡើង ។ មកនៅក្នុងក្របខ័ណ្ឌស-២១ ដែលខ្ញុំទុកជាបុគ្គលិករបស់ខ្ញុំហើយ ។

**សៈ** ហើយយើងពិនិត្យឃើញថា តើប្អូនស្រីរបស់លោកហើយនិងកូនរបស់គាត់ ឬប្អូនថ្លៃរបស់លោកដែលថា នៅក្នុងផ្ទះរបស់លោកក្នុងពេលដែល ស-២១ កំពុងតែដំណើរការហ្នឹងដែរឬទេ?

**ឆៈ** មិននៅក្នុងផ្ទះរបស់ខ្ញុំទេ ។ នៅផ្ទះផ្សេងទៀត ។

**សៈ** តើអាចនឹងធ្វើម៉េចទៅនឹងកើតដោយថាគោលការណ៍មួយចំនួននោះមានន័យថា នៅពេលដែលត្រូវដកស្មៅ គឺត្រូវដកទាំងឫស ។ តើក្នុងករណីនេះ តើគេអនុវត្តគោលការណ៍ហ្នឹងទេ? ហេតុអ្វីបានតែមានតែប្អូនថ្លៃប្រុស ប៉ុន្តែប្អូនស្រី និងកូនគឺនៅរស់? តើលោកមានអំណាច និងអន្តរាគមន៍ដែរឬទេ? ឬក៏លោកមានការភ័យខ្លាចអំពីសុវត្ថិភាពផ្ទាល់ខ្លួនដែរឬទេ?

**ឆៈ** វាមានបញ្ហាបីរួមបញ្ចូលគ្នា ។ ទីមួយ មនោសញ្ចេតនារបស់ខ្ញុំជាបងទៅលើប្អូន ។ ទីពីរ ខ្ញុំខ្លួនឯងគិតថា បើសិនជាចាប់ប្អូនទៅ វាជារឿងមួយដែលចៀសមិនរួចពីដល់ខ្ញុំឆាប់ជាង១ ខ្ញុំទុកប្អូន ។ ក៏ប៉ុន្តែរឿងមួយទៀត គឺខ្ញុំចេញមុខការពារថា ប្អូនខ្ញុំ ខ្ញុំអប់រំពីដើមមកមិនអីទេ វាផ្សេង ប្ដីវាផ្សេង ។ អានេះក្នុងឋានៈជាបក្ខជនមួយនៅមានសិទ្ធិ នៅមានអំណាច នៅមានភារកិច្ច អាចចេញមុខការពារបុគ្គលដែលខ្លួនអប់រំបាន បុគ្គលដែលខ្លួនអប់រំ ។ ឯចំណែក បុគ្គលទៅខាងលើវិញ គឺខ្ញុំគ្មានសិទ្ធិការពារគេទេ ឯចំណែកបុគ្គលដែលខ្ញុំអប់រំផ្ទាល់ ខ្ញុំមានសិទ្ធិការពារ ។ មិត្តប៉ុន ខ្ញុំមានសិទ្ធិការពារ ។ នេះជាការអនុវត្តនៅជំនាន់នុ៎ង ។

**សៈ** តើប្អូនថ្លៃប្រុសរបស់លោក គឺមានឋានៈទាបជាងលោកឬទេ? តើលោកមិនទុកចិត្តអ្នកទាំងនោះ ឬដូចម្ដេច?

[១៥:៤៤:០៦]

**ឆៈ** ទុកចិត្តវាជារឿងមួយ ។ ក្នុងឋានៈជាសាច់ជាឈាមហើយវាពិតជាមានការទុកចិត្ត ក៏ប៉ុន្តែវាផ្លូវបក្ស វាមិនមែនជាមនុស្ស ដែលខ្ញុំអប់រំខាងទ្រឹស្ដីបដិវត្តន៍ទេ ។ អ្នកផ្សេងគេអប់រំ ។ ហើយសូមបញ្ជាក់ថា អ្នកផ្សេងដែលអប់រំវាហ្នឹងចាប់មកស-២១ ហើយ មិត្តស្រ៊ុន លេខាស្រុកស្មោង ។ រួចទៅ

ហើយៗ ។ ចាប់រួចទៅហើយ ចាប់មក ស-២១ មុនវារួចទៅហើយ ។

[១៥:៤៥:១៥]

**ស៖** ដូច្នេះ ឥឡូវនេះ យើងនិយាយអំពីប្អូនថ្លៃប្រុសមួយទៀត ឈ្មោះ សៀប សាខន តើភារកិច្ចជាក់ស្តែងពិតប្រាកដរបស់គាត់អ្វី? ហេតុអ្វីបានជាគេចាប់ខ្លួនគាត់? ហេតុអ្វីបានជាគេសម្លាប់គាត់? តើអ្នកណាជាអ្នកសម្រេចថាត្រូវសម្លាប់គាត់នោះ?

**ឆ៖** ប្អូនថ្លៃទីមួយរបស់ខ្ញុំនេះ ឈ្មោះ សៀប សាខន ជាកូនស្រុកកូនភូមិជាមួយនឹងខ្ញុំ។ វាធ្វើការនៅខាងពាណិជ្ជកម្មនៅក្នុងតំបន់កំពង់ធំដែរ ។ រឿងចាប់វានេះ ខ្ញុំគ្រាន់តែប៉ាន់ប្រមាណបានទេ រហូតដល់៨១ ដែលខ្ញុំទៅជួបថ្វាយបង្គំម្តាយខ្ញុំ បានខ្ញុំដឹងរឿងនេះពិតថាគេចាប់ៗ ហើយគេច្រកបាវយកទៅបាត់ ប្អូនខ្ញុំទៅតាមរក តាមរកមិនដឹង បាត់ដាន ។ ប៉ុន្តែ ប្អូនខ្ញុំគាប់ចួនល្អដែរ គេមិនធ្វើអីវា ។ ជាគោល-ការណ៍តែគេចាប់ប្តីហើយ ប្រពន្ធមកហើយ ទៅទាំងប្រពន្ធទៅទាំងកូន ក៏ប៉ុន្តែនេះគេចាប់តែប្តីទេ ប្អូនខ្ញុំនៅៗរាល់ថ្ងៃនេះ ។

ដូច្នេះ រឿងអីដែលគេចាប់ ខ្ញុំមិនដឹង អ្នកណាចាប់? ខ្ញុំសន្និដ្ឋានថា បង ពក ចាប់ ។ បងពក នេះ គឺ កែ ពក ។ ដែលហៅថាចាប់នេះ គឺបានន័យថា គាត់សម្រេច ហើយចំណែកដែលចាប់ហើយស្ងៀមមិនឲ្យប្អូនខ្ញុំដឹង មិនឲ្យអីដឹង មិនឲ្យលេចឮដំណឹងអីបន្តិចបន្តួច ដល់ខ្ញុំ គឺខ្ញុំគិតថា ជាឃោបល់ពីខាងលើពី សុន សេន ឬក៏ពី ប៉ុល ពត ។ មិនមែនបានន័យថា គេប្រាប់ទេ គេត្រូវតែប្រាប់ទេ គ្រាន់តែដំណឹងបន្តិចលេចដល់ខ្ញុំក៏អត់លេចដែរ ។

**ស៖** តាមទស្សនៈរបស់លោក អង្គហេតុដែលបញ្ជាក់មិនមានប្អូនស្រីណាម្នាក់របស់លោក ហើយក្មួយប្រុសក្មួយស្រីត្រូវបានគេចាប់ខ្លួននោះ គឺជាព័ត៌មានមួយដែលផ្ទុយ ដែលទាក់ទងទៅនឹង ឬក៏តាមអង្គហេតុ ដែលថាប្អូនស្រី ក្មួយប្រុស ក្មួយស្រី លោកបាន-- គេរស់នៅបានដោយសារថា លោកមានតំណែងមួយខ្ពស់នៅក្នុងបក្សនោះ? តើអ៊ីចឹងដែរឬទេ?

**ឆ៖** បញ្ហានេះ វាសុទ្ធជាបញ្ហាវិភាគនិងសន្និដ្ឋាន ។ ខ្ញុំសូមសន្និដ្ឋានតាមការវិភាគរបស់ខ្ញុំដូចតទៅ៖

ការដែលចាប់ប្អូនថ្លៃលើកទីមួយរបស់ខ្ញុំ ខ្ញុំមានប្រតិកម្មមិនពេញចិត្ត ។ ខ្ញុំតបតដោយខ្ញុំព្រងើយកន្តើយ មិនអនុវត្តភ្លាមៗតាមគោលការណ៍ ទាល់តែគេព្រមានម្តងយ៉ាងធ្ងន់ធ្ងរ ហើយទាល់តែមានភេទ

លេចចេញ បានៗខ្ញុំបញ្ជាឲ្យគេធ្វើ ។

[១៥:៥០:១៣]

ដូច្នេះ ខ្ញុំជឿថា តាមការវិភាគបែបនេះ ខ្ញុំជឿថា គេចេះស្អុំកុំឲ្យខ្ញុំហ្នឹងវាច្រឡោតខ្លាំងពេក ។ គេទុកប្រមូលសំណុំរឿងជុំវិញរឿងខ្ញុំនេះ ដល់កាលណាគេចាប់ខ្ញុំ អាហ្នឹងបានវាទៅទាំងអស់ ។ របៀបគេធ្វើការអ៊ីចឹង គេទុកប្រមូលសំណុំរឿងសិន ។ នេះតាមការវិភាគ ។

ខ្ញុំសូមបញ្ជាក់ថា ក្នុងរយៈកាលនុ៎ងខ្ញុំភ័យណាស់ហើយ ភ័យដោយធ្វើការប្រៀបធៀបខ្លួនឯងទៅនឹង បង ង៉ែត យូ ហៅ ហុង ។ ហើយភ័យទីពីរ ខ្ញុំមានប្រភពមកពីឧត្តរ ហើយពួកឧត្តរគេចាប់ឡើងរីង ។ ហើយភ័យសំខាន់មែនទែន គឺរឿងខ្មាំង នែ៎! មានអ្នកទោសឆ្លើយដាក់ សុន សេន ។ ខ្ញុំគិតថាគាត់មិនមែននៅស្ងៀម ទុកបណ្តោយឲ្យខ្ញុំធ្វើតាមចិត្តទេ គាត់គង់តែរកវិធីកាច់ខ្ញុំ ។ ដូច្នេះ ភ័យណាស់ខ្ញុំកំពុងតែភ័យ ។ ដូច្នេះរឿងនេះ បានៗជាខ្ញុំសន្និដ្ឋានថា គេទុកប្រមូលរឿងឲ្យជុំ ល្មមតែខ្ញុំគ្រប់សំណុំរឿង គេកាច់ខ្ញុំបណ្តោយ អស់ហើយមួយពូជហ្នឹង ។ នេះខ្ញុំសូមជម្រាបបញ្ជាក់ប៉ុណ្ណឹង ។ នេះជាសេចក្តីសន្និដ្ឋាន ។

**ស៖** តើយើងអាចនិយាយបានទេថា លោកជាមនុស្សដែលដឹងរឿងច្រើនណាស់ ហើយថា គឺមានចំណុចមួយដែលថាមានការប្រឹងប្រែងមកពីក្រៅ កុំធ្វើឲ្យលោករំខាន ហើយកុំឲ្យលោកដឹង? តើអ៊ីចឹងមែនឬទេ?

**ឆ៖** ខ្ញុំពិបាកឆ្លើយណាស់។ ខ្ញុំដឹងរឿងច្រើនដោយសារតែនៅខាងសួរចម្លើយតែប៉ុណ្ណឹងឯងទេ។ ដូច្នេះ មិនអាចនឹងធ្វើឲ្យគេមិនខឹងនោះទេ ។ សុន សេន គាត់ខឹងនឹងខ្ញុំរួចទៅហើយ ។ គាត់ដឹងរឿងខ្ញុំបណ្តោយឲ្យខ្មាំងឆ្លើយដាក់គាត់ ។

**ស៖** តើបងប្អូនថ្លៃប្រុសផ្សេងៗទៀត មានឋានៈអ្វី ឬក៏តួនាទីអី ដែលមានការទទួលខុសត្រូវនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆ៖** ប្អូនថ្លៃទីបីរបស់ខ្ញុំ ឈ្មោះ ពេជ ក្រោយ១៧ មេសា បន្តិច វាជាលេខាវរសេនាតូចនៅក្នុងកងពល៤៥០ ។ ដល់ក្រោយមកឮថា-- ដល់ក្រោយមកគេបញ្ជូនវាទៅនៅធ្វើព្រលានយន្តហោះកំពង់ឆ្នាំងនេះ។ ដល់ទៅធ្វើព្រលានយន្តហោះនៅកំពង់ឆ្នាំមួយរយៈ ក៏បញ្ជូនឲ្យមកនៅស-២១ ហើយគេប្រាប់ថា កុំប្រគល់ភារកិច្ចអីឲ្យ ។ មានន័យថា គេដកសិទ្ធិជាបក្ខជនរបស់វាបាត់ទៅហើយ ។ ដូច្នេះ នៅចុងបញ្ចប់ប្រពន្ធខ្ញុំក៏គេដកចេញមន្ទីរពេទ្យ ។ ប្អូនខ្ញុំមេម៉ាយៗ អ៎មិនមែន មេម៉ាយម្នាក់ក៏នៅនឹងជាមួយខ្ញុំ

ហើយប្អូនម្នាក់ដែលប្តីចេញមកពីធ្វើខាងកំពង់ឆ្នាំងក៏មកនៅជាមួយនឹងខ្ញុំ នៅនុ៎ង អត់មានការងាអីទេ ។ មានតែប្អូនមួយ ដែលខ្ញុំនៅរក្សាទុកជាយុវកក ហើយឱ្យទៅរៀនខាងចិញ្ចឹមទារក ។

[១៥:៥៦:៣៤]

**ស៖** តើលោកអាចប្រាប់យើងបានទេ ថាមានអ្វីកើតឡើងនៅព្រលានយន្តហោះខេត្តកំពង់ឆ្នាំ? តើងាយស្រួលទេការងារនៅកន្លែងនោះ? ឬក៏ជាកន្លែងដែលអ្នកទាំងអស់នោះមិនមានសិទ្ធិដើរហើរដោយសេរីបាន?

**ឆ៖** សូមជម្រាបប្រសាសន៍លោកចៅក្រម! ព្រលានយន្តហោះកំពង់ឆ្នាំងនេះ ជាកន្លែងដែលគេហៅថា គុកអត់ជញ្ជាំងនោះ ។ មិនមានអ្នកណាដើរទៅណាបាន ដូចជាកន្លែងប្រមូលផ្តុំគ្រប់កន្លែងអ៊ីចឹង ហើយការងារព្រលានហ្នឹងសុទ្ធជាការងារពលកម្ម ហើយការងារលំបាកបំផុត ។ ដូច្នេះ អត់មាននេះទេ ពិបាកណាស់ ។

**ស៖** តើការងារអ្វីដែលពិតប្រាកដនោះ ដែលប្អូនថ្លៃរបស់លោកធ្វើការនៅកន្លែងព្រលានយន្តហោះនោះ?

**ឆ៖** ទៅគឺគ្រប់គ្រងអង្គភាពនុ៎ង ដែលធ្វើការនៅក្នុងព្រលានហ្នឹង ហើយខ្ញុំសូមបញ្ជាក់ម្តងទៀតបន្ថែមទៀតថា អ្នកដែលគេបញ្ជូលទៅក្នុងព្រលាន អង្គភាពណាដែលគេបញ្ជូលទៅក្នុងព្រលាន គឺវាមានលក្ខណៈជាពាក់កណ្តាលអ្នកទោសរួចទៅហើយ ដូចនៅព្រៃសអ៊ីចឹង ។

**ស៖** តើប្អូនថ្លៃប្រុសរបស់លោក តើគាត់ជាអ្នកទោស ឬគាត់ជាអ្នកមើលការខុសត្រូវលើអ្នកទោសនោះ? តើអង្គភាពណាដែលគាត់ជាអ្នកមើលការខុសត្រូវនៅទីនោះ?

[១៦:៥៩:៣៧]

**ឆ៖** សូមបញ្ជាក់ថា កងពល៤៥០ មកពីឧត្តរ ដំបូងគេចាប់មិត្ត សួង លេខាកងពល ។ គេចាប់មិត្តយ៉ាន់ ។ មិត្តយ៉ាន់ អនុលេខាកងពល ហើយគេយក មិត្តវិន កូនប្រសារ តាម៉ុក យកទៅដាក់ ។ ហើយគេចាប់កម្មាភិបាល វរសេនាធំ វរសេនាតូចមកច្រើន ។ ដូច្នេះ វរសេនាតូចខ្លះនៅក្នុងកងពលនោះគេយកទៅទុកជង្រែស្រែនោះ ក្នុងឋានៈជាពាក់កណ្តាលអ្នកទោស អ៊ូ! ឯព្រលានយន្តហោះនោះទុកជាពាក់កណ្តាលអ្នកទោសហើយ ។ ហើយទៅដំបូងហ្នឹងប្អូនថ្លៃខ្ញុំទៅជាកម្មាភិបាលដែលពាក់កណ្តាលអ្នកទោសគ្រប់គ្រងអ្នកទោស ពាក់កណ្តាលអ្នកទោសហ្នឹងដែរ ។ ដល់ក្រោយមកអ្នកទទួលខុសត្រូវព្រលានហ្នឹងគេមិនទុកចិត្តប្អូនខ្ញុំ គេដកមក គេដាក់ពួកនិរតីទៅជំនួសវិញ ។

**ស៖** ថាតើវាជាគោលការណ៍ ឬក៏យ៉ាងម៉េច? នៅពេលដែលយើងត្រូវកាប់ឫស្សី យើងត្រូវឆ្ការបន្លាផងដែរ ដូច្នេះហើយថាតើលោកបានចូលរួមអនុវត្តគំរូ ឬជួយទៅដល់ប្អូនថ្លៃប្រុសរបស់លោកដែរឬទេ?

**ឆ៖** ទ្រឹស្តីកាប់ឫស្សី មុននឹងកាប់ឫស្សីត្រូវត្រាយបន្លា គេអនុវត្តចំពោះ កុយ ធួន ។ ដល់គេបាន កុយ ធួន ហើយ គេស្រាយអ្នកក្រោម ។ ដូច្នេះទ្រឹស្តីមុននឹងកាប់ឫស្សីត្រូវត្រាយបន្លាគេប្រើគ្រប់អង្គភាព មុននឹងចាប់ ចាន់ ចក្រី គេចាប់ យិន សម្បត្តិ អ្នកបោកគ្រាប់បែកក្រោយវាំង ។ មុននឹងចាប់ កុយ ធួន គេចាប់ មិត្តអឿន ប្រធានកងពលលេខ៣១០ សិន ។ មុននឹងចាប់ មិត្តអឿន គេចាប់អ្នកផ្សេងទៀត ដូចជាអ៊ី ស៊ីនួន ខាងស្រាខាងអ៊ីនុំងពេញពាសទៅបានគេទៅចាប់ មិត្តអឿន ហើយចាប់ កុយ ធួន ។ ដល់ចាប់ កុយ ធួន មកគេចាប់អ្នកណាដែលនៅក្រោម កុយ ធួន ដែលគេសង្ស័យប៉ុន្មានដែលជិតស្និទ្ធនឹង កុយ ធួន ប៉ុន្មានគេចាប់ ។ ខ្ញុំគិតថា សំណួរលោកចៅក្រម ត្រឹមត្រូវម្យ៉ាងហើយ ។ ប្អូនខ្ញុំដែលគេមិនឲ្យចាប់ភ្លាម គេយកមកឲ្យទុកនៅជាមួយនឹងខ្ញុំដោយគ្រាន់តែដកសិទ្ធិបក្ខជនចេញក៏គេគិតដល់ខ្ញុំសិនហ្នឹងដែរ ។ ដូច្នេះ ទម្រាំតែគេប្រមូលរឿងបានអាហ្នឹងជារឿងរបស់គេមួយផ្សេងទៀត ។

**ស៖** ថាតើលោកធ្វើការធានាទៅដល់គាត់ ហើយលោកទទួលការងារតាមដានទៅលើគាត់ ហើយតើលោកមានរាយការណ៍ទៅថ្នាក់លើនូវសកម្មភាពរបស់ប្អូនថ្លៃរបស់លោក និងអ្វីដែលប្អូនថ្លៃរបស់លោកគិតដែរឬទេ?

**ឆ៖** អាប្អូនថ្លៃទីមួយដែលមកដំបូង អាធឿន ខ្ញុំឲ្យវាទៅនៅនឹងកន្លែងមួយគឺកន្លែងចម្លងផែនទី ផែនទីខ្នាតមួយរយពាន់នោះខ្ញុំឲ្យវាចម្លងជាមួយនឹងគេ ជាមួយនឹងឯងនៅហ្នឹងឲ្យមានការងារធ្វើ ។

[១៦:០៥:២៣]

ហើយអាទីពីរដែលមកនេះខ្ញុំយកទៅឲ្យនៅជាមួយ មិត្តហ៊ុយ ក្រោយមកនៅជាមួយមិត្តផល ។ ឯចំណែកប្អូនខ្ញុំ ខ្ញុំឲ្យនៅជាមួយនៅភ្នំពេញ ។

**ស៖** លោកមិនបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំនោះទេ ថាតើលោកបានធានាចំពោះប្អូនថ្លៃរបស់លោកដែរឬទេ? ដែលគាត់ជិតស្និទ្ធជាមួយនឹងលោក ហើយបានចូលទៅដល់ស-២១ ប៉ុន្តែមិនត្រូវបានគេឃុំខ្លួននៅស-២១?

**ឆ៖** ជាគោលការណ៍យើងក្នុងឋានៈជាដឹកនាំត្រូវតែមានវិធានការមួយកុំឲ្យវាបំផ្លាញអង្គភាពហ្នឹងបាន ។ ដូចអាប្អូនខ្ញុំ អាដំបូងនោះ ខ្ញុំដាក់ឲ្យនៅចម្លងផែនទីទេ ក៏ប៉ុន្តែវារលោរលាំៗ ព្រោះវាធ្លាប់ធ្វើ

នគរបាល វាធ្លាប់អានសេចក្តីសារភាព ដូច្នេះវាចង់បានសេចក្តីសារភាពយកមកអាន វាទាមទារគេអាន វាទាមទារអី វាធ្វើសកម្មភាពហ្នឹង ។ ហើយសូម្បីតែជាមួយនឹងក្មេងស្រីៗក៏វារាងរលោរលាំដែរដល់បន្តិច ដែរ ។ ដូច្នេះ ដោយមានការកំហែងរបស់ សុន សេន ផង ដោយអាកប្បកិរិយាវារបៀបនេះផង ខ្ញុំមិនបានទុកតទៅទៀត ខ្ញុំឲ្យគេចាប់ ។ ឯចំណែក អាប្អូនថ្លៃទីពីរ ខ្ញុំទុកចោលឯស្រែអត់មានបាតុភាពអីទេ រត់ទៅជាមួយនឹងខ្ញុំ ។

**ស៖** ប្រសិនបើខ្ញុំយល់ត្រឹមត្រូវទៅលើចម្លើយរបស់លោក ជាក់ស្តែងនោះគឺមិនមែនប្អូនថ្លៃរបស់លោកតែម្នាក់ទេ ដែលជាប់នៅស-២១ គឺមានពីរនាក់ តើអ៊ីចឹងមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ប្អូនថ្លៃដែលកម្ទេចនៅស-២១ មានតែម្នាក់ទេ ឈ្មោះ កៅលី ផុងហួត ។ សៀប សាខន បងពក កម្ទេចនៅឯកំពង់ធំ ។ ឯចំណែក ពេជ គេដកឋានៈវាយកមកទុកជាមួយនឹងខ្ញុំ ហើយរត់ទៅជាមួយនឹងខ្ញុំទៅស្លាប់តាមផ្លូវជាមួយនឹងប្រពន្ធកូនវា ។

**ស៖** ដូច្នេះ វានៅដូចនៅខ្វះមួយទៀត។ ថាតើប្អូនថ្លៃប្រុសដែលបន្ទាប់ពីលោកនោះ ថាតើមានអ្វីកើតឡើងចំពោះគាត់ ដែលថា សុន សេន ហ្នឹងគាត់និយាយថា គាត់មានប្រព្រឹត្តអំពើមិនខុសឆ្គងចំពោះស្ត្រី តើមានអ្វីកើតឡើងចំពោះគាត់?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! អាហ្នឹងហើយឈ្មោះ កៅលី ផុងហួត ហៅ ធឿន ។

**ស៖** ពេលវេលាចេះតែកន្លងទៅហើយ ហើយខ្ញុំចង់សួរទៅលើសំណួរមួយទៀត ។ តើលោកអាចពន្យល់បានដែរឬទេ ដែលលោកមានគ្រោះថ្នាក់នៅដៃឆ្វេងរបស់លោក តើមានអ្វីកើតឡើងនៅលើដៃឆ្វេងរបស់លោកនោះ?

[១៦:១១:០៩]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ដៃនេះរបួសនៅឆ្នាំ១៩៨១ មិនដឹង ៨០ មិនដឹង តាមខ្ញុំចាំដូច៨១ ។ ខ្ញុំនៅផ្ទះដាច់ដោយឡែកពីគេ នៅសំឡូតនេះ ខ្ញុំនៅផ្ទះដាច់ដោយឡែកពីគេ ឆ្ងាយពីគេ ។ ខ្ញុំចូលចិត្តបាញ់ពពួល ។ ខ្ញុំនៅក្បែរផ្ទះខ្ញុំហ្នឹង មានកែសមួយកែស គេកប់កាំភ្លើងមួយកែស ។ ខ្ញុំទៅរើសកាំភ្លើងមួយដើមយកមក ខ្ញុំមកដុសលាង ។ ខ្ញុំដោះស្នូកដោះអីវាចេញ ហើយខ្ញុំដាក់គ្រាប់បញ្ចូលទៅក្នុងឡុតគ្រាប់ហ្នឹង ឆ្នាំងគ្រាប់នោះ ។ ដល់ដាក់ក្នុងឆ្នាំងគ្រាប់ហ្នឹងទៅ ខ្ញុំចាក់ប្រេងម៉ាស៊ូតពីលើ ។ ខ្ញុំដាក់កាណុងទៅអ៊ីចេះ ដៃខ្ញុំទប់កាណុងពីលើអ៊ីចេះ ខ្ញុំយកក្រណាត់ជូនអាម៉ាស៊ូតហ្នឹង ។ ប្រពន្ធខ្ញុំគាត់នៅនោះ ចម្ងាយពីនេះពីខ្ញុំ ។ គាត់សួរខ្ញុំថា អុញដោះអ៊ីចឹងចេញដែរ? ខ្ញុំរកនឹកពាក្យដែលសួរហ្នឹងមិនទាំង

ទាន់ផងគាត់ លូនពីនាយមក មកកេះកៃ ដល់កេះកៃទៅគាត់រត់ វាផ្ទុះទៅដាច់ដៃខ្ញុំមួយក្រហត ។ គាត់ពេទ្យស្រាប់គាត់ ចងហ្គារ៉ូ ហើយបណ្តើរគ្នាប្តីប្រពន្ធទៅពេទ្យបាត់ទៅ ។ អត់ប៉ង់សេទេ ចងហ្គារ៉ូ រឹតហ្គារ៉ូអីចេះ ហើយនាំទៅពេទ្យគេកាត់បណ្តោយ។ ដុកទ័រដែលកាត់ខ្ញុំនៅធ្វើប្រធានពេទ្យសំឡូតរាល់ថ្ងៃ ។

**ស៖** ថាតើលោកធ្លាប់មានទម្លាប់លាងកាំភ្លើង ឬក៏ដោះកាំភ្លើងហ្នឹងរយៈពេលប៉ុន្មានដែរ? ប៉ុន្មានដង? ហើយនៅពេលដែរដោះហ្នឹងលោកលាងកាំភ្លើងហ្នឹងនៅពេលដែលមានគ្រាប់វាបញ្ចូលទៅក្នុងបង់ហើយ ឬក៏យ៉ាងម៉េច? ឬក៏អានេះជាការដែលគេបង្រៀនលោកឲ្យលោកធ្វើការលាងកាំភ្លើងតាមរបៀបហ្នឹង?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! កាំភ្លើងខ្លីខ្ញុំមានតាំងពីប្រហែលពី១៩៧៣ ខ្ញុំមិនដែលបាញ់មួយគ្រាប់ទេ ។ ខ្ញុំចេះបាញ់នៅឆ្នាំ១៩៨០ ចេះបាញ់សត្វ ។ អ្នកដែលបង្រៀនឲ្យខ្ញុំបាញ់នេះ ប្អូនថ្លៃនួន ជា ហ្នឹងមិត្តភក្តិខ្ញុំបង្រៀនឲ្យខ្ញុំចេះបាញ់ ។ ហើយដល់ក្រោយមក ខ្ញុំដោះកាំភ្លើងដែលដាក់គ្រាប់នៅខាងក្នុងជាលើកទីពីរ នៅពេលដែលគ្រោះថ្នាក់ហ្នឹងជាលើកទីពីរ លើកមុនម្តង។ ប្រពន្ធខ្ញុំគាត់អត់ឃើញទេ ។ សូមបញ្ជាក់ជូនលោកចៅក្រមថាប្រពន្ធខ្ញុំជាមនុស្សវពិស ហើយរហ័ស និយាយផុតពីមាត់មិនទាន់ទេទៅដល់ហើយ ។ ដូច្នេះរកនឹងខឹងប្រពន្ធក៏ខឹងមិនកើត ទម្លាប់គាត់វាអ៊ីចឹង ។ ហើយតាំងពីរបួសដៃមកខ្ញុំលែងហ៊ានបាញ់សត្វអីទៀតទៅ ។

[១៦:១៨:០៦]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណ ខ្ញុំពុំមានសំណួរបន្ថែមទៀតចង់សួរទៅកាន់ជនជាប់ចោទទេ លោកប្រធាន ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ដល់ពេលចៅក្រមអស់សំណួរស្របគ្នាហ្នឹង ពេលវេលាសវនាការហ្នឹងក៏ដល់ម៉ោងត្រូវសម្រាកល្ងម ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងប្រកាសសម្រាកសវនាការសម្រាប់ថ្ងៃនេះគឺផ្អាកត្រឹមនេះ ហើយសវនាការលើកទៅបន្តនៅថ្ងៃស្អែកចាប់ពីវេលាម៉ោងប្រាំបួនព្រឹក ហើយដំណើរការសវនាការថ្ងៃស្អែកនេះ គឺយើងនឹងធ្វើសវនាការបន្ត ស្តាប់ចម្លើយជនជាប់ចោទអំពីអត្តចរិតរបស់គាត់ដែលត្រូវសួរដោយភាគីតំណាងសហព្រះរាជអាជ្ញាហើយនិងមេធាវីការពារ ។ ហេតុដូច្នេះ ដូចសូមភាគីជ្រាប ។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់មកកាន់សាល

សវនាការនៅថ្ងៃ ស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹកជាកំណត់ ៕

**លោកស្រី សែ កុលវុឌ្ឍីៈ**

សូមអញ្ជើញក្រោកឈរ!

*[សវនាការផ្អាកនៅម៉ោង ១៦:១៩នាទី]*